ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយរូប ត្រូវបានជ្រើសរើស សម្រាប់ពានរង្វាន់ណូបែលអាស៊ីឆ្នាំ២០១៨
- វត្តមានព្រះពុទ្ធសាសនានៅក្នុងសម័យអង្គរ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ២២៤ ខែសីហា ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២២៤ ខែសីហា ឆ្នាំ២០១៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


### សំបុត្រ

- ណូបែលអាស៊ីៈ ប្រវត្តិសង្ខេបរបស់លោក ឆាំង យុ....................១

### ផ្នែកឯកសារ

- ពីអ្នកបម្រើការងារនៅមន្ទីរស-២១ ក្លាយជាអ្នកទោស................ ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- តើ អៀងធីរិទ្ធ គួរត្រូវផ្តន្ទាទោសកម្រិតណា? ..........................១០
- រឿងរ៉ាវអតីតកាល ដែលមិនអាចបំភ្លេច ............................ ១៤
- វ៉ាន ម៉ុនៈ នារីពេទ្យជំនាញផ្នែកទូទៅនៅមន្ទីរពេទ្យ៦មករា ........ ១៧
- ការផ្សះផ្សាតាមរយៈការផ្លាស់ប្តូរផ្នត់គំនិតរបស់និស្សិតកម្ពុជា ....២១
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយរូប.......................៣០
- អតីតយោធាខ្មែរក្រហម ដែលបានអមដំណើរ ប៉ុល ពត ..........៣២
- មិនដឹងថា ខ្មែរក្រហមបង្កត់បាយ វាយធ្វើបាប ចាប់ខ្លួន........... ៣៤

### ផ្នែកច្បាប់

- ភាពមិនប្រក្រតីនៃប្រព័ន្ធយុត្តិធម៌ៈ សេចក្តីសម្រេចរបស់.......... ៣៨

### វេទិកាពិភាក្សាសាធារណៈ

- ការបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........... ៤៣
- វត្តមានព្រះពុទ្ធសាសនានៅក្នុងសម័យអង្គរ..........................៤៦
- តើយុវវ័យជំនាន់ក្រោយយល់យ៉ាងណា.............................៤៨
- ការយល់ឃើញរបស់អ្នកស្រាវជ្រាវបរទេសបន្ទាប់ពីទស្សនា ...... ៥០
- គរុសិស្សនៅខេត្តព្រៃវែងទទួលការបណ្តុះបណ្តាលបន្ថែម ......... ៥២

### ទំព័រស្រាវជ្រាវរកគ្រួសារ

- បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម .............៥៤
- ម៉េង ឆេង៖ មន្ត្រីរដ្ឋបាលព្រលានយន្តហោះ..........................៥៩




សុត សុខេម ហៅឡាច អាយុ ៦៦ឆ្នាំ សព្វថ្ងៃរស់នៅ
ក្នុងឃុំសន្លុង ស្រុកត្រាំង ខេត្តតាកែវ


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម,៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា


***ស្នេរលេខនេះ៖*** *អ៊ុន សុដាវី, សោម ប៊ុនថន, ដារ៉ាវដ្ឋ មេត្តា, ហូ ថុនា, អាលីសុន វែលខេស, វ៉ាន់ថាន់ ពៅដារ៉ា, ទ្រី សុជាតា, សាន ប៊ុនស៊ីម, ឆេង វ៉េង, ង៉ូវ ដីហ័រ, ឡុង មុនីវណ្ណ, ប៉ាង ពីវ័ន្ត និង វេនី ខកហ្កៀល* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *ហូ ថុនា, អ៊ុន សុដាវី និង ដារ៉ាវដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដាវី* ***និពន្ធនាយកទូទៅ៖*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក៖*** *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គឹម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វ៉េង*

**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# ណូបែលអាស៊ី ៖ ប្រវត្តិសង្ខេបរបស់លោក ឆាំង យុ ម្ចាស់ពានរង្វាន់ រ៉ាម៉ុន ម៉ាក្សេសេយ៍សេយ៍ ឆ្នាំ២០១៨

របបប្រល័យពូជសាសន៍នៅកម្ពុជា កើតឡើងរវាងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានបន្តឲ្យប្រជាជនប្រមាណជាង ពីរលាននាក់ស្លាប់បាត់បង់ជីវិត។ នេះជាផ្នែកមួយនៃដំពូក ដ៏រន្ធត់នៅក្នុងប្រវត្តិសាស្ត្រដ៏វែងអន្លាយ និងខ្មៅងងឹតស្តីពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការចងចាំជាសមូហភាព របស់អ្នករស់រានមានជីវិត ក៏ដូចជាឯកសារដើមទាក់ទងនឹង របបឃោរឃៅនេះ ពិតជាមានសារសំខាន់យ៉ាងក្រៃលែង ដែលមិនគួរកប់ចោលជាមួយនឹងអតីតកាលនោះទេ។ លោក ឆាំង យុ ក្នុងនាមជាជនជាតិខ្មែរមួយរូប បានប្រើប្រាស់ជីវិត របស់ខ្លួនដើម្បីបុព្វហេតុដ៏ធំធេងក្នុងការចងក្រងឯកសារ និង ផ្តល់តម្លៃដល់ការចងចាំ និងកត់ត្រាពីអំពើប្រល័យពូជសាសន៍ ដែលដើរតួនាទីយ៉ាងសំខាន់ចំពោះដំណើរការសំណងផ្លូវច្បាប់ ការផ្សះផ្សាជាតិ និងការធ្វើឲ្យសះស្បើយរបួសផ្លូវចិត្ត។ ទន្ទឹម នឹងនេះដែរ ការងាររបស់លោក ក៏មានតួនាទីចម្បងក្នុងការ ធានាថា អតីតកាលត្រូវបានថែរក្សាយ៉ាងត្រឹមត្រូវជានិរន្តរ៍។

លោក ឆាំង យុ បានចាប់កំណើតនៅក្នុងគ្រួសារវណ្ណៈ កណ្តាលមួយនៅក្នុងទីក្រុងភ្នំពេញ។ ស្ថិតក្នុងវ័យ ១៤ឆ្នាំ លោក ព្រមទាំងក្រុមគ្រួសារបងប្អូនរបស់លោក ត្រូវបានកង កម្លាំងខ្មែរក្រហម ដែលជាទូទៅគឺជាយុវជនវ័យក្មេងមកពីទី ជនបទ និងទទួលការអប់រំក្នុងសាលារៀនតិចតួចបង្ខំឲ្យចាក ចោលផ្ទះសម្បែង និងសហគមន៍របស់ខ្លួន។ គ្រួសាររបស់ លោកបានរួមដំណើរជាមួយនឹងប្រជាជនដទៃទៀត ទៅកាន់ តំបន់ខ្សត់ខ្សោយស្ថិតនៅទីជនបទក្នុងប្រទេសកម្ពុជា។ ទីនោះ គឺជាទីកន្លែង ដែលកុមារត្រូវបានបំបែកចេញពីឪពុកម្តាយ របស់ខ្លួន និងទទួលរងការសាបព្រួសមនោគមន៍វិជ្ជា។ កុមារ ត្រូវបានអប់រំឲ្យប្រកាន់យកមនោគមន៍វិជ្ជាជ្រុលនិយម ដោយ ប្តេជ្ញាបង្កើតជាសង្គមជាតិថ្មីមួយ តាមរយៈពលកម្មធ្ងន់ធ្ងរ ផ្អែកលើការអនុវត្តទ្រឹស្តីកសិកម្ម ហួសវិស័យ ដែលខុសប្លែក ទាំងស្រុងពីចំណេះដឹង និងតម្លៃបែបលោកខាងលិច។ លោក ឆាំង យុ និងក្រុមគ្រួសារបានប្រឈមនឹងភាពលំបាកលំបិន។ លោកក៏ត្រូវទទួលរងទារុណកម្ម និងការឃុំឃាំងខ្លួន នៅពេល មានវ័យជំទង់ ដោយហេតុថាលោកបានបេះបោចផ្សិតព្រៃ ដើម្បីផ្គត់ផ្គង់បងស្រីស្រេកឃ្លានរបស់ខ្លួន។ មិនតែប៉ុណ្ណោះ លោកបានទទួលរងការឈឺចាប់ ដោយសារការស្លាប់ដោយ មិនសមហេតុផល និងយ៉ាងវេទនារបស់សាច់ញាតិប្រមាណ ជាង៦០នាក់ ដែលលោកមិនមានចេតនារំឭកអំពីឈ្មោះអ្នក ដែលបាត់បង់ជីវិតទាំងនោះ។ ម្តាយរបស់លោក បានខ្នះខ្នែង បញ្ជូនលោកឲ្យឆ្លងដែនទៅកាន់ប្រទេសថៃ ដើម្បីសេរីភាព ហើយបន្ទាប់មកទៀតដោយបំពេញតាមសេចក្តីប្រាថ្នារបស់ ម្តាយ នៅវ័យ១៧ឆ្នាំ លោកបានទៅដល់ប្រទេសហ្វីលីពីន ជាជំរំដែលលោកអាចស្វែងរកច្រកចេញ និងផ្ញើខ្លួនជាជន ភៀសខ្លួននៅសហរដ្ឋអាមេរិក។ នៅលើទឹកដីថ្មីនេះ លោក បានក្តាប់យកឱកាសទទួលការអប់រំ ព្រមទាំងបញ្ចប់ការ សិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយ និងបំពេញការងារនៅ ក្នុងអង្គភាពការពារប្រឆាំងឧក្រិដ្ឋកម្ម នៅក្នុងក្រុងដាឡាស រដ្ឋតិចសាសនាពេលប៉ុន្មានឆ្នាំក្រោយមក។ នៅក្នុងឆ្នាំ១៩៩២ បន្ទាប់ពីសណ្តាប់ធ្នាប់ក្នុងស្រុកត្រូវបានស្តាឡើងវិញ លោក បានត្រឡប់មកកាន់ប្រទេសកម្ពុជា ហើយបានចូលរួមដឹកនាំ កម្មវិធីបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ នៃវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ និងអាជ្ញាធរអន្តរកាល សហប្រជាជាតិនៅកម្ពុជា។

លោកបានរកឃើញបេសកម្មយូរអង្វែងរបស់ខ្លួននៅក្នុង

ឆ្នាំ១៩៩៥ ខណៈពេលដែលលោកត្រូវបានជ្រើសរើសជាផ្នែកមួយនៃកម្មវិធីអំពើប្រល័យពូជសាសន៍កម្ពុជារបស់សាកលវិទ្យាល័យយ៉េល ក្រោមការឧបត្ថម្ភរបស់សភាសហរដ្ឋអាមេរិក និងបានដឹកនាំគ្រប់គ្រងមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងទីក្រុងភ្នំពេញ។ លោកមានតួនាទីស៊ើបអង្កេត និងប្រមែប្រមូលចងក្រងឯកសារទាក់ទងនឹងអំពើឃោរឃៅរបស់ខ្មែរក្រហម។ នៅក្នុងឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឋានៈជាមជ្ឈមណ្ឌលឯករាជ្យ ដែលស្ថិតក្រោមការដឹកនាំ និងប្រតិបត្តិការដោយជនជាតិកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩៥ រហូតមកដល់បច្ចុប្បន្ន ដោយមានលោក ឆាំង យុ គឺជានាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជា បានពង្រីកបន្ថែមលើការងារចម្បងរបស់ខ្លួនឥតឈប់ឈរ តាមរយៈការរួមបញ្ចូលការផ្តួចផ្តើម ពោរពេញដោយការបង្កើតថ្មីដើម្បីផ្សព្វផ្សាយនិងអប់រំប្រជាជនកម្ពុជាជំនាន់ក្រោយអំពីជំពូកដ៏សោកសៅនៅក្នុងប្រវត្តិសាស្ត្រប្រទេសជាតិ។ បន្ថែមលើសពីនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាជាប្រភពព័ត៌មានបឋមនៃឯកសារភ័ស្តុតាងនានា គាំទ្រដល់ការងារនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលចូលរួមដោយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោស និងវិនិច្ឆ័យលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដ៏ឃោរឃៅ បង្កឡើងដោយមេដឹកនាំនៃរបបខ្មែរក្រហម។ សវនាការស្តីពីឧក្រិដ្ឋកម្មសង្គ្រាមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្តើមនៅក្នុងឆ្នាំ២០០៦។ ទន្ទឹមនឹងនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា បានដើរតួនាទីជាអ្នកជំរុញដ៏សំខាន់ក្នុងការលើកកម្ពស់«ការចងចាំ និងយុត្តិធម៌ ឲ្យក្លាយជាមូលដ្ឋានគ្រឹះចាំបាច់ចំពោះនីតិរដ្ឋ និងការផ្សះផ្សាជាតិយ៉ាងពិតប្រាកដ»។



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (រូបថតដោយ អ៊ូច មករា)

កិច្ចខិតខំប្រឹងប្រែង ដែលមានមុខងារច្រើនសណ្ឋាន របស់លោក បានជះឥទ្ធិពលវិជ្ជមានជាបន្តបន្ទាប់លើការផ្ញើ អន្តរកាលពីសង្គមបែកខ្ញែកមួយទៅជាសង្គមរួបរួមមួយតាម រយៈការទទួលយកការទទួលខុសត្រូវ ការទទួលស្គាល់ការ ឈឺចាប់របស់មនុស្សជាតិ ដែលបង្កឡើងដោយគេរដំណែល នៃរបបនេះ និងឆ្ពោះទៅកាន់ការបង្រួបបង្រួមរបស់ប្រជាជន អមជាមួយនឹងគោលដៅរួមគ្នាក្នុងការកសាងវិចារណញ្ញាណ រួម និងរឹងមាំជាងមុនៗ

ចាប់តាំងពីការកកើតរបស់ខ្លួនមក មជ្ឈមណ្ឌលឯកសារ កម្ពុជា បានប្រមែប្រមូលចងក្រងលើសពីមួយលានឯកសារ ដោយជាងពាក់កណ្ដាលនៃឯកសារទាំងនេះ បានផ្ដល់ជា ភ័ស្ដុតាងដល់សវនាការខុក្រិដ្ឋកម្មសង្គ្រាម ហើយត្រូវបាន បំប្លែងជាឯកសារអេឡិចត្រូនិច ដែលសាធារណជនអាចប្រើ ប្រាស់បានតាមប្រព័ន្ធអ៊ីនធឺណែតៗ មជ្ឈមណ្ឌលក៏សម្រេច បានកិច្ចការនានាដូចជា ក) ដៅទីតាំងរណ្ដៅសាកសពនៃវាល ពិឃាតកម្ពុជាចំនួនជាង២ម៉ឺន នៅលើផែនទីបែបឌីជីថល ខ) ធ្វើកំណាយគម្រូគ្រោងឆ្អឹងមនុស្ស ដែលនៅសេសសល់ដើម្បី ធ្វើកោសល្យវិច័យ គ) ធ្វើបទសម្ភាសជាមួយជនរងគ្រោះ និងជនដៃដល់ជាង១ម៉ឺននាក់ ឃ) បញ្ចូលកម្មវិធីអប់រំទូទាំង ប្រទេសស្ដីពីអំពើប្រល័យពូជសាសន៍ យុត្តិធម៌អន្តរកាល និង សិទ្ធិមនុស្ស ព្រមទាំង ង) លើកកម្ពស់ការចូលរួមជាសាធារណៈ នៅក្នុងដំណើរការទាំងមូលៗ ការងាររបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ផ្ដោតលើទាំងអតីតកាល និងអនាគតរបស់ ប្រទេសកម្ពុជាៗ លោក ឆាំង យុ ទទួលស្គាល់ថា ការថែរក្សា ការចងចាំ និងកំណត់ត្រាអំពីអតីតកាល ប្រៀបបានទៅនឹង កំពែងការពារប្រឆាំងនឹងអ្នកទាំងឡាយណាដែលមានបំណង បំភ័ន្ត ឬលុបបំបាត់នូវអ្វីដែលបានកើតមានឡើងៗ

លោក ឆាំង យុ សព្វថ្ងៃ ស្ថិតក្នុងវ័យ ៥៧ឆ្នាំ កំពុងផ្ដោត លើការសាងសង់អគារវិទ្យាស្ថាន ស្លឹករឹត ដែលនឹងរួមបញ្ចូល នូវ១) សារមន្ទីរ ២) បណ្ណសារដ្ឋាន ៣) មជ្ឈមណ្ឌលស្រាវជ្រាវ ៤) កម្មវិធីសិក្សាកម្រិតខុត្តមស្ដីពីខុក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិ និង៥) វិចិត្រសាលសហសម័យៗ វិទ្យាស្ថានស្លឹករឹត នឹង មិនត្រឹមតែបន្តនិរន្តរភាពនៃការងារ ដែលមជ្ឈមណ្ឌលឯកសារ កម្ពុជា សម្រេចបានតែប៉ុណ្ណោះទេ វិទ្យាស្ថាននេះ ក៏នឹងមាន តួនាទីជាមជ្ឈមណ្ឌលធនធានសម្រាប់ពិភពលោក ដែលធ្លាប់ ឆ្លងកាត់ និងបន្តរងការគំរាមកំហែងពីសំណាក់អំពើឃោរ ឃៅទ្រង់ទ្រាយធំ និងអំពើប្រល័យពូជសាសន៍ៗ

ចំពោះលោក ឆាំង យុ អ្វីៗទាំងអស់នេះមិនមែនជា បេសកកម្ម ដែលកើតមានដោយឯក ឯងនោះទេ ក៏ប៉ុន្តែជាការ តាំងចិត្តដ៏មោះមុតរបស់លោកៗ អ្វីៗទាំងនេះគឺដើម្បីម្ដាយ ដែលបានខ្ចីប្រាក់ពីអ្នកជិតខាងចំនួនប្រាំដុល្លារសហរដ្ឋអាមេរិក ដើម្បីអាចឲ្យលោកចាកចេញពីប្រទេសកម្ពុជានៅពេលដែល លោកមានវ័យជំទង់ និងដើម្បីអ្នករាល់គ្នា ដែលលោកមិន អាចជួបរហូត នៅពេលលោកមានវ័យ៣០ឆ្នាំៗ លោកបាន លើកឡើងថា៖ «ខ្ញុំធ្វើកិច្ចការទាំងអស់នេះដើម្បីម្ដាយរបស់ខ្ញុំ ដែលបានរងទុក្ខវេទនាៗ ខ្ញុំចង់ឲ្យគាត់មានមោទនភាពចំពោះ ខ្ញុំ ហើយខ្ញុំចង់ឲ្យគាត់ក្លាយជាស្ត្រីដ៏រីករាយម្នាក់ ដែលមិន ចាំបាច់ចារទុកនូវសោកនាដកម្មទាំងនេះនៅក្នុងចិត្ត ក៏ដូចជា ជីវិតរបស់គាត់»ៗ នេះជាការប្ដេជ្ញាអស់ពីចិត្ត ដែលលោក បានពង្រីកឲ្យក្លាយទៅជាបេសកកម្មនៃការចងចាំ យុត្តិធម៌ និងការជាសះស្បើយសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបៗ

ក្នុងការសម្រេចជ្រើសយកលោក ឆាំង យុ ឲ្យទទួលពាន រង្វាន់ រ៉ាម៉ុន ម៉ាក្សសេយ៍សេយ៍ ឆ្នាំ២០១៨ គណៈកម្មការ បានទទួលស្គាល់អំពីកិច្ចខិតខំប្រឹងប្រែងដ៏ថ្លៃថ្លា និងធំធេង របស់លោក ក្នុងការរក្សាការចងចាំនៃអំពើប្រល័យពូជសាសន៍ នៅកម្ពុជា ក៏ដូចជាភាពជាអ្នកដឹកនាំ និងចក្ខុវិស័យរបស់ លោក ក្នុងការបញ្ជាក់ឲ្យឃើញថា ការចងចាំអំពីភាពរន្ធត់ ដែលកើតមានអាចក្លាយជាគ្រឹះសម្រាប់ការកសាងឡើងវិញ នូវសង្គមមួយ ដែលប្ដូរផ្ដាច់ចំពោះអនាគត តាមរយៈការ ស្វែងរកការពិត និងថែរក្សាយុត្តិធម៌សម្រាប់ប្រទេសជាតិ របស់លោក និងពិភពលោកៗ

មជ្ឈមណ្ឌលឯកសារកម្ពុជា

# ពីអ្នកបម្រើការងារនៅមន្ទីរស-២១ ក្លាយជាអ្នកទោសជាប់ឃុំឃាំងនៅមន្ទីរស-២១

*(ដកស្រង់ចេញពីឯកសារលេខ D07385)*

អូន ស្រស់ ហៅ សែង ភេទប្រុស មានអាយុ២៩ឆ្នាំ (កើតឆ្នាំ១៩៤៨) កើតនៅភូមិកញ្ចុំ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ មានបងប្អូនបង្កើតចំនួនប្រាំនាក់ ប្រុស៤នាក់ និងស្រីម្នាក់។ ឪពុកឈ្មោះ គិន អាយុ ៦៩ឆ្នាំ និងម្តាយឈ្មោះ ណាំ អាយុ៦៥ឆ្នាំ។ ប្រពន្ធ ឈ្មោះ រ៉ា មានអាយុ២៦ឆ្នាំ និងមានកូនស្រីម្នាក់អាយុប្រាំមួយខែ។ មុនអង្គការចាប់ខ្លួន សែង បានធ្វើការនៅក្នុងមន្ទីរ២១ និងត្រូវអង្គការចាប់ខ្លួននៅក្នុងខែមីនា ឆ្នាំ១៩៧៧ ពីបទធ្វើសកម្មភាព សេ.អ៊ី.អា ប្រឆាំងនឹងបដិវត្តន៍។ ចំពោះចម្លើយរបស់ សែង នៅក្នុងឯកសារចម្លើយសារភាពនេះ យើងមិនដឹងថា សែង ឆ្លើយការពិត ឬយ៉ាងណានោះទេ។ ខាងក្រោមនេះ គឺជាការដកស្រង់ដោយសង្ខេបនូវប្រវត្តិ និងសកម្មភាពរបស់ សែងរួមជាមួយបក្ខពួកបានធ្វើកន្លងមក ដើម្បីប្រឆាំងនឹងបដិវត្តន៍៖

ឆ្នាំ១៩៥៦ សែង បានចូលរៀននៅសាលាបឋមសិក្សាឈើទាលជ្រុំ។ លុះដល់ឆ្នាំ១៩៦២ បានចូលរៀននៅអនុវិទ្យាល័យចំបក់ និងបន្តរៀនដល់ថ្នាក់ទី២ នៃវិទ្យាល័យ១៨មីនា នៅក្រុងភ្នំពេញនាឆ្នាំ១៩៦២។ កាលនោះ សែង បានស្នាក់នៅជាមួយបងម្នាក់ធ្វើគ្រូ ប៉ុន្តែបងរបស់ សែង បានផ្លាស់មកភ្នំពេញដើម្បីរៀនបន្ថែម។ ក្នុងឆ្នាំនេះដែរ សែង បានជាប់ចលនាបដិវត្តន៍ តាមរយៈឈ្មោះ រិន។ មួយឆ្នាំក្រោយមក សែង បានរត់ចេញពីគ្រួសារ ទៅនៅមន្ទីរបដិវត្តន៍ជាមួយឈ្មោះ ឆាយ នៅភ្នំពេញ។ ឆ្នាំ១៩៦៨ សែង ត្រូវបានអង្គការផ្លាស់ឲ្យទៅកសាងមូលដ្ឋានបដិវត្តន៍ នៅជាយក្រុង (នៅព្រែកប្រា) ជាមួយឈ្មោះ ប្រាក់ (គណៈតំបន់២៥) ក្រោមការដឹកនាំរបស់ ឆយ។ នៅក្នុងឆ្នាំនេះដែរ បងបង្អស់របស់ សែង ត្រូវបានខ្មាំងចាប់ខ្លួនដោយសារបានចូលបម្រើបដិវត្តន៍។ ចាប់តាំងពីពេលដែលខ្មាំង ចាប់បងមក សែង តែងឃើញបុរសម្នាក់មកទិញបន្លែរបស់ខ្លួននៅផ្សារក្បាលថ្នល់។ បុរសនោះបាននិយាយជាមួយ សែង ថា «ខ្មាំងបានចាប់បងរបស់ឯងយកទៅដាក់គុកព្រោះបានចូលបម្រើបដិវត្តន៍។ ឥឡូវនេះខ្មាំងបានរៀបចំយកបងឯងទៅបាញ់ចោលហើយ។ តើឯងចង់ឲ្យបងរបស់ឯងរួចចេញពីគុកវិញដែរឬទេ?» បុរសនោះបានបន្តថា «បើមានគេជួយបងឯងឲ្យរួចខ្លួនឯង និងបងរបស់ឯងត្រូវបម្រើគេអស់មួយជីវិត»។ ពេលនោះ សែង ក៏បានយល់ព្រម ដោយបានធ្វើការស្បថស្បែជាមួយបុរសនោះទៀតផង។ ប៉ុន្តែ សែង មិនទាន់បានស្គាល់ឈ្មោះបុរសនោះទេ ហើយក៏មិនដឹងថា បុរសនោះមានគោលបំណងអ្វីឲ្យប្រាដកដែរ។ ទើបតែនៅក្នុងឆ្នាំ១៩៧៤នេះទេ ទើប សែង ដឹងថាបុរសនោះមានគោលបំណងអូសទាញខ្លួនឲ្យចូលបម្រើការងារជា សេ.អ៊ី.អា។ ហេតុនេះ សែង បានគិតថា ខ្លួនបានចូល សេ.អ៊ី.អា នៅក្នុងឆ្នាំ១៩៦៨ ទោះបីខ្លួនមិនទាន់បានធ្វើសកម្មភាពអ្វីបម្រើដល់ការងារ សេ.អ៊ី.អា ក៏ដោយ។ នៅឆ្នាំ១៩៦៩ សែង បានទទួលដំណឹងថា បងរបស់ខ្លួនត្រូវខ្មាំងយកទៅសម្លាប់ ហើយបុរសម្នាក់នោះ ក៏មិនដែលឃើញមកជួបនឹង សែង ទៀតដែរ។

នៅក្នុងឆ្នាំ១៩៧០ អង្គការបានចាត់ឲ្យ សែង មកធ្វើការនៅភ្នំពេញវិញ មករួមក្នុងសាខាជាមួយឈ្មោះ ចេង ក្រោមការដឹកនាំរបស់ឈ្មោះ អាំ (បច្ចុប្បន្នគណៈតំបន់៣៥)។ ឆ្នាំ

១៩៧១ អាំ ត្រូវផ្លាស់ទៅនៅជនបទ រីឯ ចេង ត្រូវខ្មាំងចាប់ខ្លួន ចំណែក សែង ក៏ផ្លាស់ទៅនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ម៉ី ឌីម៉ង់ វិញ។ នៅចុងឆ្នាំ១៩៧១ សែង និងបងទី២ម្នាក់ទៀត ត្រូវខ្មាំងចាប់ខ្លួន។ នៅពេលខ្មាំងសួរចម្លើយនៅកន្លែងប៉ូលីសពិសេស សែង បានឃើញបុរសដែលសន្យាថា ជួយបងទីមួយរបស់ខ្លួននៅទីនោះដែរ។ បុរសនោះបានមកជួប សែង ជាលើកទី២ ដោយបាននិយាយថា នឹងជួយ សែង រួមជាមួយ និងបងទី២។ ពេលនោះ សែង មិនបានឆ្លើយតបទេ ព្រោះមិនមានជំនឿទៅលើបុរសម្នាក់នោះ។ ក្រោយមក សែង បានដឹងថា បងទី២ របស់ខ្លួនត្រូវខ្មាំងធ្វើទារុណកម្មរហូតដល់ស្លាប់។

លុះដល់ឆ្នាំ១៩៧៣ សែង បានផ្លាស់ទៅគុកធំ។ នៅគុកធំ ម៉ី ឌីម៉ង់ តែងមកឃោសនាបំភ័យ សែង ជាច្រើនលើកច្រើនសាថា សែង មានទោសធ្ងន់រហូតដល់ប្រហារជីវិត តែបើមានលុយសូកប៉ាន់ ឬមានអ្នកជួយទើបអាចធូរស្រាលខ្លះ។ នៅឆ្នាំ១៩៧៤ តុលាការសឹកចាប់ផ្តើមហៅ សែង ទៅកាត់ទោសរយៈពេលប្រាំទៅប្រាំមួយខែ ក្នុងមួយខែហៅសួរម្តង។ នៅខែសីហា តុលាការសឹកបានហៅ សែង ទៅសួរម្តងទៀត ប៉ុន្តែត្រូវផ្អាកវិញ។ ពីរបីថ្ងៃក្រោយមក សុក បានសរសេរសំបុត្រមួយច្បាប់មកប្រាប់ សែង ថា តុលាការសឹកបានសម្រេចកាត់ទោសប្រហារជីវិត នៅក្នុងខែតុលា ឆ្នាំ១៩៧៤ នេះហើយ។ ដំណឹងនេះបានធ្វើឲ្យ សែង មានក្តីតក់ស្លុតជាខ្លាំង។ សែង បានពឹង សុក ឲ្យជូនដំណឹងនេះទៅអគ្គការ ដើម្បីឲ្យអគ្គការជួយជាលុយកាក់ដល់ខ្លួនដើម្បីបានបន្ថយទោស ប៉ុន្តែបីបួនថ្ងៃក្រោយមក សុក បានប្រាប់ សែង វិញថា អគ្គការមិនជួយទេ ប៉ុន្តែមានអ្នកផ្សេងចង់ជួយបើសុខចិត្តបម្រើគេ។ ដើម្បីរស់ជីវិត សែង បានយល់ព្រមគ្រប់យ៉ាង ហើយបានដឹងថា សុក ក្បត់នឹងបដិវត្តន៍។ លុះដល់ខែតុលា ឆ្នាំ១៩៧៤ តុលាការសឹកបានហៅ សែង ទៅកាត់ទោស ដោយសម្រេចឲ្យជាប់គុកប្រាំមួយឆ្នាំ និងធ្វើការជាទំងន់។ សែង មានក្តីត្រេកអរជាខ្លាំង ដោយបានរួចជីវិត ប៉ុន្តែ ក៏មានការព្រួយបារម្ភណាស់ដែរ ចំពោះកិច្ចសន្យាជាមួយ សុក ព្រោះមិនដឹងថា កិច្ចការនោះមានទំហំប៉ុណ្ណាហើយជាការងារអ្វីនោះទេ។ លុះដល់ខែវិច្ឆិកា ឆ្នាំ១៩៧៤ សុក បានសរសេរសំបុត្រប្រាប់ សែង ថា «ឥឡូវនេះ គេបានជួយជីវិតឯងឲ្យរស់ហើយ។ ដូចនេះ ត្រូវបម្រើ សេ.អ៊ី.អា។ ការចូល សេ.អ៊ី.អា មានរៀបចំពិធីត្រឹមត្រូវតាមច្បាប់របស់ សេ.អ៊ី.អា។ ចាំពេលចេញពីគុក ទើបមានលទ្ធភាពធ្វើ ចំពោះការងារសុំរង់ចាំការពិគ្រោះយោបល់មួយរយៈសិន»។

នៅដើមឆ្នាំ១៩៧៥ សុក បានសរសេរសំបុត្រមួយច្បាប់ទៀតជាសំបុត្រចុងក្រោយផ្ញើមក សែង ដែលនៅក្នុងសំបុត្រនោះមានអត្ថន័យៈ ទី១. ឈ្មោះ ម៉ី ឌីម៉ង់ បានចូល សេ.អ៊ី.អា ក្នុងសភាពដូចគ្នានឹង សែង ដែរ ទី២. ខុទ្ទេសនាម សែង ឲ្យទៅនៅក្រោមការដឹកនាំរបស់ ម៉ី ឌីម៉ង់។ ប្រហែលជាម្ភៃថ្ងៃក្រោយមក ម៉ី ឌីម៉ង់ បានមកជួប សែង ហើយបាននិយាយថា ជីវិតយើងទាំងពីរមានសភាពដូចគ្នាណាស់។ ឥឡូវនេះ យើងចាប់និយាយពីការងារថ្មីរបស់យើង គឺតាមការណែនាំរបស់ សេ.អ៊ី.អា ឲ្យ សែង រស់នៅជាមួយកម្លាំងបដិវត្តន៍សិនកុំឲ្យបែកការណ៍ រួចត្រូវធ្វើយ៉ាងណាឲ្យមហាជនស្រឡាញ់ និងជឿទុកចិត្ត ងាយស្រួលធ្វើការអូសទាញ បំបែកបំបាក់ចេញពីជួរបដិវត្តន៍ទៅថ្ងៃក្រោយ។ ឥឡូវនេះ មនុស្សដែលយើងត្រូវកម្ទេចចោលតាមការណែនាំរបស់ សេ.អ៊ី.អា គឺ ឈ្មោះ ជន និង ឆយ ហើយ ឌីម៉ង់ ក៏បានចាត់ឲ្យក្រុម ទីរិទ្ធ ដាក់ថ្នាំបំពុលមនុស្សពីរនាក់នេះហើយដែរ។ នៅពេលដែលមនុស្សពីរនាក់នេះស្លាប់ សែង នឹងមានឥទ្ធិពលនៅក្នុងស្រទាប់មហាជនស្រាប់ ហើយក៏ជាពេលដែល សែង ត្រូវចាប់ផ្តើមធ្វើសកម្មភាពដែរ។ ប៉ុន្តែ សែង មិនទាន់បានធ្វើសកម្មភាពផង កងទ័ពបដិវត្តន៍ក៏បានវាយសម្រុកចូលមករំដោះទីក្រុងភ្នំពេញបានជាស្រេច។ បន្ទាប់មក វន បានហៅ សែង និង ឆយ ឲ្យទៅជួបនៅសាលាខេត្ត (តាខ្មៅ)។ នៅតាខ្មៅបានមួយអាទិត្យ វន បានឲ្យ សែង ទៅនៅមន្ទីរ៣០៥ ជាមួយ គុន នៅស្អាងប្រហែលមួយខែ។ បន្ទាប់មក អគ្គការបានឲ្យ សែង មកនៅភ្នំពេញវិញ ក្រោមការគ្រប់គ្រងរបស់ឈ្មោះ

ជន។ ពេលនោះ សែង មានភារកិច្ចដើរចាប់គិញ ដែលនៅសេសសល់លាក់ខ្លួននៅតាមផ្ទះ។ មួយខែក្រោយមក អង្គការបានចាត់ឲ្យ សែង ប្រមូលកម្មកររោងចក្រ ហើយឲ្យរៀបចំរោងចក្រកៅស៊ូកង់ឡាននៅតាខ្មៅ ឲ្យដំណើរការឡើងវិញ ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ជន ដដែល។

ប្រហែលនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៥ សែង ដែលជាអតីតអ្នកជាប់គុក ត្រូវបានផ្លាស់ប្តូរឲ្យទៅតាមជនបទដើម្បីលត់ដំកសាងខ្លួន ប៉ុន្តែមិនទាន់បានប្តូរភ្លាមៗទេ ដោយឲ្យទៅនៅជិតចំការដូងមួយរយៈពេលសិន រង់ចាំការសម្រេចចិត្តរបស់អង្គការថាត្រូវឲ្យទៅតំបន់ណា។ មួយខែក្រោយមក អង្គការបានចាត់ឲ្យ សែង មករៀបចំរោងចក្រអគ្គិសនីនៅពេទ្យលោកសង្ឃឲ្យដំណើរការឡើងវិញ ក្រោមការដឹកនាំរបស់ឈ្មោះ រិន។ នៅទីនោះបានមួយរយៈពេលខ្លីប៉ុណ្ណោះ រិន ត្រូវអង្គការផ្លាស់ឲ្យមកមន្ទីរ២១ ចំណែក សែង បានជួប សុក ជាថ្មីនិងស្ថិតនៅក្រោមការដឹកនាំរបស់ សុក។ ពេលនោះ សុក បានហៅ សែង ឲ្យជួបជាសម្ងាត់ និងបានលួងលោម សែង ជាច្រើនដោយនិយាយថា ឥឡូវនេះ សេ.អ៊ី.អា ដែលជាផ្ទៃក្នុងរបស់យើងមិនទាន់ចាប់ផ្តើមធ្វើសកម្មភាពទេ ព្រោះយើងខស្សប្រាប់ផ្លាស់ប្តូរការងារពេក។ យើងត្រូវធ្វើឲ្យអង្គការទុកចិត្តសិន ដើម្បីដណ្តើមកន្លែងកាន់ឲ្យបានច្រើន។ សុក បានប្រាប់ សែង បន្ថែមថា នៅពេលដែល សែង ជាប់គុក ខ្លួនបានរកបង្អែកដើម្បីការពារខ្លួនឯង ហើយក៏បានជួបឈ្មោះ ម៉ៃលន់ និងបានចូល សេ.អ៊ី.អា។ បន្ទាប់មកបានធ្វើសកម្មភាពដោយបានកាឡៃកម្លាំង បដិវត្តន៍ទាំងអស់ឲ្យទៅជាកម្លាំង សេ.អ៊ី.អា។ ចំពោះអ្នកដែលមិនព្រមចូលខ្លួនបានរាយការណ៍ប្រាប់ទៅគិញឲ្យចាប់យកទៅដាក់គុក ឬបាញ់ចោលខ្លះ និងបានឆ្មៀតអូសទាញកម្លាំងពីគុកមកវិញខ្លះ ដូចជា សែង និង ឌីម៉ង់ ជាឧទាហរណ៍ស្រាប់ៗ ដូច្នេះ កម្លាំង សេ.អ៊ី.អា ដែល សុកប្រមូលបានកំពុងក្តាប់កន្លែងសំខាន់ៗជាច្រើនលើកលែងតែក្រុមរបស់ ជន និងពួកថ្មីចេញ ក្រៅពីនោះខាងក្រសួងសាធារណការភាគច្រើន គឺសុទ្ធតែគ្នាយើង។ និយាយរួមគ្នាយើង មានបក្តប់ស្ទើរគ្រប់ក្រសួងមន្ទីរ ទោះក្នុងជួរកងទ័ពក៏មានគ្នាយើងដែរ។

នៅឆ្នាំ១៩៧៦ សែង ត្រូវបានអង្គការចាត់ឲ្យមកនៅមន្ទីរ២១។ មុននឹងមកមន្ទីរ២១ សុក បានហៅ សែង ទៅណែនាំចំនួនពីរលើក៖

### លើកទី១ មានតែ សែង ម្នាក់ឯង

- ស៊ើបគ្រប់យ៉ាងទាំងអស់ នៅក្នុងមន្ទីរ២១។ ស៊ើបពីចំណុចខ្លាំង និងខ្សោយរបស់គណៈកម្មាធិការបក្សមន្ទីរ២១នេះ ដើម្បីវាយប្រហារធ្វើឲ្យចុះខ្សោយឥទ្ធិពលដឹកនាំ។ ស៊ើបរកចំណុចខ្លាំង និងខ្សោយរបស់កម្មាភិបាលសួរចម្លើយទាំងអស់និងស៊ើបពីរបៀបសួរចម្លើយថាតើមានប្រសិទ្ធិភាពកម្រិតណា? និងមានគោលបំណងក្តាប់កម្មាភិបាលទាំងនោះ។ ស៊ើបពីកងការពារ និងគុកឃុំឃាំងខ្មាំង ចង់ដឹងថាតើខ្មាំងអាចមានលទ្ធភាពរត់រួចឬទេ ឬក៏យើងមកពីក្រៅមានលទ្ធភាពបំពុលខ្មាំង និងដុតបំផ្លាញគុកខ្មាំងបានឬទេ។ ស៊ើបពីខ្មាំងតើមានប៉ុន្មានប្រភេទ មកពីណាខ្លះ ហើយចម្លើយខុសគ្នាយ៉ាងម៉េចខ្លះ? និងស៊ើបពីទិសរបស់អង្គការចំពោះខ្មាំងគ្រប់ប្រភេទ។
- ក្នុងការសួរចម្លើយខ្មាំង ត្រូវធ្វើយ៉ាងម៉េចកុំឲ្យយកជាការបាន។ សួរពន្យាពេលឲ្យយូរ សួរមិនឲ្យចេញជាចម្លើយ វាយខ្មាំងឲ្យទ្រោមជិតងាប់ លែងឆ្លើយកើត ឬយកមកសួរទៀតលែងកើត និងវាយខ្មាំងឲ្យឆ្លើយប៉ាតណាប៉ាត់ណីជាដើម។
- ក្នុងការផ្ញើឯកសារខ្មាំង ដើម្បីរាយការណ៍ទៅអង្គការត្រូវធ្វើមិនឲ្យច្បាស់លាស់ បើមានឆ្លើយដាក់អ្នកណាមួយ ត្រូវដាក់អ្នកណាដែលរកមិនឃើញ ឬដាក់មនុស្សឲ្យច្រើន ហើយច្របូកច្របល់មិនដឹងថាមួយណាជាខ្មាំងមួយណាមិនមែនខ្មាំង។
- ឲ្យចុះទៅជិតស្និទ្ធនឹងមហាជននៅមន្ទីរ ២១ ទាំងអស់ដើម្បីឲ្យគេស្រឡាញ់ ជឿទុកចិត្ត។

- បើស៊ើបឃើញចំណុចខ្សោយរបស់គណៈកម្មាធិការបក្សមន្ទីរ២១ ត្រូវវាយប្រហារបំបាត់ឥទ្ធិពលដឹកនាំ ទាំងចំពោះមុខផង និងពីខាងក្រោយខ្នងផងៗ
- ត្រូវលើកទិសចុះទៅក្តាប់កម្មាភិបាល សួរចម្លើយឲ្យបានច្រើន ដើម្បីមានលទ្ធភាពការពារខ្មាំងបានកាន់តែច្រើនៗ
- ត្រូវជួយរួមចំណែកធ្វើយ៉ាងណារកគ្រប់វិធីដើម្បីដណ្តើមតំណែងគណៈកម្មាធិការបក្សមន្ទីរ២១ឲ្យបាន ព្រោះបើដណ្តើមតំណែងបាន សេ.អ៊ី.អា ងាយនឹងធ្វើសកម្មភាពគ្រប់យ៉ាងៗ
- ឲ្យប្តូរខ្សែទៅនៅក្រោមការគ្រប់គ្រងរបស់ នឿន វិញ ពេលទៅនៅមន្ទីរ២១ៗ

### លើទី២ មាននមនុស្សចំនួនប្រាំនាក់ចូលរួម

- សមាជិក សេ.អ៊ី.អា ទាំងអស់ ដែលទៅមន្ទីរ២១ ត្រូវនៅក្រោមការគ្រប់គ្រងរបស់ សុក ផ្ទាល់ ព្រោះ សុក ក៏ត្រូវទៅមន្ទីរ២១នេះដែរៗ ប៉ុន្តែក្នុងរយៈកាលដែល សុក មិនទាន់ទៅដល់ត្រូវនៅក្រោមការគ្រប់គ្រងរបស់ នឿនៗ
- ចំណុចសំខាន់របស់ សេ.អ៊ី.អា ទាំងអស់ដែល នៅមន្ទីរ២១ ត្រូវធ្វើសកម្មភាពយ៉ាងណា ដើម្បីដណ្តើមតំណែងគណៈកម្មាធិការបក្សមន្ទីរ២១ ឲ្យបានៗ
- ការងារសួរចម្លើយខ្មាំង និងការធ្វើឯកសារ គឺធ្វើមិនឲ្យត្រឹមត្រូវទេ ឯវិធីធ្វើយ៉ាងណាៗនោះ ស្រេចលើការច្នៃប្រឌិតរៀងៗខ្លួនៗ
- ចំពោះចំណុចខ្សោយ របស់គណៈកម្មាធិការបក្សមន្ទីរ២១ ដែលក្រុម សេ.អ៊ី.អា ស៊ើបបាន ត្រូវរៀបចំវាយប្រហារទាំងសម្ងាត់ទាំងចំហ ធ្វើឲ្យឥទ្ធិពលនៃការដឹកនាំរបស់គណៈមន្ទីរ២១ចុះខ្សោយៗ
- នៅក្នុងស្រទាប់មហាជនត្រូវប្រកាន់អាកប្បកិរិយាយ៉ាងណាឲ្យមហាជនស្រឡាញ់ និងជឿទុកចិត្តៗ
- ចលនាពង្រីក សេ.អ៊ី.អា ថ្មី សមាជិកម្នាក់ៗត្រូវតែធ្វើៗ
- ចំពោះភារកិច្ចរបស់ ព្រាប និង ហាន គឺបង្កចលាចលផ្សេងៗទម្លាក់កំហុសលើគណៈមន្ទីរ២១ ដើម្បីឲ្យអង្គការដកចេញ ហើយលើកគ្នាយើងចូលវិញៗ ការបង្កចលាចលនេះ គឺត្រូវវាយខ្មាំងឲ្យទ្រោម ឲ្យងាប់ (ចំពោះខ្មាំងសំខាន់ៗ) ឬលែងខ្មាំងឲ្យរត់ ដុតផ្ទះ បំពុលខ្មាំង ឬបំពុលគណៈមន្ទីរ២១ឲ្យស្លាប់តែម្តងៗ ចំពោះ ហាន ត្រូវមានភារកិច្ចមួយទៀត គឺធ្វើជានីរសាររបស់ នឿន ចេញមកជួប ខ្លួន (សុក) ចៀសវាងកុំឲ្យ នឿន ចេញមកញឹកញាប់ពេកនាំឲ្យបែកការណ៍ធ្វើឲ្យមានអន្តរាយដល់ការងារធំរបស់យើងៗ

បន្ទាប់ពី សែង បានមកនៅមន្ទីរ២១ បានមួយរយៈកាលមក ប្រហែលជានៅក្នុងខែមីនា ឆ្នាំ១៩៧៦ នឿន បានហៅ សែង ហាន និង រិន មកប្រជុំនៅផ្ទះ ខាងលិចមន្ទីរ២១ចាស់ៗ នឿន បានឲ្យសមាជិករាយការណ៍ម្តងម្នាក់ៗ ពីលទ្ធផលនៃការស៊ើបអង្កេត និងសកម្មភាព សេ.អ៊ី.អា ដែលបានធ្វើនៅមន្ទីរ២១នេះៗ បន្ទាប់ពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិក ម្នាក់ៗរួចមក នឿន បានបន្តថា «ជាជំហានដំបូង ដែល សេ.អ៊ី.អា ខាងលើមិនទាន់បានណែនាំឲ្យធ្វើការងារផង យើងធ្វើបានប៉ុណ្ណឹង វាជាជ័យជម្នះមួយធំណាស់ៗ នាពេលថ្មីៗនេះ ថ្នាក់លើ សេ.អ៊ី.អា បានណែនាំឲ្យយើងទាំងអស់គ្នាចាប់ផ្តើមធ្វើសកម្មភាពៗ តាមដំណឹងថា សុក ព្រាប និង ដែក មិនបានមកទីនេះទេ ដូច្នេះ នៅទីនេះយើងមានគ្នាតែបួននាក់ទេ ដែលត្រូវធ្វើសកម្មភាពបន្តទៅមុខទៀត»ៗ សកម្មភាពដែលត្រូវធ្វើគឺ៖

ទី១ ត្រូវស៊ើបគ្រប់បញ្ហាជាបន្តទៀត

ទី២ ការសួរចម្លើយខ្មាំង និងការធ្វើឯកសារខ្មាំង ត្រូវរកគន្លឹះបន្តកុំឲ្យច្បាស់លាស់ ៗ

ទី៣ ការចុះទៅជិតស្និទ្ធជាមួយមហាជន និងការវាយប្រហារចំណុចខ្សោយរបស់គណៈកម្មាធិការ បក្សមន្ទីរ២១ ត្រូវធ្វើបន្តទៀត និងចាប់ជំរុញឲ្យមានសកម្មភាពកាន់តែខ្លាំងឡើងថែមទៀតៗ

ទី៤ ត្រូវចុះទៅជិតស្និទ្ធជាមួយកម្មាភិបាលសួរចម្លើយសំខាន់ៗ ដើម្បីឈានទៅក្តាប់កម្មាភិបាលទាំងនោះៗ ចំពោះ

នឿន បានសម្រេចចុះទៅក្តាប់ សារ៉ាត់ រុណ និង ម៉េង។ ឯ រិន ដែលមានឥទ្ធិពលជាងគេ ត្រូវលើកទិសចុះទៅក្តាប់ ប៉ុន ហាក់ និង ត្រូវ។ ចំណែក សែង វិញ ត្រូវចុះទៅជិតស្និទ្ធនឹង ថ្វី និង អៀង ព្រោះអ្នកទាំងពីរមានចំណុចខ្សោយចង់បានប្រពន្ធ ប៉ុន្តែ អង្គការមិនទាន់រៀបចំឲ្យ។

ទី៥ ចំពោះ ហាន មានភារកិច្ចដោយឡែកជានីរសារ និងជាជំនួយការរបស់ នឿន ក្នុងការនាំដំណឹងពី នឿន ទៅ សេ.អ៊ី.អា ថ្នាក់លើ និងនាំដំណឹងពីថ្នាក់លើមក នឿន វិញ។ រីឯភារកិច្ចមួយទៀតគឺ បង្កឲ្យមានចលាចលផ្សេងៗដូចជា វាយខ្ទាំងសំខាន់ៗឲ្យរំសាប់ បំពុលខ្ទាំង និងធ្វើយ៉ាងណា ឲ្យអង្គការដកដំណែងគណៈមន្ទីរចាស់ចេញ ហើយលើកពួកយើងឡើងជំនួសវិញ។

នៅចុងឆ្នាំ១៩៧៦ សែង និង រិន ត្រូវផ្លាស់ចេញពីមន្ទីរ២១។ អង្គការបានចាត់ឲ្យ សែង ទៅនៅមន្ទីរនីរសារក្រុងជាមួយឈ្មោះ ចន រយៈពេលមួយខែ ដោយមិនបានចាត់ឲ្យធ្វើការងារអ្វីឡើយ។ បន្ទាប់មក អង្គការបានចាត់ឲ្យទៅនៅជាមួយ រិន ដើម្បីក្តាប់វិទ្យុបរទេស។ ក្រោមមកទៀត ទៅធ្វើដីដឹកថ្ម និងដឹកដីដាក់ទំនប់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ណាត។ លុះក្រោយមក អង្គការបានចាត់ឲ្យទៅអូសខ្សែលួសពីកំពង់សោមមកភ្នំពេញ ក្រោមការដឹកនាំរបស់ឈ្មោះ តែម រហូតដល់ខែមីនា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការចាប់ខ្លួន និងបានបញ្ជូនមកមន្ទីរ២១នេះ។

នៅចុងបញ្ចប់នៃចម្លើយសារភាព សែង បានសរសេរបញ្ជាក់ថា ចាប់តាំងពីអង្គការធ្វើការផ្លាស់ប្តូរចេញពីមន្ទីរ២១ ខ្លួនមិនដែលបានធ្វើសកម្មភាព សេ.អ៊ី.អា អ្វីទាំងអស់ ព្រោះដឹងច្បាស់ថា អង្គការមានការសង្ស័យមកលើខ្លួន ព្រោះការផ្លាស់ប្តូរនេះមានសភាពមិនធម្មតា គឺឲ្យនៅស្ងៀមស្ងាត់ មិនប្រគល់ការងារឲ្យធ្វើមួយរយៈ បន្ទាប់មកប្រគល់ការងារឲ្យធ្វើក៏មិនច្បាស់លាស់ដែរ។ ម្យ៉ាងទៀត ការណែនាំរបស់អង្គការរាល់លើក ក៏បានបញ្ជាក់កាន់តែច្បាស់ គឺក្នុងន័យយកមកកសាង និងឲ្យឈប់ទាក់ទងជាមួយខ្សែក្រុងទាំងអស់ ជាពិសេសទំនាក់ទំនងជាមួយ សុក និង នឿន។ សែងបានសរសេរសារភាពបន្តទៀតថា ថ្វីត្បិតខ្លួនមានជាប់ទាក់ទងជាមួយនឹងខ្សែ សេ.អ៊ី.អា តាំងពីឆ្នាំ១៩៦៨ មែន ប៉ុន្តែ សែង មិនដែលបានរៀបចំពិធីចូលជាសមាជិកទេ ហើយសកម្មភាពរបស់ខ្លួនភាគច្រើន គឺការកសាងមហាជនឲ្យធ្វើបដិវត្តន៍ ឬការធ្វើវិច្ឆេទកម្មកម្ទេចស្ពានទូតអាមេរិកជាដើម។ ឯសកម្មភាព សេ.អ៊ី.អា គឺធ្វើបានប្រហែលតែកន្លះឆ្នាំប៉ុណ្ណោះ ក្នុងឆ្នាំ១៩៧៦ នៅមន្ទីរ២១នេះ ហើយការណ៍ដែលធ្វើសកម្មភាពខូចៗនេះ គឺមកពីផុងខ្លួនជាប់លក្ខខណ្ឌ ជាមួយ សេ.អ៊ី.អា ដោយដក់ខ្លួនមិនរួច តែក្នុងចិត្តវិញ គឺចង់លាងខ្លួនឲ្យបានស្អាត ដាច់ស្រឡះពី សេ.អ៊ី.អា ណាស់។

*ឆេង វ៉ើង*

## ដំណឹងស្វែងរកពូ

នាងខ្ញុំឈ្មោះ ឡូវ៉ា សាន។ ម្តាយរបស់នាងខ្ញុំឈ្មោះ សាន ង៉ែត មកពីខេត្តកំពង់ចាម។ គាត់មានបងស្រីម្នាក់ដែលបានជួបគ្នានៅមុនពេលបងស្រីរបស់គាត់បានស្លាប់ទៅ។ ប៉ុន្តែ ម្តាយនាងខ្ញុំនៅតែមានចម្ងល់អំពីប្អូនរបស់គាត់ម្នាក់ ដែលខ្ញុំមិនដឹងប្រកបតាមភាសាអង់គ្លេសយ៉ាងណានោះទេ គ្រាន់តែដឹងថាអាចជាឈ្មោះ សារុន ឬ សារឿន និងត្រកូល ង៉ែត។ ព័ត៌មានមួយទៀត ដែលអាចជួយបង្ហាញអត្តសញ្ញាណរបស់គាត់ គឺគាត់បានត្រឡប់មករៀននៅវិទ្យាល័យពោធិ៍វាល មួយរយៈ។ ម្តាយរបស់ខ្ញុំបាននិយាយថា មកដល់បច្ចុប្បន្ន ពូរបស់ខ្ញុំមានអាយុជាង៨០ឆ្នាំហើយ។ ប៉ុន្តែមានរឿងមួយ គឺម្តាយខ្ញុំបានប្រាប់ខ្ញុំថា ពូរបស់ខ្ញុំអាចត្រូវបាននាំទៅប្រទេសថៃ។

ដូច្នេះប្រសិនបើបងប្អូនណាបានស្គាល់ពូរបស់ខ្ញុំ សូមទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។

សូមអរគុណ!

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០១៨ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃដូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប១ច្បាប់ (Resume) ។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org ។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# តើ អៀង ធីរិទ្ធ គួរត្រូវផ្តន្ទាទោសកម្រិតណា?

## *(ការយល់ឃើញរបស់ពុទ្ធសាសនិកា ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម)*

អៀង ធីរិទ្ធ ដែលជាអតីតរដ្ឋមន្ត្រីសង្គមកិច្ច និងសុខាភិបាល មានភារៈកិច្ចទទួលខុសត្រូវលើការងាររបស់ក្រសួងសង្គមកិច្ច និងមន្ទីរពេទ្យនៅទូទាំងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) បានទទួលមរណភាពនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ ក្នុងអាយុ៨៣ឆ្នាំ។ អៀង ធីរិទ្ធ គឺជាភរិយារបស់ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហម។ អៀង ធីរិទ្ធ មានកូន៤នាក់ (ស្រី៣នាក់ និងប្រុស១នាក់) និងមានឈ្មោះដើម ខៀវ ធីរិទ្ធ កើតក្នុងឆ្នាំ១៩៣២ នៅក្នុងខេត្តបាត់ដំបង ក្នុងគ្រួសារអ្នកមានទ្រព្យសម្បត្តិ។ អៀង ធីរិទ្ធ មានបងស្រីម្នាក់ឈ្មោះ ខៀវ ប៉ុណ្ណារី ដែលជាប្រពន្ធទី១របស់ ប៉ុល ពត។ អៀង ធីរិទ្ធ បានទទួលការសិក្សាផ្នែកអក្សរសាស្ត្រអង់គ្លេសពីប្រទេសបារាំង ហើយបន្ទាប់ពីបញ្ចប់ការសិក្សា ក៏បានត្រឡប់មកស្រុកកំណើតវិញ និងធ្វើជាគ្រូបង្រៀនផ្នែកភាសាអង់គ្លេស។

នៅខែវិច្ឆិកា ឆ្នាំ២០០៧ អៀង ធីរិទ្ធ ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ខ្លួនរួមជាមួយមេដឹកនាំជាន់ខ្ពស់៣នាក់ផ្សេងទៀតគឺ នួន ជា ខៀវ សំផន និង អៀង សារី ពីបទសង្ស័យថាបានចូលរួមប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ដែលបណ្តាលឲ្យប្រជាជនប្រមាណ២លាននាក់ស្លាប់ដោយសារការសម្លាប់ ការបង្ខំឲ្យធ្វើការងារហួសកម្លាំង និងឈឺគ្មានថ្នាំព្យាបាល។ អៀង ធីរិទ្ធ និងមេដឹកនាំជាន់ខ្ពស់



*កែវ សឿន អាយុ ៧១ឆ្នាំ គឺជាដូនជី ដែលសព្វថ្ងៃរស់នៅក្នុងវត្តលង្កាក្នុងទីក្រុងភ្នំពេញ*

៣នាក់ផ្សេងទៀតត្រូវបានតុលាការដាក់ឲ្យស្ថិតនៅក្នុងសំណុំរឿង០០២ ចំពោះឧក្រិដ្ឋរួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មនុស្សឃាត ការដាក់ឃុំឃាំង ការធ្វើទុក្ខបុកម្នេញ ការសម្លាប់បំផុតពូជ និងអំពើអមនុស្សធម៌ដទៃទៀត ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាម។ លើសពីនេះ អៀង ធីរិទ្ធ ក៏ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនាក្រោមក្រមព្រហ្មទណ្ឌកម្ពុជាក្នុងឆ្នាំ១៩៥៦។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២ តុលាការខ្មែរក្រហម បានសម្រេចឲ្យ អៀង ធីរិទ្ធ រស់នៅក្រោមទីឃុំឃាំង បន្ទាប់ពីអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានសន្និដ្ឋានថា អៀង ធីរិទ្ធ ពុំមានសម្បទាអាចចូលរួមក្នុងការជំនុំជម្រះបាន ដោយសារមានជំងឺវង្វេងស្មារតី។ អៀង ធីរិទ្ធ ស្លាប់នៅខែសីហា ឆ្នាំ២០១៥ មុនពេលដែលតុលាការសម្រេចថា តើខ្លួនមានទោសកម្រិតណា ចំពោះឧក្រិដ្ឋកម្មបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។

តើពុទ្ធសាសនិកា ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម យល់ឃើញដូចម្តេចចំពោះការស្លាប់របស់ អៀង ធីរិទ្ធ ដែលមិនទាន់បានកាត់ទោសកម្រិតណានោះ?

កែវ សឿន គឺជាដូនជីម្នាក់បានបួសរៀននៅក្នុងវត្តលង្កា ស្ថិតក្នុងទីក្រុងភ្នំពេញ អស់រយៈពេល ១១ឆ្នាំមកហើយ។ សឿន មានអាយុ៧១ឆ្នាំ មានបងប្អូន៥នាក់ ហើយមានស្រុកកំណើតនៅឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ សឿន បានរៀបការនៅក្នុងសម័យសង្គមរាស្ត្រនិយម និងមានកូនស្រី២នាក់។ សឿន រីករាយចំពោះការចូលរួមចែករំលែកពីការយល់ឃើញរបស់គាត់ទៅលើការដោះលែង អៀង ធីរិទ្ធ ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន បន្ទាប់ពីតុលាការខ្មែរក្រហម រកឃើញថា អៀង ធីរិទ្ធ មានជំងឺវង្វេងស្មារតី ហើយថែមទាំងបានរៀបរាប់ពីបទពិសោធន៍ជីវិតរបស់គាត់ក្នុងសម័យខ្មែរក្រហមដូចខាងក្រោម ៖

ខ្ញុំបានសម្រេចចិត្តបួសជាដូនជីដោយមិនស្ទាក់ស្ទើរក្នុងចិត្តឡើយ ព្រោះជីវិតក្នុងសង្គ្រាមបានធ្វើឲ្យខ្ញុំនឿយហត់ ទាំងរូបកាយ និងចិត្តយ៉ាងផ្អែតផ្អន់។ ក្នុងនាមខ្ញុំជាជនរងគ្រោះម្នាក់ ខ្ញុំជឿជាក់ និងយល់ស្របតាមការសម្រេចចិត្តរបស់តុលាការខ្មែរក្រហមទៅលើករណីកាត់ទោសរបស់ អៀង ធីរិទ្ធ។ ខ្ញុំមិនខឹងនឹងនរណាម្នាក់ទេ ព្រោះជីវិតដែលនៅសេសសល់របស់ខ្ញុំ គឺសម្រាប់តែការរស់នៅជាមួយសាសនា និងស្វែងរកភាពស្ងប់ក្នុងចិត្តតែប៉ុណ្ណោះ។ មនុស្សគ្រប់រូបតែងតែខឹងចំពោះបុគ្គលដែលធ្វើបាបខ្លួន តែដោយសារការខឹងស្អប់គ្នានេះ បានធ្វើឲ្យយើងកាន់តែមានគំនុំ និងនឿយហត់ ដូច្នេះទើបខ្ញុំសម្រេចចិត្តជ្រើសរើសផ្លូវធម៌ ដោយខិតខំរក្សាចិត្តរបស់ខ្ញុំឲ្យស្ងប់ និងមិនចង់បានអ្វីទៀតឡើយ។ ភាពលំបាកដែលខ្ញុំបានឆ្លងកាត់កន្លងមក បានធ្វើឲ្យខ្ញុំឈប់ខឹង និងស្អប់នរណាទៀតហើយ ព្រោះខ្ញុំជឿថា មនុស្សគ្រប់រូបបានកើតមកហើយរមែងតែងតែមានទុក្ខ។ ខ្ញុំគិតថា អៀង ធីរិទ្ធ បានទទួលកម្មពៀរ ដែលគាត់បានប្រព្រឹត្តពីអតីតកាលគ្រប់គ្រាន់ហើយ។ ខ្ញុំមិនចង់ចងកម្មជាមួយបុគ្គលណាទៀតឡើយ ហើយរឿងតែម្យ៉ាងគត់ដែលខ្ញុំប្រាថ្នាទៅថ្ងៃមុខ គឺខ្ញុំមិនចង់កើតមកជាមនុស្សដូចជាតិនេះទៀតទេ។

ខ្ញុំពិតជាមានសំណាងណាស់ ដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ ទោះបីជាខ្មែរក្រហមបានយកខ្ញុំទៅរៀនសូត្រជាច្រើនដង តែទន្ទឹមនឹងនោះ ខ្ញុំក៏ជាមនុស្សម្នាក់ដែលមានជីវិតកម្សត់ណាស់ ព្រោះប្តីនិងបងស្រីរបស់ខ្ញុំបានស្លាប់ចោលខ្ញុំនៅពេលសង្គ្រាមដណ្តើមអំណាចបានកើតឡើងក្នុងឆ្នាំ១៩៧២។ នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៤ មានការប្រយុទ្ធគ្នាខ្លាំងរវាងទាហានវៀតណាម ទាហាន លន់ នល់ និងកងទ័ពខ្មែរក្រហម នៅក្នុងឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្តីនិងប្អូនរបស់ខ្ញុំស្លាប់ដោយសារការទម្លាក់គ្រាប់បែកនៅពេលនោះ។ នៅក្នុងឆ្នាំ១៩៧៣ ខ្ញុំនិងសមាជិកគ្រួសារទាំងអស់បានសម្រេចចិត្តចាកចេញពីស្រុកកំណើតមករស់នៅស្រុកកៀនស្វាយ ខេត្តកណ្តាល ជាបណ្តោះអាសន្ន ដើម្បីជៀសផុតពីការរត់គេចពីគ្រាប់ផ្លោង។ ជីវិតរស់នៅស្រុក

កៀនស្វាយ មានលក្ខណៈប្រសើរជាងនៅស្រុកកំណើតរបស់ខ្ញុំ ព្រោះយើងមិនបានឮស្គរគ្រាប់កាំភ្លើង និងរស់នៅដោយភិតភ័យជារៀងរាល់ថ្ងៃទៀតទេ។ សមាជិកគ្រួសាររបស់ខ្ញុំប្រកបមុខរបរលក់ដូរនៅក្នុងផ្សារមួយក្នុងស្រុកកៀនស្វាយ។ ចំណែកឯខ្ញុំបានជួយការងារម្ដាយឪពុកខ្លះ ហើយរៀនត្បាញក្រមា និងសំពត់បន្ថែមទៀត។ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ខ្ញុំនិងសមាជិកគ្រួសារទាំងអស់បានត្រឡប់ទៅស្រុកកំណើតវិញ ព្រោះគិតថាប្រទេសជាតិបានបញ្ចប់សង្គ្រាមហើយ។ ប៉ុន្តែផ្ទុយពីការយល់ឃើញរបស់ខ្ញុំពេលមកដល់ស្រុកកំណើត អ្វីៗបានផ្លាស់ប្ដូរខុសពីមុនទាំងអស់។ ផ្ទះសម្បែងរបស់ប្រជាជន ត្រូវបានសែងតម្រៀបជិតៗគ្នា មានការប្រមូលប្រជាជនឲ្យរស់នៅរួមគ្នា ធ្វើការងាររួមគ្នា ហូបអាហារក៏រួមគ្នា ហើយបែងចែកមនុស្សជាក្រុមៗ។ ក្មេងៗ ត្រូវអង្គការចាត់តាំងឲ្យនៅក្នុងកងកុមារ ធ្វើការងារស្រាលជាងមនុស្សធំ ចំណែកឯយុវជនបានចាត់តាំងឲ្យធ្វើការក្នុងកងចល័តដែលមានការងារ ដូចជា ធ្វើស្រែ លើកទំនប់ ជីកប្រឡាយ និងការងារផ្សេងៗជាច្រើនទៀតដែលតម្រូវដោយអង្គការ។ ចំណែកខ្ញុំ ត្រូវអង្គការចាត់ឲ្យចូលធ្វើការក្នុងកងចល័ត ដែលដំបូងធ្វើការងារដូចជាធ្វើជី រែកដីបាតស្រះ និងធ្វើស្រែចម្ការ តែខ្ញុំធ្វើមិនដែលបានតាមការកំណត់របស់អង្គការទេ។ ក្រៅពីការងារនេះ ខ្ញុំជាអ្នកត្បាញក្រមាឲ្យក្រុមកងចល័តដែរ។ ក្រមាទាំងអស់ ធ្វើពីកប្បាសដោយដំបូងយកទៅរវៃជាសសៃ ហើយយកមកជ្រលក់ពណ៌រួចក៏យកទៅត្បាញ។ ក្រមាសម្រាប់ក្រុមកងចល័តមានពណ៌ខ្មៅលាយស ហើយមានតែថ្នាក់គ្រប់គ្រងទេ ដែលប្រើប្រាស់ក្រមាពណ៌សលាយពណ៌ក្រហម។ ជារឿយៗប្រធានរបស់ខ្ញុំ បានចោទថាខ្ញុំជាមនុស្សខ្ជិលធ្វើការ ហើយក៏បានហៅខ្ញុំទៅកសាងដោយធ្វើការស្ដីបន្ទោសខ្ញុំយ៉ាងខ្លាំង។ នៅពេលនោះ ខ្មែរក្រហមឲ្យខ្ញុំសរសេរប្រវត្តិរូបខ្លួនឯង និងគ្រួសារ ហើយមានថ្ងៃមួយ គេចង់យកខ្ញុំទៅសម្លាប់ តែសំណាងល្អមានយុវជនម្នាក់ឈ្មោះ នី បានជួយខ្ញុំ។ ក្រោយមក នី បានហៅខ្ញុំមកធ្វើការនៅក្នុងមន្ទីរឃុំចាម ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ភីម។ ខ្ញុំធ្វើជាអ្នកដាំបាយ និងដេរខោអាវឲ្យកងទ័ព ដែលក្នុង១ថ្ងៃ ខ្ញុំត្រូវដេរខោឲ្យបាន៣០ខោ។ ប្រជាជនស្លាប់ច្រើនណាស់នៅកន្លែងដែលខ្ញុំរស់នៅ ដែលអ្នកខ្លះស្លាប់ដោយសារតែការសម្លាប់ អ្នកខ្លះអត់អាហារ ហើយខ្លះទៀតឈឺដោយមិនមានថ្នាំពេទ្យព្យាបាល។

បន្ទាប់មក ខ្ញុំបានរត់ទៅជាមួយកងទ័ពខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៩ ដោយហែលឆ្លងកាត់ទន្លេអ្នកលឿង នៅពេលដែលកងទ័ពវៀតណាមវាយចូលមកទីកន្លែងដែលខ្ញុំរស់នៅ។ ប្រជាជន កងទ័ពនិងក្មេងជាច្រើនបានស្លាប់ដោយសារលង់ទឹក និងត្រូវគ្រាប់កាំភ្លើង។ ចំណែកខ្ញុំបានហែលឆ្លងទន្លេ រីឯកូនខ្ញុំវិញ ជិះលើដើមចេកឆ្លងទន្លេដោយបានកងទ័ពខ្មែរក្រហមជួយចម្លង។ បន្ទាប់ពីឆ្លងផុតទន្លេ ខ្ញុំ និងកូននាំគ្នារត់ចូលទៅក្នុងព្រៃ ទៅតាមភ្នំតាម៉ៅ ភ្នំតាឪ និងភ្នំស្រង់។ ខ្ញុំឃើញមានមនុស្សស្លាប់ច្រើនណាស់នៅក្នុងព្រៃ ដែលអ្នកខ្លះស្លាប់ដោយសារការអត់អាហារ និងជំងឺ។ នៅក្នុងព្រៃមិនយូរប៉ុន្មាន ប្រជាជនចេះតែនិយាយតៗគ្នាថា កងទ័ពវៀតណាមមិនបានមកធ្វើបាបប្រជាជនទេ ហើយខ្ញុំក៏បានស្ដាប់វិទ្យុឮស្គរសំឡេងច្រៀងសប្បាយ ទើបខ្ញុំសម្រេចចិត្តត្រឡប់មកស្រុកកំណើតវិញ។

យន់ យឿន អាយុ៧៥ឆ្នាំ ជាពុទ្ធសាសនិកាម្នាក់ ដែលមានស្រុកកំណើតនៅឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ យឿន មានបងប្អូន៧នាក់ ស្រី២នាក់និងប្រុស៣នាក់។ គាត់រៀបការក្នុងសម័យសង្គមរាស្ត្រនិយម និងមានកូន៩នាក់ ស្រី៤នាក់និងប្រុស៥នាក់ ហើយប្ដីរបស់គាត់បានស្លាប់ដោយសារជំងឺអស់រយៈពេលប្រហែល៣ឆ្នាំកន្លងមកហើយ។ សព្វថ្ងៃ យឿន រស់នៅជាមួយកូនស្រី និងចៅស្រីរបស់គាត់ ដោយប្រកបមុខរបរធ្វើស្រែចម្ការ។ ក្រៅពីធ្វើស្រែចម្ការចិញ្ចឹមជីវិត យឿន បានចូលរួមជាមួយព្រះពុទ្ធសាសនាយ៉ាងសកម្ម ព្រោះគាត់គិតថាសាសនា ជាអ្នកទូន្មានមនុស្សឲ្យប្រព្រឹត្តតែអំពើល្អ និងជួយមនុស្សនៅជាតិមុខទៀត។ យឿន

បានព្យាយាមរំឭកពីអតីតកាលរបស់គាត់ និងចែករំលែកការយល់ឃើញទៅលើការទទួលខុសត្រូវរបស់មេដឹកនាំខ្មែរក្រហមដូចខាងក្រោម៖

ខ្ញុំពិតជានឹករឭកដល់សាច់ញាតិរបស់ខ្ញុំណាស់ ពេលដែលខ្ញុំនិយាយរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហមម្តងៗ។ សព្វថ្ងៃនេះ ខ្ញុំមានការភ្លេចភ្លាំងច្រើនណាស់ សូម្បីតែខ្ញុំមានអាយុប៉ុន្មាន ខ្ញុំមានបងប្អូនប៉ុន្មាននាក់ ក៏ខ្ញុំមិនសូវចាំដែរ ប្រសិនបើគ្មានអ្នកជួយរំឭក តែខ្ញុំអាចចងចាំបានពីអ្នកដែលធ្លាប់ធ្វើបាបខ្ញុំនិងសាច់ញាតិរបស់ខ្ញុំ។ ខ្ញុំមិនធ្លាប់បានឃើញមុខ ឬស្គាល់មេដឹកនាំខ្មែរក្រហមណាម្នាក់ទេ តែមេដឹកនាំទាំងអស់ មិនថាស្លាប់ឬរស់គួរតែមានឈ្មោះជាឧក្រិដ្ឋជននៅក្នុងប្រវត្តិសាស្ត្រសម្រាប់ឲ្យក្មេងៗជំនាន់ក្រោយបានដឹង។ ទោះបីជា អៀង ធីរិទ្ធ មិនបានមកធ្វើបាបខ្ញុំ និងសាច់ញាតិរបស់ខ្ញុំផ្ទាល់ តែការគ្រប់គ្រងរបស់គាត់បានធ្វើឲ្យប៉ះពាល់មកលើគ្រួសារខ្ញុំ និងប្រជាជនដ៏ទៃទៀតខ្លាំងណាស់។បើ អៀង ធីរិទ្ធ មិនបានកាត់ទោសក្នុងតុលាការ គាត់គួរតែមានឈ្មោះថាជាមេដឹកនាំអាក្រក់ម្នាក់ក្នុងរបបខ្មែរក្រហម។ ពីមុនខ្ញុំខឹងណាស់ចំពោះអ្នកដឹកនាំសម័យនោះ ប៉ុន្តែឥឡូវខ្ញុំរសាយចិត្តខ្លះហើយ ព្រោះខ្ញុំជឿតាមធម៌ព្រះពុទ្ធសាសនាថា «ពៀររំងាប់ដោយការមិនចងពៀរ»។

ខ្ញុំ មិនសូវមានបទពិសោធន៍អ្វីច្រើនខុសប្លែកពីប្រជាជនដ៏ទៃទៀត ដែលបានឆ្លងកាត់ក្នុងសម័យខ្មែរក្រហមទេ តែអ្វីដែលខ្ញុំបានឆ្លងកាត់ប្លែកពីប្រជាជនមួយចំនួនទៀត គឺខ្ញុំមានផ្ទៃពោះ និងបានបង្កើតកូនប្រុសម្នាក់នៅពេលនោះ។ ខ្ញុំដឹកតែឫសឈើផ្សំគ្នា សម្រាប់ធ្វើជាថ្នាំថែរក្សាកូនក្នុងផ្ទៃពោះតែប៉ុណ្ណោះ ហើយនៅតែបន្តធ្វើការងារគ្រប់យ៉ាង ដែលអង្គការបញ្ជា។ ក្នុងពេលនោះ ខ្ញុំមានសុខភាពល្អណាស់ ទោះបីជាធ្វើការងារធ្ងន់យ៉ាងណា ក៏ខ្ញុំមិនដែលឈឺដែរ។ ខ្ញុំដឹងថាការផ្តល់កំណើត គឺជារឿងមួយ ដែលលំបាកបំផុតសម្រាប់ស្ត្រី ហើយចំពោះបទពិសោធន៍ខ្ញុំវិញ ការពពោះនិងបង្កើតកូន៣នាក់ដំបូងរបស់ខ្ញុំមុនសម័យខ្មែរក្រហម ពិតជាពិបាកណាស់ តែបើប្រៀបធៀបទៅនឹងការពពោះ និងបង្កើតកូនក្នុងសម័យខ្មែរក្រហមវិញ គឺពិបាកលើសពីមុន១០ទៅ២០ដងឯណោះ។ ខ្ញុំចាំបានថា ឆ្មបម្នាក់ឈ្មោះ យាយ នន បានបង្កើតកូនឲ្យខ្ញុំនៅក្នុងខ្ទមដោយប្រើតែកន្ទ្រៃមួយតែប៉ុណ្ណោះ។ ខ្ញុំគិតថា យាយ នន មិនបានរៀនវិជ្ជាឆ្មបជ្រៅជ្រះទេ គឺគាត់គ្រាន់តែចេះបង្កើតកូនតៗគ្នាប៉ុណ្ណោះ។ ប៉ុន្តែទោះបីជាយ៉ាងណា យាយ នន បានបង្កើតកូនឲ្យប្រជាជនក្នុងភូមិ ដែលខ្ញុំរស់នៅក្នុងសម័យខ្មែរក្រហម មិនដែលជួបប្រទះនឹងគ្រោះថ្នាក់អ្វីទេ។ បន្ទាប់ពីសម្រាលកូនរួច ខ្ញុំបានឆ្អើរភ្លើងប្រហែល១សប្តាហ៍តាមចាស់ៗពីបុរាណណែនាំ ដែលក្នុងពេលនោះប្តីរបស់ខ្ញុំបានឆ្លៀតមកជួបមួយភ្លែតៗ។ ខ្ញុំមិនបានផឹកថ្នាំពេទ្យអ្វីទេ ហើយខ្ញុំក៏មិនដែលឮថាមានថ្នាំពេទ្យសម្រាប់ស្ត្រីមានផ្ទៃពោះដែរ។

ក្រុមគ្រួសាររបស់ខ្ញុំ សុទ្ធតែស្លាប់ដោយសារជំងឺ ដែលខ្វះថ្នាំព្យាបាល។ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺ នៅក្នុងថ្ងៃដែលទាហានវៀតណាមចូលមករំដោះ ចំណែកឯកូនខ្ញុំវិញ ដែលមានអាយុត្រឹមតែ៥ឆ្នាំប៉ុណ្ណោះ បានស្លាប់មុនឪពុកខ្ញុំប្រហែលជា៣ថ្ងៃ ដោយសារកើតជំងឺខាន់ស្លាក់។ ក្រៅពីនោះ បងប្អូនបង្កើត២នាក់ទៀតរបស់ខ្ញុំក៏បានស្លាប់ដោយសារតែឈឺក្នុងកំឡុងសម័យខ្មែរក្រហមដែរ។

យុត្តិធម៌ គឺជាការផ្សះផ្សាមួយយ៉ាងសំខាន់ សម្រាប់ជនរងគ្រោះនៅក្នុងប្រទេសក្រោយជម្លោះដូចជាប្រទេសកម្ពុជា។ តម្រូវការនៃភាពយុត្តិធម៌នៅតែមានសម្រាប់ជនរងគ្រោះនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ព្រោះមេដឹកនាំខ្មែរក្រហមមួយចំនួន មិនទាន់បានទទួលការកាត់ទោសទៅតាមច្បាប់ដូចជា អៀង ធីរិទ្ធ ជាដើម។ បន្ទាប់ពី អៀង ធីរិទ្ធ បានស្លាប់ដោយខកខានមិនបានចូលរួមក្នុងដំណើរការរបស់តុលាការ ពុទ្ធសាសនិកា ហាក់បីដូចជាយល់ឃើញថាវាគ្រប់គ្រាន់ ចំពោះអ្វីដែលគាត់បានប្រព្រឹត្ត តែទន្ទឹមនឹងនេះក៏នៅមានពុទ្ធសាសនិកាផ្សេងទៀតគិតថា អៀង ធីរិទ្ធ គួរតែទទួលបានឈ្មោះជាឧក្រិដ្ឋជន ទោះបីជាគាត់បានស្លាប់មុនការកាត់ទោសរបស់តុលាការយ៉ាងណាក៏ដោយ។

**អ៊ិន សុដាវី**

# រឿងរ៉ាវអតីតកាល ដែលមិនអាចបំភ្លេច

ប្រជាជននៅក្នុងប្រទេសកម្ពុជា ដែលនៅរស់រានមានជីវិត មិនចង់រំឭកនិងចងចាំពីអតីតកាលដ៏ឈឺចាប់របស់ខ្លួន ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមទេ។ របបខ្មែរក្រហមបានធ្វើឲ្យប្រជាជន មិនទុកចិត្តគ្នា បាក់ស្បាត និងខ្លាចរអាយ៉ាងខ្លាំង ជាពិសេសចំពោះអ្នក ដែលបានបាត់បង់ក្រុមគ្រួសារ សាច់ញាតិ និងបានឆ្លងកាត់ពេលវេលាដ៏លំបាក ហើយបញ្ហាទាំងនេះ កំពុងតែបន្តជះឥទ្ធិពលទៅដល់ជីវិតរស់នៅបច្ចុប្បន្នរបស់ជនរងគ្រោះ។

សុត សុខេម ហៅ ឡាច ជាស្ត្រីម្នាក់បានទទួលបទ-ពិសោធន៍ជីវិតជាច្រើនក្នុងរបបខ្មែរក្រហម និងជាស្ត្រីម្នាក់បានខិតខំព្យាយាមបំភ្លេចរឿងរ៉ាវអតីតកាល ដែលបានកើតឡើងចំពោះគាត់និងក្រុមគ្រួសាររបស់គាត់ក្នុងរបបខ្មែរក្រហម។ តែទោះបីជាយ៉ាងណាក៏ដោយ ឡាច មិនអាចបំភ្លេចអតីតកាលទាំងអស់បានឡើយ ព្រោះទំហំនៃការបាត់បង់ និងការឈឺចាប់ ដែលគាត់បានជួបប្រទះ នៅតែជាស្រមោលជាប់ជាមួយខ្លួនគាត់ជានិច្ច។

នៅចុងឆ្នាំ១៩៧៨ ស្វាមីរបស់ ឡាច ឈ្មោះ សុខ សួគ៌ហេង ជាគ្រូបង្រៀន ហើយក៏ជាអ្នកសរសេរបទចម្រៀង «ទំនួញករវិទល់ដែន» ដែលច្រៀងដោយលោក អ៊ិន យ៉េង បានចងកសម្លាប់ខ្លួន ក្រោយពេលដឹងថាខ្មែរក្រហមមានបំណងសម្លាប់គាត់។ ចំណែកឯកូនស្រីទី៣របស់ ឡាច ដែលមានអាយុ១០ឆ្នាំ បានឈឺស្លាប់ដោយសារជំងឺ។ ក្រោយពីនោះ ឡាច ក៏បានរំឭកពីពេលវេលាដ៏លំបាកបំផុតក្នុងកំឡុងពេលផ្តល់កំណើតដល់កូនប្រុសម្នាក់របស់គាត់ក្នុងរបបខ្មែរក្រហម។ ទាំងអស់នេះគឺជាឥទ្ធិពលមួយ បានជំរុញឲ្យ ឡាច ចាប់ផ្តើមគិត និងចងចាំពីភាពមិនអាចលើកលែងទោសដល់មេដឹកនាំក្នុងរបបខ្មែរក្រហមណាម្នាក់បានឡើយ។

សព្វថ្ងៃ ឡាច មានអាយុ ៦៦ឆ្នាំ ជាអ្នកកាន់ព្រះពុទ្ធ


សុត សុខេម ហៅ ឡាច ក្នុងឃុំសន្លុង ស្រុកត្រាំង ខេត្តតាកែវ

សាសនា រស់នៅក្នុងភូមិក្រាំងត្នោត ឃុំសន្លុង ស្រុកត្រាំង ខេត្តតាកែវ។ ឡាច មានកូន៤នាក់ ស្រី២នាក់ និងប្រុស២នាក់។ សព្វថ្ងៃ ឡាច រស់នៅជាមួយកូនស្រីច្បង កូនប្រសា និងចៅ៣នាក់ ដោយប្រកបមុខរបបធ្វើស្រែចម្ការ និងលក់ទឹកអំពៅក្នុងសាលារៀនមួយនៅជិតផ្ទះរបស់គាត់។

ឡាច បានរៀបការក្នុងសម័យសង្គមរាស្ត្រនិយម ហើយមានកូន ៣នាក់ មុនពេលដែលខ្មែរក្រហមទទួលបានអំណាចគ្រប់គ្រងប្រទេសនៅក្នុងឆ្នាំ១៩៧៥។ ដោយសារតែប្ដីមានមុខរបរជាគ្រូបង្រៀន ទើប ឡាច ត្រូវចាកចេញពីស្រុកកំណើតទៅរស់នៅជាមួយប្ដី។ ដំបូង ឡាច បានចាកចេញពីស្រុកកំណើតទៅរស់នៅស្រុកកំពង់ត្រាច ខេត្តកំពត ដែលជាស្រុកមួយមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ហើយក៏ជាកន្លែងមួយ ដែលប្ដីរបស់គាត់បានសរសេរបទចម្រៀង «ទំនួយករទឹលដែន»ឡើង។ ក្រោយមក ឡាច និងក្រុមគ្រួសារបានផ្លាស់ទៅរស់នៅក្នុងខេត្តកំពត។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានទទួលជ័យជម្នះ និងចូលមកកាន់កាប់គ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ឡាច ប្ដីនិងកូន៣នាក់ ត្រូវខ្មែរក្រហមជម្លៀសចេញពីទីរួមខេត្តកំពត មករស់នៅនិងធ្វើការនៅក្នុងឃុំដំបូកខ្ពស់ ស្រុកឈូក ខេត្តកំពត។ មកដល់ឃុំដំបូកខ្ពស់ដំបូង ឡាច ត្រូវអង្គការចាត់តាំងឲ្យធ្វើការងារដូចជា ដកស្ទូង និងលើកទំនប់។ ចំណែកឯប្ដី ត្រូវអង្គការចាត់តាំងឲ្យទៅភ្ជួរស្រែ និងដឹកខស រីឯកូន៣នាក់ តម្រូវឲ្យទៅធ្វើការងារក្នុងកងកុមារនិងរៀនសូត្រជាមួយកុមារដទៃទៀត។ ឡាច បញ្ជាក់ថា គ្មានថ្ងៃណាដែលគ្រួសារបានជួបជុំគ្នាដោយរីករាយដូចពីមុនទេ គឺសមាជិកគ្រួសារទាំងអស់អាចជួបជុំគ្នាតែពេលយប់បន្ទាប់ពីត្រឡប់មកពីធ្វើការវិញតែប៉ុណ្ណោះ។ ពីមួយថ្ងៃទៅមួយថ្ងៃ ការងារកាន់តែលំបាកទៅៗ ចំណែករបបអាហារដែលទទួលបានជាប្រចាំថ្ងៃបានកាត់បន្ថយបន្តិចម្ដងៗ។

នៅចុងឆ្នាំ១៩៧៧ ឡាច បានផ្តល់កំណើតដល់កូនប្រុសពៅរបស់គាត់ឈ្មោះ សុខ ហន។ ឡាច ប្រាប់ថា ក្នុងកំឡុងពេលមានផ្ទៃពោះ ស្ត្រីក្នុងរបបខ្មែរក្រហមទាំងអស់ នៅតែបន្តធ្វើការងារជាធម្មតាដូចពីមុនរហូតដល់ថ្ងៃសម្រាលកូន។ ឡាច បានបញ្ជាក់បន្ថែមថា ក្រៅពីខ្មែរក្រហមបង្ខំឲ្យធ្វើការងារធ្ងន់ក្នុងពេលមានផ្ទៃពោះ គាត់និងស្ត្រីដទៃទៀតមិនធ្លាប់ទទួលបានថ្នាំរក្សាកូនឬការត្រួតពិនិត្យសុខភាពម្ដាយ និងទារកជាប្រចាំខែឬប្រចាំត្រីមាសនោះទេ។ ឡាច បានយកប្រភេទរុក្ខជាតិម្យ៉ាងឈ្មោះ «ដើមបន្ទាបន្ទ្រាប» ជាប្រភេទរុក្ខជាតិដុះទាបស្មើដី ដើមវាមានបន្លា និងមានផ្កាតូចៗពណ៌ឈូកខ្ចី ហើយភាគច្រើនដុះនៅជុំវិញផ្ទះ សម្រាប់ធ្វើជាឪសថដាំទឹកហូបក្នុងកំឡុងពេលមានផ្ទៃពោះ។ ឡាច ប្រាប់ថាបន្លាប្រភេទនេះត្រូវបានចាស់ៗពីបុរាណជឿថាជាឪសថបុរាណម្យ៉ាងអាចព្យាបាលជំងឺបាន១០០មុខ។

ទោះបីជាយ៉ាងណា ឡាច បានបង្កើតកូនប្រុសរបស់គាត់ដោយសុវត្ថិភាព។ ឡាច បានចែករំលែកពីបទពិសោធន៍របស់គាត់ដោយមិនស្ទាក់ស្ទើរក្នុងពេលសម្រាលកូនថា កូនរបស់គាត់កើតមកបានដោយសុវត្ថិភាពដោយសារតែកន្ត្រៃដ៏ចាស់មួយ ដែលមានមុខសុទ្ធតែច្រែសសម្រាប់កាត់ទងផ្ចិតតែប៉ុណ្ណោះ។ គ្មានថ្នាំសង្កូវ គ្មានក្រណាត់ គ្មានសម្លៀកបំពាក់ និងគ្មានសម្ភារៈអ្វីទាល់តែសោះក្នុងពេលដែលគាត់សម្រាលកូន។ ចំពោះ ឡាច ជាម្ដាយ មានតែភួយមួយធ្វើពីក្រចៅ ដែលធ្ងន់ស្ទើរតែលើកមិនរួចសម្រាប់គ្របដណ្ដប់ខ្លួន។ បន្ទាប់ពីសម្រាលកូន ឡាច បានប្រើប្រាស់តែឪសថបុរាណដែលផ្សំពីឫសឈើច្រើនប្រភេទសម្រាប់ដាំទឹកដឹក។ ក្រៅពីនោះ ឡាច បានអាំងភ្លើងស្អើរខ្លួនតាមទម្លាប់ចាស់ពីបុរាណដែលតែងតែធ្វើតាំងពីបុរាណកាល។ ទោះបីជាជួបប្រទះបញ្ហាច្រើនយ៉ាងណា ឡាច នៅតែអាចឆ្លងកាត់ភាពលំបាកទាំងអស់បាន ហើយបង្កើតបានកូនប្រុសម្នាក់ ដែលនៅរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។

ឡាច និយាយទាំងអួលដើមករថា នៅថ្ងៃដែលកូនរបស់គាត់មានអាយុគម្រប់១ខែ ជាថ្ងៃមួយដែលប្ដីរបស់គាត់បានចាកចេញទៅដោយគ្មានថ្ងៃវិលត្រឡប់។ ឡាច បានប្រាប់ថា

ថ្ងៃមួយ នៅពេលដែលគាត់កំពុងតែបំបៅដោះកូន ម៉ោងប្រហែល៥រសៀល មានកងឈ្លបខ្មែរក្រហមមួយក្រុមស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ បានចូលមកខាងក្នុងផ្ទះរបស់គាត់ ហើយប្រាប់ប្តីគាត់ ឲ្យទៅចូលរួមប្រជុំនៅរសៀលថ្ងៃបន្ទាប់ជាមួយបុរស៥នាក់ផ្សេងទៀតនៅក្នុងភូមិ។ បន្ទាប់ពីកងឈ្លបចាកចេញផុតពីផ្ទះ ប្តី របស់ឡាច បានប្រាប់ ឡាច ថា គាត់មិនទៅចូលរួមប្រជុំទេ ព្រោះវាជាផែនការសម្លាប់របស់ខ្មែរក្រហម ហើយម្យ៉ាងទៀត ប្តីរបស់ ឡាច មិនចង់ឲ្យក្មេងតូចៗវាយសម្លាប់គាត់ដែរ។ ព្រឹកថ្ងៃបន្ទាប់ ប្តី របស់ឡាច បានទៅជួបឪពុកម្តាយ និងសាច់ញាតិ ដែលរស់នៅក្នុងភូមិជាមួយគ្នា ហើយប្រាប់ពីដំណឹងដែលគាត់ទទួលបានពីកងឈ្លប និងផែនការដែលគាត់មិនទៅចូលរួមប្រជុំជាមួយបុរស៥នាក់ទៀត បន្ទាប់មកក៏បានចាកចេញទៅ។ ឡាច ស្មានថាប្តីរបស់គាត់ សម្រេចចិត្តទៅចូលរួមប្រជុំតាមការកោះហៅរបស់អង្គការ តែបីថ្ងៃក្រោយមក គាត់ទទួលដំណឹងថាប្តីរបស់គាត់បានចងករសម្លាប់ខ្លួន។ ឡាច និយាយថា នៅពេលដែលប្តីរបស់គាត់ខកខានមិនបានទៅចូលរួមប្រជុំ កងឈ្លបបានមករកប្តីរបស់គាត់ដល់ផ្ទះតែមិនជួប ក៏ចាប់ផ្តើមដើរស្វែងរកនៅកន្លែងផ្សេងៗនៅក្នុងភូមិ។ បីថ្ងៃក្រោយមក កងឈ្លបទាំងនោះបានប្រទះឃើញសាកសពប្តីរបស់គាត់ ដែលបានចងកសម្លាប់ខ្លួននៅលើដើមឈើមួយ ហើយក្រុមឈ្លបបានយកសាកសពប្តីរបស់ ឡាច ទៅកប់ក្នុងភូមិដែលគាត់រស់នៅ។

ឡាច ចាប់ផ្តើមមានអារម្មណ៍អស់សង្ឃឹមនៅពេលដែលដឹងថាប្តីបានស្លាប់បាត់បង់ជីវិត។ ប៉ុន្តែដោយសារកូនទាំង៤នាក់របស់គាត់ បានធ្វើឲ្យគាត់មានកម្លាំងចិត្តតស៊ូរស់ឡើងវិញ។ ឡាច ត្រូវបានប្រធានភូមិ ចាត់ឲ្យមើលថែរក្សាក្មេងៗមួយក្រុមចំនួន៥នាក់ ព្រោះប្រធានភូមិគិតថា ឡាច ទើបតែសម្រាលកូនរួចៗ មិនយូរប៉ុន្មាន ឡាច ត្រូវចាត់តាំងឲ្យចូលធ្វើការជាមួយក្រុមកងនារីមេម៉ាយមានគ្នាប្រហែល១០០នាក់ ដើម្បីលើកទំនប់ម្ចិច ដែលស្ថិតក្នុងស្រុកជុំគិរី ខេត្តកំពត។ និយាយដល់ចំណុចនេះ ឡាច បានប្រែទឹកមុខក្រៀមក្រំ តែគាត់នៅតែបន្តរៀបរាប់ទៀតថា ទំនប់ម្ចិច ជាទីលានទុក្ខសោកដែលមានមនុស្សជាច្រើនបានស្លាប់ ដោយសារការបង្ខំឲ្យធ្វើការផ្សារហួសកម្លាំង។ ខ្មែរក្រហមមានគោលដៅសាងសង់ទំនប់នេះ ជាកន្លែងស្តុកទឹកប្រើប្រាស់និងសម្រាប់ធ្វើស្រែចម្ការ។

ក្នុងឆ្នាំ១៩៧៩ កងទ័ពវៀតណាម បានចូលមកដល់ទីកន្លែងដែល ឡាច កំពុងរស់នៅ។ ឡាច និងប្រជាជនជាច្រើនត្រូវខ្មែរក្រហមបង្ខំឲ្យរត់សំដៅទៅភ្នំលះបង់ដែលស្ថិតនៅក្នុងស្រុកជុំគិរី ខេត្តកំពត។ ឡាច និងសាច់ញាតិ បានធ្វើដំណើរតាមរទេះគោសំដៅទៅកាន់ភ្នំលះបង់ តែគាត់ធ្វើដំណើរបានត្រឹមតែពាក់កណ្តាលផ្លូវក៏ត្រឡប់មកក្រោយវិញ ព្រោះគាត់និងប្រជាជនមួយក្រុមបានដឹងថា កងទ័ពវៀតណាមមិនបានធ្វើបាបប្រជាជនដូចខ្មែរក្រហមឃោសនាឡើយ ព្រោះគាត់បានជួបជាមួយកងទ័ពវៀតណាមនៅតាមផ្លូវ។ ឡាច និងសាច់ញាតិ បានត្រឡប់មករស់នៅស្រុកកំណើតវិញតាំងពីពេលនោះមក។

ដោយសារតែប្រពៃណី ឡាច សម្រេចចិត្តមិនរៀបការទៀតទេ ហើយព្យាយាមដើរតួរនាទីជាម្តាយ និងឪពុក ដើម្បីមើលថែរក្សាកូនទាំង៣ ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម។ ទោះបីជាលំបាកយ៉ាងណា ក៏គាត់បានប្តេជ្ញាចិត្តបញ្ជូនកូនឲ្យទៅសាលា រហូតដល់កូនប្រុសច្បងរបស់គាត់បានក្លាយជាអាជីវករ និងកូនប្រុសពៅបានធ្វើជាគ្រូបង្រៀនដូចប្តីរបស់គាត់។

ឡាច បានយំបន្ទាប់ពីគាត់បានផ្តល់បទសម្ភាសន៍ ដែលនេះជាសញ្ញាមួយបង្ហាញថា គាត់ពិតជាបានឆ្លងកាត់ពេលវេលាមួយដែលធ្វើឲ្យគាត់ឈឺចាប់ និងចងចាំរហូតដល់បច្ចុប្បន្ន។ រឿងរ៉ាវរបស់ ឡាច បានឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ស្ត្រីជាច្រើនទៀតនៅក្នុងរបបខ្មែរក្រហម ថាតើស្ត្រីបានប្រឈមមុខចំពោះពេលវេលាដ៏លំបាក និងបញ្ហាអ្វីខ្លះក្នុងការផ្តល់កំណើត។ **អ៊ុន សុដាវី និង អាលីសុន វ៉ែលខេស**

# ម៉ាន ម៉ុន ៖ នារីពេទ្យជំនាញផ្នែកទូទៅនៅមន្ទីរពេទ្យ ៦ មករា

ខ្ញុំ ជាកូនច្បងក្នុងគ្រួសារក្នុងចំណោមបងប្អូន៨នាក់។ ម្តាយរបស់ខ្ញុំ បានស្លាប់ចោលនៅពេលដែលខ្ញុំមានអាយុ ១៥ឆ្នាំ។ ម្តាយរបស់ខ្ញុំស្លាប់ដោយសារតែជំងឺម្យ៉ាង ដែលប្រជាជនខ្មែរភាគច្រើនហៅថាជំងឺទាស់ចំណី។ បន្ទាប់ពីសម្រាលប្អូនរបស់ខ្ញុំបានប្រហែល៣ខែ ម្តាយខ្ញុំបានបរិភោគក្បាលជ្រូកបន្ទាប់មកក៏ស្លាប់ភ្លាមៗ។ខ្ញុំធ្លាប់ឮចាស់ៗនិយាយថា ការបរិភោគក្បាលជ្រូក នៅពេលយើងមានជំងឺអាចធ្វើឲ្យយើងកាន់តែទ្រុឌទ្រោម ជាពិសេសសម្រាប់ស្ត្រី ដែលទើបតែសម្រាលកូនរួចៗ ខ្ញុំមិនបានរៀនសូត្រទាល់តែសោះ ព្រោះខ្ញុំមានតួនាទីមើលថែរក្សាប្អូនៗ បន្ទាប់ពីម្តាយរបស់ខ្ញុំបានស្លាប់ចោលទៅ ដែលពេលនោះឪពុករបស់ខ្ញុំបានដើរស៊ីឈ្នួលនៅតាមភូមិផ្សេងៗសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។

ស្ថានភាពក្នុងភូមិបានប្រែប្រួលភ្លាមៗ នៅពេលខ្មែរក្រហមទទួលបានជ័យជំនះ និងចូលមកគ្រប់គ្រងកន្លែងដែលខ្ញុំរស់នៅ។ ប្រជាជនត្រូវបានរៀបចំឲ្យរស់នៅជាក្រុម ចំណែកឯសមាជិកគ្រួសារក៏ត្រូវបានបំបែកចេញពីគ្នា។ ខ្ញុំបានបញ្ជូនប្អូនៗឲ្យទៅរស់នៅជាមួយឪពុករបស់ខ្ញុំ នៅក្នុងភូមិមួយក្បែរភូមិដែលខ្ញុំរស់នៅ ព្រោះខ្ញុំគិតថាខ្ញុំមិនអាចមើលថែរក្សាប្អូនរបស់ខ្ញុំទាំងអស់បានទៀតឡើយ បន្ទាប់ពីខ្មែរក្រហមបានចាត់តាំងឲ្យខ្ញុំទៅធ្វើការក្នុងកងចល័តមួយ ស្ថិតក្នុងភូមិស្រះធុល ឃុំដើងរស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ កំឡុងឆ្នាំ១៩៧៦។ មកដល់ទីតាំង ដែលខ្ញុំត្រូវធ្វើការដំបូង ខ្ញុំបានជួបប្រធានសហករណ៍ឈ្មោះ តាប៊ុន ដែលពេលនោះ គាត់បានឲ្យខ្ញុំធ្វើកងឈ្លបប្រចាំតំបន់នៅទីនោះ។ ការងារដែលខ្ញុំត្រូវធ្វើរាល់ថ្ងៃ គឺចាំឃ្លាំមើលប្រជាជនធ្វើការងារនៅក្នុងកងចល័ត និងដើរត្រួតពិនិត្យតាមភូមិ ហើយរាយការណ៍ជូនថ្នាក់លើប្រសិន



នារីពេទ្យក្នុងសម័យខ្មែរក្រហម

បើជួបរឿងរ៉ាវអ្វីមិនប្រក្រតី។ ខ្ញុំចាំបានថា អង្គការនឹងយកប្រជាជនទៅកសាង ឬដាក់ទណ្ឌកម្មប្រសិនបើប្រជាជនណាធ្វើខុសនឹងបញ្ជារបស់អង្គការ ឬមានគំនិតរត់គេចៗ

បន្ទាប់ពីបំពេញការងារជាកងឈ្លបអស់រយៈពេល៥ខែ តាប៊ិន បានផ្លាស់ខ្ញុំឲ្យទៅធ្វើការនៅក្នុងកងចល័តតំបន់៣២វិញ។ កងចល័តតំបន់៣២ មានទីតាំងស្ថិតនៅក្នុងស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលគ្រប់គ្រងដោយឈ្មោះ រីម។ ខ្ញុំបានប្រកែកជាមួយ តាប៊ិន ថា ខ្ញុំមិនចង់ផ្លាស់ទៅធ្វើការនៅទីនោះទេ ព្រោះឆ្ងាយពីឪពុកនឹងប្អូនៗរបស់ខ្ញុំ ដែលគ្មាននរណាជួយថែរក្សា។ ប៉ុន្តែ តាប៊ិន មិនយល់ព្រមឡើយ ហើយប្រាប់ខ្ញុំថា ប្អូនៗរបស់ខ្ញុំត្រូវរស់នៅក្រោមការមើលថែរក្សារបស់អង្គការ។ មុនពេលចាកចេញទៅធ្វើការងារនៅកន្លែងថ្មី ខ្ញុំបានទៅទៅលាឪពុក និងប្អូនៗរបស់ខ្ញុំ ព្រោះខ្ញុំដឹងមុនថាមិនងាយមានឱកាសបានជួបគ្នាទៀតទេ។

ជីវិតក្នុងកងចល័ត មានភាពខុសគ្នាទាំងស្រុងជាមួយនឹងការងារជាកងឈ្លប។ ខ្ញុំត្រូវបានអង្គការចាត់ឲ្យធ្វើការងារដូចជាប្រជាជនធម្មតាដ៏ទៃទៀត ដូចជាលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ និងចាំបង្ហូរទឹកដាក់ស្រែនៅពេលយប់។ ខ្ញុំបានធ្វើការងារចល័តពីកន្លែងមួយទៅកន្លែងមួយ ជាមួយប្រជាជនប្រហែល៣០០នាក់ទៀតនៅក្នុងខេត្តកំពង់ស្ពឺ។ បទពិសោធន៍ប្រហែលមួយឆ្នាំរបស់ខ្ញុំ ដែលធ្វើការងារក្នុងកងចល័តតំបន់៣២ បានធ្វើឲ្យខ្ញុំជួបទុក្ខលំបាក ដូចជា កង្វះខាតអាហារទន្ទឹមពេលដែលអង្គការបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ធ្ងរជាដើម។ ក្រៅពីនោះ ការងារក្នុងកងចល័តបានធ្វើឲ្យខ្ញុំបាក់ស្បាតណាស់ព្រោះអង្គការធ្លាប់បានយកខ្ញុំទៅកសាង និងគំរាមសម្លាប់ដោយចោទថា ខ្ញុំខ្ជិលធ្វើការងារ។ លើសពីនេះ ខ្ញុំធ្លាប់បានឃើញកម្មាភិបាលខ្មែរក្រហមមួយក្រុម បណ្ដើរមនុស្សប្រុស៣នាក់ចងមុខឆ្លងកាត់កន្លែងដែលខ្ញុំកំពុងធ្វើការ ក្រោមការចោទប្រកាន់ថាបុរសទាំង៣បានប្រព្រឹត្តខុសសីលធម៌។ បុរសម្នាក់ក្នុងចំណោមបុរសទាំង៣នាក់គឺជាពូរបស់ខ្ញុំ។ ខ្ញុំមិនបានឃើញខ្មែរក្រហមសម្លាប់ដោយផ្ទាល់ភ្នែកទេ តែចាប់តាំងពីថ្ងៃនោះមក ពូរបស់ខ្ញុំមិនដែលត្រឡប់មកផ្ទះវិញឡើយរហូតមកដល់សព្វថ្ងៃនេះ។

នៅក្នុងឆ្នាំ១៩៧៧ រីម បានមកប្រាប់ខ្ញុំឲ្យផ្លាស់ទៅធ្វើការងារនៅទីក្រុងភ្នំពេញភ្លាមៗតែម្ដង ដែលនៅពេលនោះមិនទាន់ដឹងថា អង្គការចាត់តាំងឲ្យធ្វើអ្វីទេ។ ខ្ញុំគិតក្នុងចិត្តថាមេកងចល័តស្អប់ខ្ញុំហើយ។ ខ្ញុំបានចាកចេញមកដល់ទីក្រុងភ្នំពេញក្នុងរយៈពេល៣ថ្ងៃបន្ទាប់។ មកដល់ភ្នំពេញដំបូងអង្គការបានបញ្ជូនខ្ញុំឲ្យចូលទៅធ្វើការនៅក្នុងមន្ទីរពេទ្យ៦មករា (មន្ទីរពេទ្យកេតុមាលា)។ រយៈពេល២ថ្ងៃដំបូង ប្រធានពេទ្យបានបញ្ជូនខ្ញុំឲ្យទៅចូលរួមប្រជុំជាមួយបុគ្គលិកពេទ្យប្រហែល១០០នាក់ទៀត ដែលមានទីតាំងស្ថិតក្នុងផ្សារធំថ្មីបច្ចុប្បន្ន។ ការប្រជុំនេះ គឺជាការប្រជុំបែងចែកការងារទៅតាមផ្នែកនៅក្នុងមន្ទីរពេទ្យ។ ប្រធានអង្គប្រជុំបានប្រាប់ថា អ្នកដែលមកចូលរួមប្រជុំនេះភាគច្រើន គឺជាប្រជាជនភូមិភាគបូព៌ា និងនិរតី ដែលអង្គការចាត់ទុកថាមានប្រវត្តិរូបល្អ។ ខ្ញុំភ័យខ្លាចខ្លាំងណាស់ នៅពេលខ្ញុំហ្វឹកហាត់រៀនចាក់ថ្នាំជាមួយគ្រូពេទ្យទាំងជនជាតិខ្មែរនិងជនជាតិចិនដំបូងៗ រៀនចាក់ថ្នាំបានរយៈពេលប្រហែល១ខែ គ្រូពេទ្យទាំងនោះ បានបង្រៀនខ្ញុំពីរបៀបវះកាត់ និងពិនិត្យជំងឺទូទៅ។ ខ្ញុំរៀនពេទ្យពិតជាលំបាកណាស់ព្រោះខ្ញុំមិនចេះអានអក្សរ។ ខ្ញុំអាចប្រើប្រាស់ថ្នាំ និងព្យាបាលជំងឺផ្សេងៗបានដោយសារតែការអនុវត្តដដែលៗជាច្រើនដងនិងធ្វើការកត់ចំណាំទៅលើសញ្ញា ទ្រង់ទ្រាយ និងសម្បកថ្នាំ។ អ្នកជំងឺភាគច្រើននៅក្នុងមន្ទីរពេទ្យ ដែលខ្ញុំធ្វើការគឺជាកងទ័ពមកពីភូមិភាគបូព៌ាដឹកឆ្លងកាត់ទន្លេតាមស្រឡាង ហើយយកមកទុកនៅពីខាងមុខព្រះបរមរាជវាំង បន្ទាប់មកត្រូវសែងមកព្យាបាលនៅក្នុងមន្ទីរពេទ្យ៦មករា។ ខ្ញុំធ្លាប់បានឃើញហេតុការណ៍តក់ស្លុតជាច្រើន ក្នុងកំឡុងពេលដែលខ្ញុំវះកាត់ ដូចជាការកាត់ដៃជើង វះកាត់យកអំបែង និងគ្រោះថ្នាក់ផ្សេងៗទៀត។ ចំណែកឯប្រសិទ្ធភាពថ្នាំក្នុងរបបខ្មែរក្រហមនៅមានកម្រិត។ ម្ជុល និងសារាងដែលប្រើប្រាស់រួចត្រូវយកមកប្រើច្រើនដងទៀត បន្ទាប់ពីចំហុយរួចៗ ក្រៅពីការងារជា

ពេទ្យ ខ្ញុំធ្លាប់បានទៅទទួលថ្នាក់ដឹកនាំដូចជា ប៉ុល ពត និង អៀង សារី នៅពេលដែលគាត់ធ្វើដំណើរមកព្រះបរមរាជវាំង។ ក្នុងពេលនោះ អង្គការបាត់ចាត់តាំងក្រុមគ្រូពេទ្យជាច្រើនឈរអមតាមផ្លូវនៅម្តុំផ្សារថ្មី និងវត្តភ្នំ ដោយរៀបចំជា២ជួរ គឺប្រុស១ជួរ និងស្រី១ជួរ។ ស្ត្រីស្លៀកសំពត់ហូលនឹងអាវស ឈរតម្រៀបគ្នា ដោយនាំគ្នាស្រែកថា «ជ័យយោៗ» ដើម្បីអបអរសាទរដល់ថ្នាក់ដឹកនាំ។ ក្នុងឆ្នាំ១៩៧៨ ខ្ញុំបានចូលរួមប្រជុំជាមួយ អៀង សារី បុគ្គលិកពេទ្យ និងកម្មករធ្វើផ្ទះជាច្រើនទៀត។ ក្នុងការប្រជុំនោះ អៀង សារី បាននិយាយថា កិច្ចការដែលអង្គការដាក់ឲ្យធ្វើសព្វថ្ងៃគឺជាការងារជួយគាំទ្រដល់របបខ្មែរក្រហម ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត និងបានសុំឲ្យអ្នកចូលរួមទាំងអស់ខិតខំធ្វើការងារបម្រើអង្គការឲ្យបានល្អ។ ខ្ញុំបានឮមិត្តរួមការងាររបស់ខ្ញុំប្រាប់ថា មិត្តនារីពេទ្យជាច្រើនត្រូវបានអង្គការចាប់ខ្លួន ព្រោះដោយសារប្រព្រឹត្តខុសសីលធម៌ជាមួយកងទ័ពដែលសម្រាកពេទ្យនៅក្នុងមន្ទីរពេទ្យ។

ក្នុងឆ្នាំ១៩៧៩ ស្ថានភាពនៅក្នុងមន្ទីរពេទ្យចាប់ផ្តើមច្របូកច្របល់ដោយមានការនិយាយតៗគ្នានៅក្នុងមន្ទីរពេទ្យថា ទាហានវៀតណាមបានចូលមកសម្លាប់ប្រជាជននៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក ខ្ញុំនិងពេទ្យដ៏ទៃទៀតនៅក្នុងមន្ទីរពេទ្យ៦មករា បានចាកចេញពីទីក្រុងភ្នំពេញភ្លាមៗដោយធ្វើដំណើរតាមរថភ្លើងទៅកាន់ខេត្តបាត់ដំបង មុន១ថ្ងៃ ដែលទាហានវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ។ ចំណែកឯអ្នកជំងឺឈឺធ្ងន់ និងជនពិការដែលគ្មានសាច់ញាតិ និងមិនអាចចាកចេញ បានសម្រេចចិត្តបោកគ្រាប់បែកសម្លាប់ខ្លួនក្នុងមន្ទីរពេទ្យតែម្តង។ ខ្ញុំមិនបានចាំឈ្មោះទីកន្លែងដែលខ្ញុំរស់នៅក្នុងខេត្តបាត់ដំបងនោះទេ ប៉ុន្តែអ្វីដែលខ្ញុំចាំបំផុត គឺភាពលំបាកក្នុងការរត់តាមផ្លូវពីមួយកន្លែងទៅកាន់មួយកន្លែងទៀត ខ្វះខាតអាហារ សូម្បីតែទឹកក៏វាល់ចែកគ្នាផឹកដែរ។ កងទ័ពខ្មែរក្រហមយ៉ាងច្រើនកាន់សុទ្ធតែកាំភ្លើងបានជម្លៀសប្រជាជនពីកន្លែងមួយទៅកន្លែងមួយទៀត និងមិនអនុញ្ញាតឲ្យប្រជាជនណាម្នាក់រត់ត្រឡប់ក្រោយទេ។ ខ្ញុំបានឃើញមនុស្សជាច្រើនបានស្លាប់នៅតាមផ្លូវ ជាពិសេសក្មេងៗ និងមានទារកមួយចំនួនកំពុងស្រែកទ្រហោយំនៅលើទ្រូងម្តាយកំពុងដេកស្លាប់។ សំឡេងក្មេងយំលាន់រំពងពេញព្រៃ ដូចសត្វសារិកាស្រែករំពង។

ខ្ញុំពិតជាមនុស្សម្នាក់ មានសំណាងណាស់ក្នុងចំណោមប្រជាជនរាប់លាននាក់ ដែលបានស្លាប់ទៅ។

វ៉ាន់ ម៉ុន ជាស្ត្រីម្នាក់បានឆ្លងកាត់បទពិសោធន៍យ៉ាងច្រើនក្នុងរបបខ្មែរក្រហម។ សព្វថ្ងៃ ម៉ុន មានអាយុ៦០ឆ្នាំ មានមុខរបរធ្វើស្រែចម្ការ និងមានស្រុកកំណើតនៅក្នុងភូមិត្រពាំងធំ ឃុំជើងព្រៃ ស្រុកខដុក្គ ខេត្តកំពង់ស្ពឺ។ ម៉ុន បានផ្លាស់មករស់នៅក្នុងភូមិស្រះធុល ឃុំយុទ្ធសាមគ្គី ស្រុកខដុក្គ ខេត្តកំពង់ស្ពឺ។ ម៉ុន បានរៀបការជាមួយប្តីរបស់គាត់ឈ្មោះ ស៊ិន ខន ហើយមានកូន៦ នាក់ គឺស្រី១នាក់ និងប្រុស៥នាក់។ កូនប្រុសច្បងរបស់គាត់ បានស្លាប់ដោយសារជំងឺនៅក្នុងរបបខ្មែរក្រហម។

អ៊ុន សុដាវី

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូប ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួននឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសព្ទលេខ (៨៥៥) (១២) ៩៩៦ ៧៥០
ទូរសព្ទលេខ (៨៥៥) (២៣) ២១០ ៣៥៨
Email: truthbunthorn.s@dccam.org
Home Page: www.d.dccam.org

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណៈជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោងប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង មី បូរី តាមរយៈទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthborey.m@dccam.org។




















# ការផ្សះផ្សាតាមរយៈការផ្លាស់ប្តូរផ្នត់គំនិតរបស់និស្សិតកម្ពុជានៅក្នុង ទឹកដីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

ការសួរនាំ ការចែករំលែក និងការសិក្សាស្វែងយល់រឿងរ៉ាវពីអតីតកាល គឺជាជំហានមួយជួយឲ្យមានការផ្លាស់ប្តូរផ្នត់គំនិត ដើម្បីជំរុញឲ្យមានការផ្សះផ្សាសម្រាប់ប្រទេសក្រោយជម្លោះ។ ទោះបីជាសង្គ្រាមដ៏ឃោរឃៅនៅក្នុងប្រទេសកម្ពុជា បានផុតរលត់អស់រយៈពេលប្រហែល៤០ឆ្នាំកន្លងទៅយ៉ាងណាក៏ដោយ ក៏ការស្អប់ខ្ពើម គំនុំគំគួន និងភាពមិនទុកចិត្តគ្នា នៅតែដក់ជាប់ក្នុងចិត្ត ហើយស្រមោលអន្ទការទាំងអស់នៅតែបន្តលងបន្លាចដល់ប្រជាជនកម្ពុជាជាច្រើន និងបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ក្មេងៗជំនាន់ក្រោយ។

នៅរវាងឆ្នាំ១៩៧៥ដល់ ១៩៧៩ ប្រទេសកម្ពុជា បានធ្លាក់ចូលក្នុងរបបដ៏ឃោរឃៅមួយដែលយើងហៅថា របបខ្មែរក្រហម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ប៉ុល ពត។ ប៉ុល ពត គឺជាមេដឹកនាំម្នាក់ ដែលបានដឹកនាំប្រទេសឈានទៅរកភាពវិនាសអន្តរាយ បង្កឲ្យមានការកាប់សម្លាប់ប្រជាជនរបស់ខ្លួនឯងអស់ប្រហែល២លាននាក់ក្នុងរយៈពេលត្រឹមតែ៣ឆ្នាំ៨ខែនិង២០ថ្ងៃ។

អន្លង់វែង គឺជាស្រុកមួយស្ថិតនៅក្នុងភាគខាងជើងនៃប្រទេសកម្ពុជា តាមបណ្តោយជួរភ្នំដងរែក ដែលមានព្រំ



ក្រុមនិស្សិតស្ម័គ្រចិត្តមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចូលរួមដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង

ប្រទល់ជាប់ប្រទេសថៃ ហើយគឺជាតំបន់កាន់កាប់ចុងក្រោយបង្អស់របស់ខ្មែរក្រហម មានបន្សល់ទុកទីតាំងប្រវត្តិសាស្ត្រជាច្រើនបន្ទាប់ពីសង្គ្រាម។ ភាពស្ងប់ស្ងាត់ ភាពស្រស់ស្អាតនៃធម្មជាតិ រួមជាមួយភាពរីកចម្រើននៃការអភិវឌ្ឍន៍របស់តំបន់អន្លង់វែងនាពេលបច្ចុប្បន្ន បានធ្វើឲ្យយើងស្ទើរតែមិនជឿថាតំបន់អន្លង់វែង ធ្លាប់ជាទីកន្លែងដែលមានរឿងរ៉ាវជាច្រើនបានកើតឡើងពីអតីតកាល។

និស្សិតចំនួន២០ នាក់ ដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រ និងរដ្ឋបាលសាធារណៈឆ្នាំទី១នៃសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើដំណើរទស្សនកិច្ចសិក្សាទៅកាន់ស្រុកអន្លង់វែង ចាប់ពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ដឹកនាំដោយមជ្ឈមណ្ឌលឯកសារកម្ពុជានាពេលថ្មីៗនេះ ក្នុងគោលបំណងសិក្សាស្វែងយល់ពីរឿងរ៉ាវអតីតកាល ដែលបានកើតឡើងក្នុងស្រុកអន្លង់វែងតាមរយៈទីតាំងប្រវត្តិសាស្ត្រ និងប្រជាជននៅក្នុងតំបន់អន្លង់វែង ដើម្បីអាចនិងទទួលបានចំណេះដឹងផ្នែកប្រវត្តិសាស្ត្រនិងជំរុញឲ្យមានការផ្សះផ្សានាពេលអនាគត។ ដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់អន្លង់វែងនេះ បានធ្វើឲ្យនិស្សិតភាគច្រើនយល់ដឹងពីប្រវត្តិសាស្ត្ររបស់តំបន់អន្លង់វែង និងបានផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួនទៅលើប្រជាជន ក៏ដូចតំបន់អន្លង់វែង។ ក្នុងចំណោមនោះ ក៏មាននិស្សិតមួយចំនួនតូចនៅតែមានការយល់ឃើញពីភាពអវិជ្ជមានមួយចំនួន ចំពោះតំបន់អន្លង់វែង ដោយសារតែតំបន់នេះ បានបន្សល់ទុកនូវភ័ស្តុតាងប្រវត្តិសាស្ត្រជាក់ស្តែងជាច្រើន ដែលនិស្សិតខ្លះមិនអាចទទួលយកបាន។ ខាងក្រោមនេះ ជាការចែករំលែកនូវចំណាប់អារម្មណ៍ និងការយល់ឃើញចំពោះតំបន់អន្លង់វែងរបស់ក្រុមនិស្សិតទាំងអស់ ៖

**វី ថានី ៖** «ខ្ញុំមានអារម្មណ៍សោកស្តាយ និងសោកសង្រេងចំពោះប្រជាជនកម្ពុជាយ៉ាងខ្លាំង ដែលបានទទួលរងគ្រោះ និងស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមអស់យ៉ាងច្រើន។ នៅក្នុងរយៈពេលនៃដំណើរទស្សនកិច្ចសិក្សា ខ្ញុំបាន


វី ថានី និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ទទួលបានបទពិសោធន៍ និងចំណេះដឹងប្រវត្តិសាស្ត្រជាច្រើន រួមទាំងការយល់ដឹងពីស្ថានភាពនៃការរស់នៅរបស់ប្រជាជនអន្លង់វែង។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលបន្តិច នៅពេលចុះជួបសម្ភាសន៍ជាមួយពូមីងរស់នៅក្នុងអន្លង់វែង ខណៈពួកគាត់មានអារម្មណ៍ភ័យខ្លាច នៅពេលឃើញវត្តមានរបស់យើង។ យ៉ាងណាក៏ដោយ បន្ទាប់ពីដំណើរទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខ្ញុំទទួលបានចំណេះដឹង និងបទពិសោធន៍ជាច្រើន អមជាមួយធម្មជាតិដ៏ស្រស់ស្អាតនៃទឹកដីអន្លង់វែង បានធ្វើឲ្យខ្ញុំផ្លាស់ប្តូរ ទស្សនៈរបស់ខ្ញុំពីមុនចំពោះប្រជាជនរស់នៅអន្លង់វែង រួមទាំងប្រវត្តិសាស្ត្រខ្មែរ-ក្រហមដែរ»។

**យន បុរីរតនៈ ៖** ខាងក្រោមនេះ ជាមតិរបស់ខ្ញុំទាក់ទងនឹងដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង។


យន បុរីរតនៈ និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

«នឹកកាលគ្រានៅអន្លង់វែង ខ្ញុំគ្មានចំបែងក្នុងទិវា”

រៀនសូត្រ ចេះដឹងបានប្រាជ្ញា ឯម្ហូបអាហារក៏គ្រប់គ្រាន់ៗ សាមគ្គីសាមគ្គាជាជោគជ័យ ពួកយើងឃ្លាតឃ្លីខំរួសរាន់ គ្រប់ៗរូបភាពថតចំណាំ ទុកផ្តាំញាតិមិត្តទៅថ្ងៃក្រោយៗ អន្លង់វែងជាទីឋានល្អពិត ដិតដាមដក់ជាប់ចិត្តខ្ញុំហើយ នៅក្នុងជាតិនេះបានស្គាល់ហើយ អន្លង់វែងអើយចាំខ្ញុំផងៗ អន្លង់វែងប្រវត្តិជូរចត់ពិតមិនបានប្រឌិត នាំសោហ្មង ខ្ញុំបានសាកសួរទៅអ្នកផង រៀមច្បងក៏បានជួយណែនាំៗ រៀនបានដឹងពីអន្លង់វែង ការពិតជាក់ស្តែងគឺសុាំញាំ អ្នកអន្លង់វែងស៊ូទ្រាំ ទម្រាំបានផុតពីសង្គ្រាមៗ អន្លង់វែងអើយខ្ញុំនឹកអ្នក វាយោត្រជាក់ដល់សសៃឈាម អន្លង់វែងដក់ជាប់បេះដូងរៀម សង្ឃឹមថាបានទៅម្តងទៀត»ៗ

**ស៊ឹម គឹមហាវ** ៖ «ខ្ញុំមានអារម្មណ៍រំភើបផង សប្បាយ



ស៊ឹម គឹមហាវ និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ចិត្តផង នៅពេលដែលខ្ញុំបានចូលរួមធ្វើដំណើរទស្សនកិច្ចទៅកាន់តំបន់អន្លង់វែង ព្រោះខ្ញុំបានមើលឃើញទេសភាពធម្មជាតិដ៏ស្រស់ស្អាតនៅអមតាមដងផ្លូវៗ ប៉ុន្តែទន្ទឹមនឹងនេះ ខ្ញុំក៏មានអារម្មណ៍ភ័យតិចតួចដែរ នៅពេលដែលខ្ញុំធ្វើការសម្ភាសន៍ជាមួយប្រជាជន ដែលរស់នៅក្នុងស្រុកអន្លង់វែង ព្រោះខ្ញុំមិនធ្លាប់ធ្វើការសម្ភាសន៍ពីមុនមកទេ»ៗ

**តុប ច័ន្ទរតនា** ៖ «បន្ទាប់ពីខ្ញុំបានចូលរួមដំណើរទស្សនកិច្ចសិក្សាទៅកាន់ស្រុកអន្លង់វែងរួចមក ខ្ញុំពិតជាមានអារម្មណ៍សប្បាយរីករាយណាស់ ទោះបីជាខ្ញុំហត់បន្តិចក៏ដោយៗ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងមជ្ឈមណ្ឌល



តុប ច័ន្ទរតនា និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សន្តិភាពអន្លង់វែង ដែលបានបង្កើតដំណើរទស្សនកិច្ចសិក្សានេះឡើងៗ ខ្ញុំបានទទួលនូវបទពិសោធន៍យ៉ាងច្រើន ដែលខ្ញុំមិនធ្លាប់មានពីមុនមកៗ ខ្ញុំក៏សូមថ្លែងអំណរគុណដល់មគ្គុទេសក៍ ដែលបានធ្វើបទបង្ហាញពីតំបន់ប្រវត្តិសាស្ត្រខ្មែរក្រហមទាំង ១៨កន្លែងឲ្យខ្ញុំបានដឹង និងបានស្គាល់កាន់តែច្បាស់ពីកន្លែងទាំងអស់នោះ»ៗ

**ស្រ៊ឹ ពេញចិត្ត** ៖ «ខ្ញុំបានទទួលការសិក្សាស្វែងយល់ជាច្រើនអំពីជីវភាពរស់នៅរបស់ប្រជាជននៅក្នុងស្រុកអន្លង់វែង និងការស្វែងរកការពិត ដែលខ្ញុំមិនធ្លាប់ដឹងពីមុនមកៗ ប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែង បានស្វាគមន៍ដល់ក្រុមរបស់ខ្ញុំយ៉ាងកក់ក្តៅ ដោយស្នាមញញឹម ភាពរួសរាយរាក់ទាក់ ហើយថែមទាំងបានផ្តល់បទសម្ភាសដល់ក្រុមខ្ញុំអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ក្នុងរបបខ្មែរក្រហមៗ លើសពីនេះ ខ្ញុំក៏បានទទួលបទពិសោធន៍ជាច្រើន ដូចជា វិធីសាស្ត្រនៃការ



ស្រ៊ឹ ពេញចិត្ត និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ទំនាក់ទំនងជាមួយអ្នកភូមិ ការរៀនថតវីឌីអូ ការចូលរួមដាំដើមឈើនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ហើយថែមទាំងបានស្គាល់តំបន់ប្រវត្តិសាស្ត្រទាំង១៨កន្លែង នៅក្នុងស្រុកអន្លង់វែង ដែលបានបន្សល់ទុកពីរបបខ្មែរក្រហម។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំបានទទួលចំណេះដឹងបន្ថែមអំពីការដឹកនាំរបស់មេដឹកនាំខ្មែរក្រហមដូចជា ប៉ុល ពត តាម៉ុក ខៀវ សំផន សុន សេន ដែលខ្ញុំមិនធ្លាប់បានដឹងច្បាស់ពីមុនមក។ ចំណែកឯការធ្វើដំណើរ ការហូបចុក និងការស្នាក់នៅវិញ គឺខ្ញុំគ្មានបញ្ហាអ្វីទាំងអស់ ព្រោះខ្ញុំបានទទួលការយកចិត្តទុកដាក់ពីលោកនាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងគឺបង លី សុខឃាង និងក្រុមការងាររបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ខ្ញុំក៏សូមអរគុណដល់ បង ស៊ាង ចិន្តា ជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានទូរសព្ទសួរសុខទុក្ខ និងយកចិត្តទុកយ៉ាងខ្លាំងមកលើរូបខ្ញុំក៏ដូចជាមិត្តភក្តិរបស់ខ្ញុំដែរ»។

***រ៉េត ម៉េងហៃ*** ៖ «សម្រាប់រូបខ្ញុំផ្ទាល់ ខ្ញុំពិតជាមានសេចក្តី



រ៉េត ម៉េងហៃ និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សោមនស្សជាខ្លាំង ដែលបានចូលរួមជាមួយដំណើរទស្សនកិច្ចសិក្សាទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង»។

***មុត ច័ន្ទរីណា*** ៖ «សម្រាប់ខ្ញុំអត់មានបញ្ហាអ្វីទេជាមួយទស្សនកិច្ចសិក្សានេះ ទាំងការស្នាក់នៅ ម្ហូបអាហារ គឺសុទ្ធតែល្អ។ អ្នកភូមិដែលរស់នៅក្នុងស្រុកអន្លង់វែង សុទ្ធតែរួសរាយ និងសប្បាយចិត្ត នៅពេលបានឃើញក្រុមនិស្សិតទៅទស្សនកិច្ចភូមិរបស់គាត់។ ចំពោះចំណេះដឹងវិញ ខ្ញុំទទួលបានជាច្រើន



មុត ច័ន្ទរីណា និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

រួមមានប្រវត្តិសាស្ត្រ ដែលខ្ញុំអត់ធ្លាប់បានរៀន និងចំណេះដឹងអំពីរបៀបនៃការថត ការសរសេរ ក៏ដូចជាការបង្កើតទំនាក់ទំនង ហើយខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានដាំកូនឈើនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ សរុបជារួម ខ្ញុំទទួលបានបទពិសោធន៍ ថ្មីយ៉ាងច្រើន ហើយសប្បាយចិត្តណាស់តាំងពីធ្វើដំណើរចេញទៅស្រុកអន្លង់វែងរហូតត្រឡប់មកផ្ទះវិញ។ ចំពោះសុខភាព ខ្ញុំមានអាការៈឈឺក្បាល និងផ្តាសាយបន្តិចបន្តួច ដោយសារតែខ្ញុំធ្វើដំណើរហត់ និងគេងមិនសូវបានច្រើនដោយសារតែប្លែកកន្លែង។ ម្យ៉ាងទៀត អាកាសធាតុនៅតំបន់អន្លង់វែង ត្រជាក់ណាស់ហើយមានភ្លៀងច្រើនជាងនៅភ្នំពេញ ប៉ុន្តែខ្ញុំមិនបានគិតថាកត្តាទាំងនេះជាបញ្ហាចោទនោះទេ តែផ្ទុយទៅវិញ ខ្ញុំគិតថាបញ្ហាទាំងអស់នេះគឺជាបទពិសោធន៍ដ៏ល្អសម្រាប់ខ្ញុំ»។

***ព្រាំ គិតម៉ាន់*** ៖ «ខ្ញុំមានអារម្មណ៍ថា ទោះបីជាដំណើរ



ព្រាំ គិតម៉ាន់ និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង ជាបទពិសោធន៍នៅក្នុងសង្គមលើកដំបូងរបស់ខ្ញុំ ប៉ុន្តែដំណើរទស្សនកិច្ចនេះក៏ជាការចងចាំជារៀងរហូតរបស់ខ្ញុំដែរ»។

***សៀ គីមចេង*** ៖ «បន្ទាប់ពីខ្ញុំបានធ្វើដំណើរទស្សនកិច្ច



សៀ គីមចេង និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សិក្សានៅស្រុកអន្លង់វែងរួចមក ខ្ញុំពិតជាមានអារម្មណ៍សប្បាយ ទោះបីជាហត់ក្នុងការធ្វើដំណើរបន្តិចក៏ដោយ តែទោះបីជាយ៉ាងណា ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដែលបានបង្កើតនូវទស្សនកិច្ចនេះឡើង សម្រាប់ឲ្យសិស្ស ក៏ដូចជានិស្សិតជំនាន់ក្រោយដូចក្រុមរបស់ខ្ញុំទទួលបាននូវបទពិសោធន៍ជាច្រើន ដែលពីមុនមកខ្ញុំមិនធ្លាប់បានចូលរួម។ លើសពីនេះ ខ្ញុំបានចុះធ្វើការស្រាវជ្រាវដោយផ្ទាល់តាមរយៈការចុះសម្ភាសន៍ជាក់ស្តែងជាមួយប្រជាជននៅតាមតំបន់នោះ។ ការសិក្សាពីបូជនីយដ្ឋានប្រវត្តិសាស្ត្រជាច្រើនកន្លែង និងការដាំដំណាំដូចជា សណ្តែក និងពោត ដែលទិដ្ឋភាពនោះធ្វើឲ្យខ្ញុំបំភ្លេចមិនបានឡើយ។ ទោះបីជាយ៉ាងណា ខ្ញុំក៏សូមអរគុណដល់មគ្គុទេស ដែលបានធ្វើបទបង្ហាញពីតំបន់ប្រវត្តិសាស្ត្រទាំង ១៨កន្លែង ឲ្យខ្ញុំបានដឹង និងបានស្គាល់។ អ្វីដែលជាកត្តាសំខាន់នោះ គឺការយកចិត្តទុកដាក់ពីសំណាក់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមកកាន់និស្សិតទាំងអស់ ហើយខ្ញុំសង្ឃឹមថា បើមានឱកាសក្រោយទៀតខ្ញុំរីករាយក្នុងការសហការនិងចូលរួមជាមួយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៀត»។

***ជឹប សត្ថាវី*** ៖ «បន្ទាប់ពីខ្ញុំបានធ្វើដំណើរទៅទស្សនកិច្ច



ជឹប សត្ថាវី និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ទៅកាន់ស្រុកអន្លង់វែងរួចមក ខ្ញុំទទួលបានចំណេះដឹងជាច្រើនអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក៏ដូចជាស្រុកអន្លង់វែងផ្ទាល់ និងទទួលបានបទពិសោធន៍ពីការធ្វើដំណើរនេះយ៉ាងច្រើន។ ទោះបីជាខ្ញុំមានជំងឺផ្តាសាយតិចតួច ព្រោះតែសុខភាពរបស់ខ្ញុំខ្សោយ ប៉ុន្តែខ្ញុំនៅតែសប្បាយចិត្តជាមួយនឹងការធ្វើដំណើរមួយនេះ។ ជាចុងក្រោយខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្វើឲ្យខ្ញុំទទួលបានឱកាសដ៏កម្រមួយនេះ និងអរគុណជាខ្លាំងដល់បងៗក្រុមការងារ ដែលមើលការខុសត្រូវ និងមើលថែដល់ខ្ញុំផ្ទាល់នៅទីនោះបានយ៉ាងល្អ»។

***ទូន រក្សា*** ៖ «ខ្ញុំមានអារម្មណ៍រំភើប និងសប្បាយរីក



ទូន រក្សា និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

រាយណាស់ ដែលបានធ្វើដំណើរទៅកាន់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ព្រោះខ្ញុំបានយល់ដឹងច្រើនពីរឿងរ៉ាវទាក់ទងនឹង

តំបន់អន្លង់វែង។ ប៉ុន្តែអ្វីដែលខ្ញុំចាប់អារម្មណ៍ជាងគេគឺការរស់នៅរបស់ប្រជាជននៅទីនោះ ព្រោះគាត់បានរៀបរាប់ពីជីវប្រវត្តិរបស់គាត់ពីមុនសម័យខ្មែរក្រហមមកដល់បច្ចុប្បន្ន»។

**សឿន ចាន់ថេង** ៖ «សម្រាប់ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ សម្រាប់ដំណើរទស្សនកិច្ចទៅកាន់តំបន់សន្តិភាពអន្លង់វែង ចាប់តាំងពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ នាពេលកន្លងមកនេះ។ ចំណែកឯការធ្វើដំណើរ ការហូបចុក និងការស្នាក់នៅគឺល្អខ្លាំងណាស់ ពិតជាធ្វើឲ្យខ្ញុំនឹកស្មានមិនដល់ ព្រោះមុនពេលដែលខ្ញុំទៅដល់ស្រុកអន្លង់វែងខ្ញុំបានគិតថា តើខ្ញុំនឹងអាចទៅស្នាក់នៅផ្ទះដែលនៅក្នុងព្រៃ ហើយជាកន្លែងស្ងាត់មិនសូវមានមនុស្សរស់នៅដែរឬទេ? ប៉ុន្តែអ្វីៗខុសពីការគិតទាំងស្រុងរបស់ខ្ញុំ។ ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានផ្តល់ឱកាសចែករំលែកចំណេះដឹង និងបទពិសោធន៍ជាច្រើនមកកាន់ខ្ញុំក៏ដូចជាក្រុមនិស្សិតទាំងអស់ ហើយក៏សូមអរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ដែលបានយកចិត្តទុកដាក់ មកលើក្រុមនិស្សិតទាំងអស់គ្នា អរគុណ»។


សឿន ចាន់ថេង និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**ពៅ ដេយវិន** ៖ «បន្ទាប់ពីបានចូលរួមដំណើរទស្សនកិច្ចសិក្សាអស់រយៈពេល ៤ថ្ងៃ ៣យប់ទៅកាន់ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យមក ខ្ញុំមានអារម្មណ៍សប្បាយចិត្ត និងរីករាយយ៉ាងខ្លាំង ទាំងការហូបចុក ទាំងការស្នាក់នៅការធ្វើដំណើរកម្សាន្ត និងជាពិសេសបានទទួលបានចំណេះដឹងជាច្រើនដែលទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជានៅក្នុងស្រុកអន្លង់វែង។ លើសពីនេះ ខ្ញុំបានទទួលបទពិសោធន៍យ៉ាងថ្មីស្រឡាងមួយគឺ ការសម្ភាសន៍ប្រជាជនអំពីប្រវត្តិនៃការឆ្លងកាត់របបខ្មែរក្រហមរបស់គាត់។ ខ្ញុំមានអារម្មណ៍ថានឹកទីកន្លែងនោះខ្លាំងណាស់ ទោះបីជាខ្ញុំបានត្រឡប់មកភ្នំពេញវិញក៏ដោយ នឹកអនុស្សាវរីយ៍ ដែលខ្ញុំធ្លាប់បានធ្វើការងារជាក្រុមជាមួយមិត្តរួមថ្នាក់ និងថែមទាំងនឹកទេសភាព និងបរិយាកាសនៅក្នុងស្រុកអន្លងវែងដែរ»។


ពៅ ដេយវិន និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**ខុម គីមរ៉ា** ៖ «ខ្ញុំចង់និយាយថា អន្លង់វែង មានសម្រស់ស្រស់ស្អាត ជាមួយប្រវត្តិសាស្ត្រជាច្រើន»។


ខុម គីមរ៉ា និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**ស៊ីម រ៉ា** ៖ «អត្ថាភាព ពិតជាមានចិត្តរំភើបរីករាយណាស់ដែលបានទៅទស្សនកិច្ចសិក្សានៅសហគមន៍អន្លង់វែង សូមអរគុណមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានអនុញ្ញាត



ស៊ីម រ៉ា និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ឲ្យអាត្មាភាពចូលរួមដំណើរទស្សនកិច្ចមួយនេះ ដែលអាត្មាភាពទទួលបានបទពិសោធន៍ និងចំណេះដឹងប្រវត្តិសាស្ត្រជាច្រើន»។

**រ៉ឹម សុខខេង ៖** «ខ្ញុំបាទ ឈ្មោះ រ៉ឹម សុខខេង ចង់បង្ហាញពីចំណាប់អារម្មណ៍របស់ខ្ញុំទៅលើដំណើរទស្សនកិច្ចសិក្សាសម្រាប់រយៈពេល៤ថ្ងៃ ទៅកាន់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ អន្លង់វែងជាទីកន្លែង ដែលមានសម្រស់ធម្មជាតិ



រ៉ឹម សុខខេង និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ដ៏ស្អាតផ្សារភ្ជាប់ និងរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជា។ យើងពេញចិត្តនឹងដំណើរទស្សនកិច្ចមួយនេះគ្រប់ៗគ្នា ជាមួយស្នាមញញឹម។ ខ្ញុំបានទៅកន្លែងជាច្រើននៅក្នុងស្រុកខ្មែរ ប៉ុន្តែអន្លង់វែងបានធ្វើឲ្យខ្ញុំចងចាំពីប្រវត្តិសាស្ត្ររបស់យើង និងទឹកដីទល់ដែនមួយនេះ ពោរពេញទៅដោយសម្រស់ធម្មជាតិ ដែលខ្ញុំមិនអាចបំភ្លេចបានពីសកម្មភាពដែលខ្ញុំបានធ្វើនៅក្នុងស្រុកអន្លង់វែងបាន។ រយៈពេល៤ថ្ងៃ ខ្ញុំពេញចិត្តក្នុងការសិក្សា ការធ្វើការងារជាក្រុម ដោយស្នាមញញឹមគ្រប់កាលៈទេសៈទាំងអស់។ ការធ្វើដំណើរទស្សនកិច្ចរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងពិសេសដូចជា កាស្វែងយល់ពីទីតាំងរបស់ប្រវត្តិសាស្ត្រ និងការរស់នៅរបស់ប្រជាជនមូលដ្ឋាន»។

**ទឹម ពន្លឺ ៖** «ការចុះកម្មសិក្សានេះពិតជាមានសារសំខាន់ណាស់សម្រាប់ខ្ញុំ ព្រោះវាជាបទពិសោធន៍ថ្មីមួយសម្រាប់ខ្ញុំ



ទឹម ពន្លឺ និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ហើយតាមរយៈបទពិសោធន៍នេះដែរ បានជួយឲ្យខ្ញុំកាន់តែយល់ច្បាស់ពីរបបខ្មែរក្រហម ដែលបានកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩។ ចំពោះការមើលថែ និងយកចិត្តទុកដាក់ ពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាល្អណាស់ ទាំងការហូបចុក និងការស្នាក់នៅ។ ចុងក្រោយខ្ញុំសូមអរគុណសម្រាប់ការយកចិត្តទុកដាក់ចំពោះក្រុមនិស្សិតយើងទាំងអស់គ្នា»។

**ឈួន ចំប៊ី ៖** «ខ្ញុំបាទឈ្មោះ ឈួន ចំប៊ី។ ចំពោះដំណើរទស្សនកិច្ចទៅកាន់ស្រុកអន្លង់វែង ខ្ញុំមិនយល់ថា ជាកន្លែងសប្បាយបន្តិចសោះ បានតែនាំភាពក្រៀមក្រាំខ្លោចផ្សាស្រណោះឈាមជ័រខ្មែរ ធ្លាប់រត់លូន ដេកតែក្នុងព្រៃគ្មានអ្វីបរិភោគហូបបានតែស្លឹកឈើ ដេកព្រួយ ដេកខ្លាចគ្មានថ្ងៃណាភ្លេច លាក់ឈ្មោះលាក់ប្រវត្តិ។ ពេលក្រុមនិស្សិតយើងធ្វើដំណើរទៅដល់ជិតផ្ទះរបស់ប្រជាជនដើម្បីធ្វើការសម្ភាសន៍ គាត់បានជិះកង់ជៀសចេញ អ្នកខ្លះថាចាំមិនបាន មិនស្គាល់


ឈួន ចំប៉ី និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

និងមិនលំបាកអ្វីឡើយក្នុងរបបខ្មែរក្រហម។ ក្រុមនិស្សិតរបស់យើងចង់ដឹងរឿងពិត តែបែរជានិយាយរឿងមិនពិតឲ្យយើងស្តាប់ ដោយសង្ស័យថាយើងជាអ្នកយកការណ៍នយោបាយ។ ប្រជាជន ហាក់បីដូចជាមិនចង់និយាយប្រាប់ក្រុមនិស្សិតរបស់យើងឡើយ។ ខ្ញុំពិតជាអាសូរគាត់ណាស់។ តើសប្បាយត្រង់ណានៅពេលឃើញ ១)កន្លែងដុតខ្មោចរបស់ ប៉ុល ពត ២)ទីតាំងបូជាសពរបស់ សុន សេន និងគ្រួសារ ៣)ផ្នូររបស់ តាម៉ុកដែលមិនហ៊ានសរសេរសូម្បីតែឈ្មោះ។ តើក្រុមនិស្សិតរបស់យើងនឹងអាចជួយអ្វីបានដល់ប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែង? គិតឃើញអ្វី? ទស្សនកិច្ចសិក្សានេះល្អហើយ តែខុសពេលបន្តិច ហើយក៏មិនមានអ្វីធ្វើឲ្យអន្លង់វែងចាប់ចិត្តយើងដែរ។ សម្រាប់ខ្ញុំ ទោះបីជាគិតឃើញ ក៏មិនប្រាកដថាធ្វើបានដែរ។ ខ្ញុំក៏មិនអាចភ្លេចគុណអ្នកគ្រូ សៀវម៉ី និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើឲ្យខ្ញុំចេះគិតដែរ។

**រិន ម៉ាលីន ៖** «ជាដំបូងខ្ញុំសូមអរគុណដល់អ្នកគ្រូ ជា សៀវម៉ី អរគុណមជ្ឈមណ្ឌលឯកសារកម្ពុជា និងមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបានផ្តល់ពេលវេលាដ៏មានតម្លៃ និងការមើលថែ ការយកចិត្តទុកដាក់បំផុត។ បន្ទាប់ពីខ្ញុំបានទៅទស្សនកិច្ចសិក្សានៅស្រុកអន្លង់វែងរួចមក ខ្ញុំពិតជាទទួលបានបទពិសោធន៍ជាច្រើន ដែលខ្ញុំមិនធ្លាប់បានដឹង ស្គាល់ និងជួបប្រទះពីមុនមក។ ខ្ញុំសូមអរគុណដល់បងៗមគ្គុទេសអន្លង់វែង ដែលបានធ្វើបទបង្ហាញពីតំបន់ប្រវត្តិសាស្ត្រទាំង១៤ កន្លែងឲ្យខ្ញុំបានស្គាល់ និងដឹងពីតំបន់នីមួយៗនៅទីនោះ។ ជាពិសេសទៅទៀតនោះ ខ្ញុំសូមអរគុណប្រជាជននៅតំបន់អន្លង់វែងទាំងពីរឃុំ ដែលបានផ្តល់បទសម្ភាសន៍ពីដំណើរប្រវត្តិតស៊ូរបស់ខ្លួននាសម័យកម្ពុជាប្រជាធិបតេយ្យ និងជីវិតរស់នៅប្រចាំថ្ងៃ ដែលបានធ្វើឲ្យខ្ញុំយល់ដឹងបានកាន់តែច្បាស់លាស់ពីប្រវត្តិសាស្ត្រដ៏ជូរចត់នាសម័យនោះ។ ជាចុងក្រោយខ្ញុំពិតជាមានអារម្មណ៍រំភើប និងមានមោទនភាពទៅលើប្រទេសកម្ពុជានាពេលបច្ចុប្បន្ន និងមានការសោកស្តាយជាខ្លាំង


រិន ម៉ាលីន និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

ទៅលើសោកនាដកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនគួរឲ្យកើតឡើងទាល់តែសោះ។ ដូច្នេះយើងគួរចូលរួមចំណែកថែរក្សាការចងចាំនៃកេរដំណែលរបស់ខ្មែរក្រហម និងស្តាឡើងវិញនូវអ្វីដែលបានបាត់បង់ ដើម្បីប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសមួយ ដែលរុងរឿង និងមានវឌ្ឍនៈភាពនៅក្នុងសកលលោក»។


សេន គិមឡាង និស្សិតឆ្នាំទី១
នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សេន គឹមឡាង៖** «អរគុណបងសម្រាប់សំណួរដ៏ល្អមួយនេះ សម្រាប់ខ្ញុំផ្ទាល់ក្រោយពីបានទៅទស្សនកិច្ចនៅតំបន់អន្លង់វែងរួចមក បានធ្វើឲ្យខ្ញុំទទួលបាននូវបទពិសោធន៍ល្អៗជាច្រើនក្នុងការធ្វើកិច្ចការងារជាក្រុម និងបានយល់ដឹងច្រើនជាងមុនទាក់ទងទៅនឹងប្រវត្តិសាស្ត្ររបស់ប្រទេសយើង។ ខ្ញុំពិតជារីករាយខ្លាំងណាស់ ដែលបានចូលរួមចំណែកមួយនៅក្នុងដំណើរទស្សនកិច្ចមួយនេះ ហើយក៏សូមអរគុណមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានបង្កើតឲ្យមានដំណើរទស្សនកិច្ចសិក្សាមួយនេះឡើង ដែលនេះជាឱកាសមួយបានជួយឲ្យខ្ញុំទទួលបានចំណេះដឹងថ្មីៗជាច្រើនបន្ថែមទៀត។ ខ្ញុំសូមអរគុណក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់ និងមជ្ឈមណ្ឌលឯកសារកម្ពុជា»។

**អ៊ុន សុដារី**



ក្រុមនិស្សិតស្ម័គ្រចិត្ត កំពុងដាំកូនឈើក្នុងបរិវេណមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ ត្រូវបានជ្រើសរើស សម្រាប់ពានរង្វាន់ណូបែលអាស៊ីឆ្នាំ២០១៨

លោក ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ពានរង្វាន់ Ramon Magsaysay Award ដែលត្រូវបានគេស្គាល់ថា ជាពានរង្វាន់ណូបែលសម្រាប់ទ្វីបអាស៊ី ឆ្នាំ២០១៨ យោងតាមការប្រកាសរបស់គណកម្មការនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាសប្តាហ៍កន្លងទៅនេះ។

ការជ្រើសរើសលោក ឆាំង យុ ផ្អែកទៅលើការងាររបស់លោកក្នុងការប្រមូលផ្តុំនិងចងក្រងឯកសារពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមដ៏សន្ធឹកសន្ធាប់ ដើម្បីការផ្សះផ្សា យុត្តិធម៌ និងការចងចាំដើម្បីការអប់រំនិងទប់ស្កាត់អំពើប្រល័យពូជសាសន៍សម្រាប់កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត។

លោកសូមអរគុណដល់ប្រទេសហ្វីលីពីនដែលបានជួយជនភៀសខ្លួនកម្ពុជាអំឡុង ឆ្នាំ១៩៨០ ក្រោយពេលរបបខ្មែរក្រហមដួលរលំ។ លោកបន្តថា៖ «អ្នករស់រានជីវិតពីរបបខ្មែរក្រហមបានរំឮកខ្ញុំរាល់ថ្ងៃថា កុំឲ្យបោះបង់ចោលក្តីសង្ឃឹម។ ចំណែកពានរង្វាន់នេះក៏ដូចគ្នា វាជាការរំឮកមួយចំពោះចិត្តសន្តោសរបស់ជនជាតិហ្វីលីពីនដល់ម្តាយរបស់ខ្ញុំ និងម្តាយទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលបានរួចរស់ពីរបបប្រល័យពូជសាសន៍។ ប្រជាជននិងរដ្ឋាភិបាលហ្វីលីពីន ក៏ដូចជាបណ្តាប្រទេសដទៃទៀត បានជួយដល់យើង។ រង្វាន់មួយនេះជាការអរគុណដល់ប្រទេសហ្វីលីពីន ដែលបានជួយសង្គ្រោះពលរដ្ឋកម្ពុជាកាលពីគ្រានោះ ហើយវាក៏ជាឧទាហរណ៍ដ៏មានតម្លៃដើម្បីឲ្យយើងមិនបោះបង់ចោលក្តីសង្ឃឹម»។

ក្នុងនាមជាជនរងគ្រោះដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម លោក ឆាំង យុ ចង់ឲ្យអ្នករស់រានមានជីវិតផ្សេងទៀតមានក្តីសង្ឃឹមនិងផ្សះផ្សារបួសផ្លូវចិត្ត ដែលខ្ទេចខ្ទាំដោយសារព្រាត់ប្រាស់មនុស្សជាទីស្រលាញ់។ លោកនិយាយថា៖ «ប្រសិនបើ អ្នកបានរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ អ្នកគឺជាមនុស្សដែលមានសំណាងខ្លាំងណាស់។ អ្នកអាចចាប់ផ្តើមជីវិតសារជាថ្មីម្តងទៀត។ អ្នកអាចមានទីជម្រក មានផ្ទះសម្បែង មានការងារធ្វើ មានមិត្តភក្តិ និងចាប់ផ្តើមកសាងគ្រួសារថ្មីមួយ។ ប៉ុន្តែអ្នកនឹងមានការរំខានដោយសារតែរឿងរ៉ាវជាច្រើនដែលបានកើតឡើងមកលើខ្លួនឯង។ ជីវិតនិងផ្លូវចិត្តរបស់អ្នកទទួលរងការបែកបាក់។ បេះដូងរបស់អ្នកទទួលរងការឈឺចាប់ ពីការបាត់បង់មនុស្សជាទីស្រឡាញ់។ អ្នកត្រូវបានរំខានដោយការចងចាំរបស់អ្នក។ អ្នកមានអារម្មណ៍ថា មានកំហុសដោយសារតែអ្នកអាចរស់រានមានជីវិតខណៈដែលមនុស្សជាច្រើននាក់ផ្សេងទៀតបានបាត់បង់ជីវិត ហើយអ្វីដែលអាក្រក់ជាងនេះទៀតនោះ គឺអ្នកអាចបាត់បង់ក្តីសង្ឃឹម។ ពានរង្វាន់មួយនេះតំណាងការមិនឲ្យបោះបង់ចោលនូវសេចក្តីសង្ឃឹមសម្រាប់អនាគតដ៏ប្រសើរមួយ»។

គួររំឮកថា នេះជាខួបលើកទី៦០នៃការប្រគល់ពានរង្វាន់ ហើយបុគ្គលដែលជាប់ចំណាត់ថ្នាក់សម្រាប់ពេលនេះ មានសរុបប្រាំមួយរូប ក្នុងនោះរួមមានប្រទេសឥណ្ឌាពីររូប វៀតណាមមួយរូប កម្ពុជាមួយរូប ហ្វីលីពីនមួយរូប និងទីម័រមួយរូប។ ពិធីប្រគល់ពានរង្វាន់ផ្លូវការនឹងប្រារព្ធធ្វើនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ នៅប្រទេសហ្វីលីពីន។

ពានរង្វាន់ រ៉ាម៉ុន ម៉ាសាយសាយ ជាពានរង្វាន់ដ៏ខ្ពង់ខ្ពស់សម្រាប់អ្នកដឹកនាំនៅអាស៊ី។ ចាប់តាំងពីការបង្កើតពានរង្វាន់នេះតាំងពីឆ្នាំ១៩៥៧ មក មានបុគ្គលនិងស្ថាប័នជាង៣០០ ដែលត្រូវបានផ្តល់ជូនចំពោះការងារបម្រើសង្គមរបស់ខ្លួន ថ្នាក់តំបន់អាស៊ី និងពិភពលោក ដែលបានដោះស្រាយបញ្ហាជាច្រើនសម្រាប់ការអភិវឌ្ឍមនុស្សជាតិ។ **សាន ប៊ុនស៊ីម**

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន៣០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរពីប្រវត្តិសាស្ត្ររឿងរ៉ាវចេញពីភូមិឃុំកំណើត ឬភូមិឃុំដែលខ្លួនកំពុងរស់នៅ ដែលជាប់ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់លោកគ្រូអ្នកគ្រូ នឹងត្រូវបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនលោកគ្រូអ្នកគ្រូវិញដើម្បីប្រើប្រាស់ជាសម្ភារៈឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។









***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ គឺត្រូវតែជាគ្រូមុខវិជ្ជាប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង ស្វាយរៀង ត្បូងឃ្មុំ កណ្តាល (ស្រុកមុខកំពូល ល្វាឯម និងខ្សាច់កណ្តាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជាការធ្វើបទសម្ភាសន៍, ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួន។

៤) មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ឯកសារយោង កំណត់គោលដៅសម្រាប់សម្ភាសន៍ ការសម្ភាសន៍ វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរពីកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុកនិងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរចេញពីភូមិកំណើតរបស់ខ្លួន តាមអសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីម៉ែល truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ ០១២ ៦៩៦ ៩៦១ ឬអ៊ីម៉ែល truthrasy.p@dccam.org ។

# អតីតយោធាខ្មែរក្រហម ដែលបានអមដំណើរ ប៉ុល ពត យកទៅកាត់ទោស បានស្លាប់យ៉ាងស្ងៀមស្ងាត់ដោយសារជំងឺ នៅស្រុកអន្លង់វែង

សន ផាត អតីតយោធាខ្មែរក្រហមដែលបានអមដំណើរ ប៉ុល ពត យកទៅកាត់ទោស នៅឆ្នាំ១៩៩៧ បានស្លាប់ដោយជំងឺយ៉ាងស្ងៀមស្ងាត់នៅគេហដ្ឋាន ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨។ សន ផាត គឺជាអតីតយោធាខ្មែរក្រហមមួយរូប ក្នុងចំណោមយោធាខ្មែរក្រហមពីររូបដែលបានអមដំណើរ និងគ្រា ប៉ុល ពត យកទៅកន្លែងកាត់ទោស ស្ថិតនៅលើខ្នងភ្នំដងរែក ក្នុងស្រុកអន្លង់វែង ដែលជាអតីតមូលដ្ឋានតស៊ូចុងក្រោយរបស់កងកម្លាំងខ្មែរក្រហមដែលស្មោះស្ម័គ្រនឹង តាម៉ុក។ គ្រួសារ និងមិត្តភក្តិរបស់ សន ផាត បានឲ្យដឹងថា ខាងលើនេះ គឺជាកិច្ចការសំខាន់របស់ ផាត ដែលបានធ្វើក្នុងអំឡុងពេលរបបខ្មែរក្រហម។ ទោះបីយ៉ាងណា អ្នកទាំងនេះនៅតែមានភាពស្ទាក់ស្ទើរ និងភ័យខ្លាចក្នុងការបង្ហាញពីប្រវត្តិច្បាស់លាស់របស់ សន ផាត ក្នុងអំឡុងពេលចូលរួមជាមួយចលនាបដិវត្តន៍ខ្មែរក្រហម តួនាទី និងវត្តមាននាពេលកាត់ទោស ប៉ុល ពត ដោយតុលាការប្រជាជននៅស្រុកអន្លង់វែង។

ប៉ុល ពត ត្រូវបាន តាម៉ុក ចោទប្រកាន់ថា បានរៀបចំគម្រោងផែនការ និងបានបញ្ជាឲ្យយោធាសម្លាប់ សុន សេន អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងគ្រួសារ នៅក្នុងស្រុកអន្លង់វែង។

ប៉ុល ពត បានរត់គេចពីកងកម្លាំងរបស់ តាម៉ុក ទៅលាក់ខ្លួននៅក្នុងរូងភ្នំមួយ នៅក្នុងឃុំអូរស្វាយ ស្រុកត្រពាំងប្រសាទ។ កងយោធាមួយចំនួនដែលរត់ភៀសខ្លួន និងតាមការពារ ប៉ុល ពត គឺជាអតីតយោធារបស់ តាម៉ុក។ ដោយសារអស់សង្ឃឹមថានឹងបានទទួលជោគជ័យ កងយោធាទាំងនោះចាប់ផ្តើមរត់ចោល ប៉ុល ពត។ ក្រោយមក កងយោធារបស់ តាម៉ុក បានរកឃើញកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត។ កងយោធារបស់តាម៉ុកបានចូលទៅដល់រូងភ្នំ ហើយបាននិយាយទៅកាន់ ប៉ុល ពត ដោយសម្តីសុភាពរាបសាថា «យើងសុំអញ្ជើញអ៊ំ [ប៉ុល ពត] ត្រឡប់ទៅវិញ តា [តាម៉ុក] ចង់ជួបអ៊ំ»។ ប៉ុល ពត ត្រូវបានចាប់ខ្លួនដោយយោធារបស់ តាម៉ុក នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៧។ យោធារបស់ តាម៉ុក បានសែង ប៉ុល ពត ត្រឡប់មកវិញ។

នៅថ្ងៃទី២៥ ខែកក្កដា ប៉ុល ពត ត្រូវបានកាត់ទោសនៅចំពោះមុខ «តុលាការប្រជាជន» នៅអំឡុងពេលដែលខ្លួនកំពុងមានបញ្ហាសុខភាពជាច្រើនរួចទៅហើយ ដែលរួមទាំងជំងឺខ្សោយបេះដូង និងលើសឈាមតាំងពីឆ្នាំ១៩៩៥ មកម្ល៉េះ។ នៅពេលនោះ ផ្នែកខាងឆ្វេងនៃដងខ្លួនរបស់ ប៉ុល ពត មិនអាចដំណើរការបានជាប្រក្រតីទេ ហើយភ្នែកខាងឆ្វេងរបស់គាត់ស្ទើរតែងងឹតទៅហើយ។ ប៉ុល ពត អាចដើរមកកន្លែងកាត់ទោសលុះត្រាតែមានជំនួយពី សន ផាត អតីតយោធារបស់ តាម៉ុក និងអ្នកផ្សេងទៀតតាមអម និងគ្រា។

ប៉ុល ពត ស្លាប់នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ដោយសារជំងឺនៅកន្លែងឃុំឃាំងនៅលើភ្នំដងរែក ដែលគ្រប់គ្រងដោយកងកម្លាំងយោធារបស់ តាម៉ុក។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩ តាម៉ុក ក៏ត្រូវបានកងកម្លាំងរបស់រដ្ឋាភិបាលចាប់ខ្លួន ចំណែកកងកម្លាំងរបស់ តាម៉ុក ដែលនៅសេសសល់ទាំងប៉ុន្មានក៏បានធ្វើសមាហរណកម្មជាមួយរដ្ឋាភិបាលកម្ពុជា។ តាម៉ុក ត្រូវបានឃុំឃាំងនៅតុលាការយោធា ក្នុងទីក្រុងភ្នំពេញ រហូតដល់ស្លាប់ដោយចាស់ជរា

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ មួយឆ្នាំមុនពេលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅជាទូទៅថា សាលាក្តីខ្មែរក្រហម ដើម្បីកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហម។

រហូតមកដល់សព្វថ្ងៃ មានជនជាប់ចោទចំនួន ៣នាក់ប៉ុណ្ណោះ រួមមាន កាំង ហ្គេចអ៊ាវ ហៅ ឌុច, នួន ជា និង ខៀវ សំផន ដែលត្រូវបានរកឃើញថាមានពិរុទ្ធ និងកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ខណៈពេលដែលជនជាប់ចោទ ៣នាក់ទៀត ខកខានមិនបានកាត់ទោសដូចជា អៀង សារី បានស្លាប់មុនពេលតុលាការកាត់ទោស និង អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមានជំងឺវង្វេងស្មារតី ហើយមិនអាចចូលរួមក្នុងសវនាការបាន និងបានស្លាប់បន្ទាប់មក។ ចំណែករឿងក្តីរបស់ អ៊ឹម ចែម អតីតគណៈស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ដែលបច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង កំពុងស្ថិតនៅក្នុងភាពចម្រូងចម្រាស់រវាង សហចៅក្រមស៊ើបអង្កេត ដែលបានលើកលែងការ ចោទប្រកាន់ដោយសម្អាងទៅលើការខ្វះចន្លោះនីតិវិធី ភ័ស្តុតាំង និងការពន្យាពេលដោយមិនសមស្រប និងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានប្តឹងទៅអង្គបុរេជំនុំជម្រះ ដើម្បីជំទាស់ទៅការលើកលែងការចោទប្រកាន់នេះ។

ទោះបីរបបខ្មែរក្រហមបានដួលរលំទៅជាង៣០ឆ្នាំមកហើយ ហើយតុលាការបានកំណត់អត្តសញ្ញាណអ្នកដែលនឹងត្រូវចោទប្រកាន់រួចហើយក្តី ក៏រហូតមកដល់សព្វថ្ងៃនេះ អតីតយោធា និងកម្មាភិបាលខ្មែរក្រហមមួយចំនួននៅតំបន់អន្លង់វែង នៅតែមិនចង់និយាយ និងបង្ហាញពីអត្តសញ្ញាណរបស់ខ្លួនដែលជាប់ទាក់ទងនឹងរបបខ្មែរក្រហមដដែល។

***សោម ប៊ុនថន***



*សន ផាត អតីតយោធាខ្មែរក្រហម បានស្លាប់ដោយសារជំងឺនៅថ្ងៃទី២៨ កក្កដា ឆ្នាំ២០១៨ ក្នុងស្រុកអន្លង់វែង*

# មិនដឹងថាខ្មែរក្រហម បង្អត់បាយ វាយធ្វើបាប ចាប់ខ្លួន និងកាប់សម្លាប់ប្រជាជន

ទាវ តឿម អាយុ៦០ឆ្នាំ បានមានប្រសាសន៍ថា គាត់ជាអតីតយោធាខ្មែរក្រហម បច្ចុប្បន្នរស់នៅឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ គាត់ត្រូវបានអង្គភាពយោធាបញ្ជូនឲ្យទៅការពារព្រំដែនកម្ពុជា ស្ថិតនៅក្នុងខេត្តស្វាយរៀង ភូមិភាគបូព៌ា។ តឿម បានឲ្យដឹងថា «គាត់បានវាយប្រយុទ្ធតទល់ជាមួយវៀតណាមយ៉ាងស្វិតស្វាយនៅតាមបណ្តោយព្រំដែន ចំណែកកងទ័ពវៀតណាមក៏តស៊ូ ប្តូរផ្តាច់ និងប្តូរជីវិតក្នុងសង្គ្រាមនេះដែរ»។ ដូច្នេះរាល់ពេលឡើងទៅប្រយុទ្ធនៅសមរភូមិម្តងៗ តឿម មិនដែលសង្ឃឹមថា បាននៅរស់ជីវិតរហូតមកដល់សព្វថ្ងៃឡើយ។ តឿម ស្ថិតនៅក្នុងសម្លៀកបំពាក់ជាប្រជាជនសាមញ្ញ មាឌតូច និងទឹកមុខមាំ បានបន្ថែមថា«គាត់បានចូលរួមជាមួយបដិវត្តន៍ខ្មែរក្រហម តាំងពីឆ្នាំ១៩៧២ បន្ទាប់ពីគាត់ឈប់រៀននៅថ្នាក់ទី៣ពីសាលាឫស្សីលក ព្រោះចាប់ពីអន្លង់ ស្វាយធំ រហូតដល់ភូមិកំណើតរបស់គាត់នៅស្រុកជីក្រែង ខេត្តសៀមរាប ត្រូវបានកងកម្លាំងបដិវត្តន៍ខ្មែរក្រហមរំដោះបានទាំងស្រុងហើយ»។ ខាងក្រោមជាការរៀបរាប់របស់ ទាវ តឿម៖

នៅអំឡុងឆ្នាំ១៩៧២ ម្តាយរបស់ តឿម បានស្ម័គ្រចិត្តបញ្ជូន តឿម ឲ្យទៅរស់នៅជាមួយបដិវត្តន៍ខ្មែរក្រហម ខណៈដែលកម្មាភិបាលខ្មែរក្រហមមក ពីមន្ទីរយុវជនក្នុងសង្កាត់ឫស្សីលក ឈ្មោះ ហួយ ដើរជ្រើសរើសយុវជននៅក្នុងភូមិ។ ពេលចូលដំបូងនៅឆ្នាំ១៩៧២ តឿម បានស្នាក់នៅជាមួយក្រុមយុវជនសរុបប្រមាណ២០នាក់ នៅមន្ទីរយុវជនភូមិឫស្សី-ខ្លាច់ ដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ឫស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប។ បន្ទាប់មក ប្រធានមន្ទីរយុវជនបានហៅយុវជនមកប្រជុំប្រាប់ពីការងារដែលត្រូវបំពេញ និងបែងចែកយុវជនទៅតាមក្រុមតូចៗ ដោយមួយក្រុមមានសមាជិក១០នាក់ ឲ្យចេញទៅត្រាយព្រៃធ្វើចម្ការ និងកាប់ដីដាំដំឡូង។ ក្រៅពីធ្វើចម្ការ តឿម រួមជាមួយសមាជិកក្នុងមន្ទីរយុវជនឫស្សីខ្លាច់ បានភ្ជួររាស់ ដក ស្ទូង និងច្រូតកាត់ស្រូវដើម្បីទុកហូបនៅក្នុងមន្ទីររបស់ខ្លួន ដោយមិនចាំបាច់សុំពីខាងសហករណ៍ ឬប្រជាជន។

តឿម បានរំឭកថា នៅពេលចេញទៅធ្វើការ ហើយបានដើរកាត់ផ្លូវក្នុងភូមិម្តងៗ គាត់តែងឆ្លៀតចូលលេងឪពុកម្តាយ និងបងប្អូននៅផ្ទះ។ តឿម ក៏អាចស្នាក់នៅផ្ទះបានដែរនៅពេលគាត់ធ្វើការងាររួចតាមផែនការ ដោយអង្គការមិនបានហាមឃាត់ឡើយ។ តឿម បានបន្តថា ជាញឹកញាប់ខាងសង្កាត់ និងខាងស្រុកចុះមកប្រជុំ និងណែនាំការងារដល់មន្ទីរយុវជន។

បន្ទាប់ពីយោធាខ្មែរក្រហមទទួលជ័យជម្នះនៅខែមេសា ឆ្នាំ១៩៧៥ ភ្លាម អង្គភាពយោធាមកពីភ្នំពេញបានមកជ្រើសរើស តឿម រួមជាមួយយុវជនមួយចំនួនទៀតនៅក្នុងមន្ទីរយុវជននៅភូមិឫស្សីខ្លាច់ និងក្នុងតំបន់ផ្សេងៗទៀត ក្នុងខេត្តសៀមរាប សរុបទាំងអស់៤០០នាក់ឲ្យចូលបម្រើយោធា។ នៅដើមខែ៦ ឆ្នាំ១៩៧៥ តឿម ត្រូវបានអង្គភាពយោធាបញ្ចូលក្នុងកងពល៤៥០ ព្រោះកម្លាំងចាស់មួយចំនួនក្នុងកងពលនេះបានស្លាប់ក្នុងសង្គ្រាម។ កងពល៤៥០ បោះទីតាំងនៅវត្តឃ្មួញ ខាងលិចព្រែកព្នៅ ក្រុងភ្នំពេញ ដោយមាន តាសួង ជាប្រធានកងពល និងមិនឃើញមានប្រជាជនរស់នៅទេ។ តឿម ត្រូវបានអង្គភាពបែងចែកបន្តឲ្យចូលក្នុងវរសេនាធំ៦១ ដែលមាន តាសំ ជាប្រធាន និងមានសមាជិកប្រមាណ៧០០ ទៅ ៨០០នាក់។ ក្រោយមកអង្គការ បានបញ្ជូនកងវរសេធំរបស់ តឿម មកធ្វើការងារដកស្ទូង នៅ

ស្រុកបារាយណ៍ ខេត្តកំពង់ធំ រយៈពេលមួយវស្សា។ រហូតដល់ចុងឆ្នាំ១៩៧៥ ទើបអង្គការអនុញ្ញាតឲ្យកងរបស់ គឿម ត្រឡប់មកអង្គភាពយោធានៅវត្តឃ្លាញវិញ។

នៅខែមេសា ឆ្នាំ១៩៧៦ អង្គការបានចោទប្រកាន់អង្គភាពយោធារបស់ គឿម ថាជា សេ.អ៊ី.អា រៀបចំបះបោរ ដើម្បីផ្តួលរំលំបក្សកុម្មុយនីស្តកម្ពុជា ហើយបានចាប់ខ្លួនប្រធានក្រុមរបស់ គឿម ឈ្មោះ ហេង មេកងឈ្មោះ ឆោម និង ហាន់ រហូតដល់មេបញ្ជាវរសេនាធំឈ្មោះ គាសំ និងមេកងពល។ គឿម មិនដឹងថា អង្គការយកអ្នកទាំងនោះទៅណាទេ ចំណែកអ្នកដែលមានវ័យចាស់ៗនៅក្នុងអង្គភាពយោធារបស់គាត់មួយចំនួនទៀតក៏បាត់ខ្លួនដែរ។ បន្ទាប់ពីចាប់មេៗយកទៅអស់ អង្គការបានយកយោធាមកពីខាងភូមិភាគនិរតីឈ្មោះ រី ឲ្យមកគ្រប់គ្រងជំនួសវិញ។ គឿម បានមានប្រសាសន៍ថា សំណាងល្អគាត់បានរួចផុតពីការចាប់ខ្លួន ដោយសារគាត់ជាយុទ្ធជនតូចតាច។ នៅឆ្នាំ១៩៧៦ ដដែល អង្គភាពយោធាបានហៅ គឿម រួមទាំងយុទ្ធជនក្មេងៗដែលមានអាយុចាប់ ១៨ឆ្នាំ ដល់២១ឆ្នាំ ចំនួន៦០នាក់មកប្រជុំប្រាប់ថា អង្គការដកឲ្យទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំង។ គឿម មានការងឿងឆ្ងល់យ៉ាងខ្លាំងដោយសារគាត់មិនធ្លាប់ធ្វើកិច្ចការនេះពីមុនមក។ គឿម បានទៅដេកនៅទីរួមខេត្តកំពង់ឆ្នាំងមួយយប់ ហើយនៅព្រឹកថ្ងៃបន្ទាប់អង្គភាពយោធា ក៏បានរៀបចំបែងចែកកម្លាំងតាមក្រុម ដោយមួយក្រុមមានសមាជិក ១០នាក់ ឲ្យធ្វើការងារតាមផ្នែកនីមួយៗ ដូចជា ផ្នែកដាំបង្គោលខ្សែភ្លើង ផ្នែកប្រមូល និងដឹកជញ្ជូនថ្ម និងផ្នែកឈូសដីធ្វើផ្លូវឡើងទៅលើភ្នំ។ បន្ទាប់ពីបែងចែកការងារតាមផ្នែករួច គឿម ឃើញរថយន្តរបស់ចិនបានមករង់ចាំទទួលរួចជាស្រេចដូច្នេះ អង្គភាពយោធាក៏បានចាត់តាំងឲ្យក្រុមនីមួយឡើងជិះរថយន្ត។ គឿមបានធ្វើការជាមួយចិនប៉ុន្តែការងារធ្ងន់ៗចិនមិនបានប្រើគាត់ឲ្យធ្វើឡើយ គឺយកគ្រឿងចក្រមកប្រើជំនួសវិញ។ ចិនបានប្រើរំសេវដើម្បីបំបែកយកថ្ម និងប្រើរថយន្ត គ្រឿងចក្រសម្រាប់ចូក ឈូស រុញ និងដឹកជញ្ជូនថ្ម និងដីសម្រាប់ចាក់ក្រាលធ្វើផ្លូវ។ គឿម បានធ្វើការងារស្រាលៗ ដូចជា តម្រៀបថ្មធ្វើជើងទេរតាមផ្លូវឡើងទៅលើភ្នំ និងដើរប្រមូលថ្ម ដែលខ្ទាតចេញពីផ្លូវនៅពេលរថយន្តដឹកមកចាក់និងនៅពេលគ្រឿងចក្រឈូសឆាយ។ ចិនបានរៀបចំដំឡើងអង់តែននៅលើភ្នំ ដើម្បីតាមសកម្មភាពយន្តហោះដែលហោះឆ្លងកាត់ប្រទេសកម្ពុជា។ ជនជាតិចិនដែលជាមេការរបស់ គឿម មានអ្នកបកប្រែភាសាម្នាក់នៅជាមួយ ហើយនៅពេលចង់ប្រើក្រុមរបស់ គឿម ឲ្យធ្វើអ្វីមួយ គឺប្រាប់ទៅតាមរយៈអ្នកបកប្រែពីភាសាចិនមកខ្មែរ។ ជនជាតិចិនទាំងនោះមិនបានស្នាក់នៅជាមួយកងរបស់ គឿម នៅព្រលានយន្តហោះទេ គឺត្រឡប់មកស្នាក់នៅទីរួមខេត្តកំពង់ឆ្នាំងវិញ ដែលមានចម្ងាយប្រមាណជាង២០គីឡូម៉ែត្រពីការដ្ឋាន។ គឿម ធ្វើការងារនៅការដ្ឋានព្រលានយន្តហោះដោយមិនមានការបង្ខិតបង្ខំឡើយ។ ចំពោះអ្នកមានជំងឺមិនអាចចេញទៅធ្វើការងារបាន ត្រូវសុំច្បាប់អង្គភាពយោធាដើម្បីឈប់សម្រាក ហើយប្រសិនបើឈឺធ្ងន់ ខាងអង្គភាពយោធា បានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ចំណែករបបអាហារ បន្ទាប់ពីធ្វើការងារ និងដល់ម៉ោងឈប់សម្រាក គឿម និងសមាជិកក្រុមការងារគ្រាន់តែនាំគ្នាទៅលាងដៃរួចមកហូបបាយ ដោយមានខាងចុងភៅចម្អិនរួចជាស្រេច។ នៅម៉ោង១រសៀល គឿម និងសមាជិកទាំងអស់ក៏ចាប់ផ្តើមចុះធ្វើការងារបន្តទៀត។ គឿម បានសង្កេតឃើញនៅការដ្ឋានព្រលានយន្តហោះ គឺមានគ្រឿងចក្រជាច្រើនគ្រឿង ដូចជា គ្រឿងចក្រសម្រាប់លើកដាក់ឈូសដី ចូកដី កិនបង្ហាប់ដីធ្វើផ្លូវ ចំណែកអ្នកបើកបរសុទ្ធសឹងជាជនជាតិខ្មែរ។ រាល់ពេល គឿម ចេញទៅធ្វើការម្តងៗគឺមានឡានចិនមកចាំដឹកចេញទៅ និងដឹកត្រឡប់មកវិញ។ កម្មករខ្មែរ ដែលធ្វើការនៅការដ្ឋានព្រលានយន្តហោះនៅពេលនោះ មានចំនួនច្រើន ហើយជនជាតិចិនដែលសុទ្ធសឹងជាមេការ ក៏មានចំនួនច្រើនដែរ។ នៅក្នុងកងរបស់ គឿម មានសមាជិកសរុប៦០ ដែលមានប្រធានកងឈ្មោះ រី គ្រប់គ្រងដដែល។ រី បានប្រាប់ គឿម ពីមូលហេតុដែលអង្គការមក

សង់ព្រលានយន្តហោះថ្មីនៅខេត្តកំពង់ឆ្នាំងថា ដោយសារទីតាំងនេះស្ថិតនៅចំណុចកណ្តាលប្រទេសកម្ពុជា ហើយបន្ទាប់ពីសាងសង់រួចរាល់ អង្គការនឹងប្តូរព្រលានយន្តហោះពីភ្នំពេញ មកកំពង់ឆ្នាំងវិញ។

តឿម បានធ្វើការនៅព្រលានយន្តហោះកំពង់ឆ្នាំង រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ ក៏ត្រូវបានអង្គភាពយោធាបញ្ជូនគាត់ឲ្យទៅឈរជើងនៅស្រុកប្រសូត្រ ស្រុកចន្ទ្រា និងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ តឿម ស្ថិតនៅកងវរសេនាធំលេខ៦១ ដែលមានប្រធានឈ្មោះ តាលី និងប្រធានកងពល៨០៥ ឈ្មោះ តាផន មកពីខាងភូមិភាគនិរតីជាអ្នកគ្រប់គ្រង។ កងវរសេនាធំ៦១របស់ តឿម ត្រូវឡើងទៅត្រៀម និងចល័តនៅតាមខ្សែបន្ទាត់ព្រំដែនចាប់ពី ឃួនគៀង ដាប្ញស្សី និង តានូ ក្នុងទឹកដីប្រទេសកម្ពុជា។ តឿម បានរៀបរាប់ថា ដោយសារកងពល៨០៥ ជាកងរបស់មជ្ឈិម ទើបរៀងរាល់មួយសប្តាហ៍ ឬ មួយខែម្តង គាត់ឃើញ សុន សេន ចុះមកពិនិត្យមើលខ្សែត្រៀម និងកងកម្លាំងយោធានៅសមរភូមិ និងមើលការលំបាករបស់កម្លាំងយោធាដោយផ្ទាល់ ហើយបានចាត់តាំងឲ្យកងដឹកជញ្ជូនដឹកត្រីសាច់ បន្លែបង្កា មកផ្តល់ឲ្យកងយោធាហូបដើម្បីបំប៉នសុខភាព។

សមរភូមិដែល តឿម ឡើងទៅវាយប្រយុទ្ធជាមួយវៀតណាមខ្លាំងក្លា គឺនៅសមរភូមិតានូ និងនៅសមរភូមិក្នុងស្រុកចន្ទ្រា តាមបណ្តោយថ្នល់ជាតិ។ រាល់ពេលវាយប្រយុទ្ធម្តងៗ កងកម្លាំងទាំងសងខាងបានស្លាប់ និងរងរបួស និងមានសាកសពកងទ័ពទាំងសងខាងនៅសមរភូមិ។ នៅពេលខ្លះ កងយោធាខ្មែរក្រហមបានវាយចូលដល់ភូមិវេញទ្រីត្រឡោងខុស ក្នុងដីវៀតណាម ដែលចម្ងាយពីរគីឡូពីបន្ទាត់ព្រំដែន


ទាវ តឿ អាយុ ៦០ ឆ្នាំ សព្វថ្ងៃរស់នៅក្នុងឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

និងបានឈរជើងនៅទីនោះរយៈពេលមួយទៅពីរថ្ងៃទៀតផងៗ នៅពេលគាត់វាយចូលដល់ក្នុងភូមិរបស់វៀតណាម តឿម មិនឃើញមានប្រជាជនរស់នៅទេ គឺមានតែទីតាំងស្នាក់ការរបស់កងទ័ពវៀតណាមតែប៉ុណ្ណោះៗ ប៉ុន្តែ ជាញឹកញាប់ កងទ័ពវៀតណាមបានវាយបណ្តេញយោធាខ្មែរក្រហមចេញមកវិញ និងតែងទទួលជ័យជម្នះនៅលើសមរភូមិៗ

តឿម បានចាំថា នៅវេលាម៉ោង៧យប់ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៨ គាត់ត្រូវកងទ័ពវៀតណាមបាញ់ឲ្យរងរបួសនៅត្រង់ដៃ នៅក្នុងភូមិបួន ក្នុងទឹកដីវៀតណាម ជាប់នឹងភូមិតានូ ក្នុងស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ប្រទេសកម្ពុជា នៅពេលដែលគាត់ព្យាយាមចូលទៅអូសយកមិត្តភក្តិរបស់គាត់ម្នាក់ដែលរងរបួសនៅសមរភូមិៗ តឿន ត្រូវបានអង្គភាពយោធាបញ្ជូនមកព្យាបាលនៅពេទ្យ៣-៩៨ (ពេទ្យ៦មករា) ក្នុងក្រុងភ្នំពេញរហូតជាសះស្បើយ ទើបគាត់ត្រឡប់ទៅអង្គភាពយោធារបស់គាត់ក្នុងខេត្តស្វាយរៀងវិញៗ ប៉ុន្តែ អង្គភាពយោធារបស់គាត់បានចាត់តាំងគាត់ឲ្យស្នាក់នៅអង្គភាពយុទ្ធជនពិការ ស្ថិតនៅភូមិបាសាក់ ខាងកើតក្រុងស្វាយរៀង រយៈពេលបីខែសិន ទើបបញ្ជូនគាត់ឲ្យទៅត្រៀមវាយជាមួយវៀតណាមនៅសមរភូមិបន្តទៀតៗ

នៅពេលវាយប្រយុទ្ធតទល់នឹងកងទ័ពវៀតណាមម្តងៗ កម្មាភិបាលខ្មែរក្រហមនៅមូលដ្ឋាន និងតំបន់បានកៀរប្រជាជនដែលរស់នៅតាមបណ្តោយព្រំចេញទាំងអស់ និងមិនអនុញ្ញាតឲ្យនៅជិតទីតាំងយោធាឡើយៗ នៅពេលខ្លះយោធាខ្មែរក្រហមក៏ចាប់បានកងទ័ពវៀតណាមចំនួន២-៣នាក់ក្នុងពេលប្រយុទ្ធគ្នាម្តងៗ តឿម បានអះអាងថា ខាងថ្នាក់លើរបស់គាត់មិនអនុញ្ញាតឲ្យប៉ះពាល់ សួរចម្លើយ ឬវាយធ្វើបាបកងទ័ពវៀតណាមទាំងនេះទេ គឺឲ្យរក្សាទុកៗ បន្ទាប់មក តឿម បានឃើញរថយន្តរបស់អគ្គសេនាធិការមកដឹកកងទ័ពវៀតណាមទាំងនោះមកភ្នំពេញបាត់ ប៉ុន្តែគាត់មិនដឹងថា ខាងអគ្គសេនាធិការដឹកកងទ័ពវៀតណាមទាំងនោះទៅដាក់នៅទីណាទេៗ

បន្ទាប់ពីមានការវាយប្រយុទ្ធគ្នាកាន់តែខ្លាំង នៅចុងឆ្នាំ១៩៧៨ វាំងយោធាខ្មែរក្រហម និងកងទ័ពវៀតណាម ខាងមជ្ឈិមក៏បានបញ្ជូនយោធាទៅបន្ថែមទៀតដែរៗ ប៉ុន្តែ កងយោធាទាំងនោះ បានឈរជើងនៅខេត្តស្វាយរៀង បានរយៈពេល១០ថ្ងៃប៉ុណ្ណោះ ក៏ដកចេញមកវិញអស់ៗ កងវរសេនាធំរបស់ តឿម មិនទាន់បានទទួលបានដំណឹងថាកងទ័ពវៀតណាមវាយចូលមកដល់ក្រុងភ្នំពេញនោះទេៗ ដូច្នេះ កងរបស់គាត់នៅបន្តវាយទប់ទល់ជាមួយកងទ័ពវៀតណាមនៅតានូងដែល រហូតកងទ័ពវៀតណាមកាន់កាប់ភ្នំពេញទាំងស្រុងៗ នៅពេលទទួលបានដំណឹងថាវៀតណាមបានជ័យជម្នះ តឿម រួមនឹងសមាជិកកងក៏លែងមានទឹកចិត្តប្រយុទ្ធទៀតដែរ ហើយគាត់ និងមិត្តភក្តិក៏បានរត់គេចចេញពីសមរភូមិ ឆ្លងកាត់អ្នកលឿង សំដៅទៅខេត្តកំពង់ស្ពឺៗ តឿម និងមិត្តភក្តិឈ្មោះ ប៊ុន និង ថេត បានរត់បែកបាក់គ្នានៅម្តុំថ្នល់ព្រៃ ខេត្តកំពង់ស្ពឺ ហើយមកដល់សព្វថ្ងៃ ក៏គាត់មិនដឹងថា មិត្តភក្តិទាំងពីរនាក់របស់គាត់នៅរស់ ឬស្លាប់យ៉ាងណាដែរៗ

ក្រោយមក តឿម បានធ្វើដំណើរទៅខេត្តកំពង់ឆ្នាំង កន្លែងដែលគាត់ធ្លាប់ធ្វើការងារពីមុន និងចូលសារភាពជាមួយវៀតណាមៗ តឿម ត្រូវវៀតណាមឃុំរយៈពេល៣ថ្ងៃ ហើយក្រោយពីត្រូវបានដោះលែង គាត់ក៏សម្រេចចិត្តត្រឡប់មករស់នៅស្រុកកំណើតក្នុងស្រុកជីក្រែង ខេត្តសៀមរាបវិញៗ នៅឆ្នាំ២០០០ តឿម ក៏បាននាំប្រពន្ធ និងកូនមករស់នៅឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យរហូតមកដល់សព្វថ្ងៃៗ

តឿម បានមានប្រសាសន៍ថា ចាប់តាំងពីគាត់ចាកចេញពីស្រុកកំណើតនៅឆ្នាំ១៩៧៥ គាត់មិនដែលបានត្រឡប់ទៅលេងស្រុកកំណើតទេ ហើយនៅខាងមូលដ្ឋាន គាត់ក៏មិនបានដឹងថា «ខ្មែរក្រហមបង្អត់បាយ វាយធ្វើបាប ចាប់ខ្លួន និងកាប់សម្លាប់ប្រជាជនដែរ ព្រោះគាត់នៅ ចាំត្រៀមប្រយុទ្ធនៅលើសមរភូមិប៉ុណ្ណោះៗ គាត់បានដឹងរឿងរ៉ាវទាំងនេះក្រោយពេលរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩»ៗ ***សោម ប៊ុនថន***

# ភាពមិនប្រក្រតីនៃប្រព័ន្ធយុត្តិធម៌

## សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទៅលើដីកាដំណោះស្រាយរបស់សំណុំរឿង០០៤/១

នៅក្នុងឆ្នាំ២០០៣ កិច្ចព្រមព្រៀងមួយរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ត្រូវបានចុះហត្ថលេខា ដើម្បីបង្កើតឲ្យមានតុលាការខ្មែរក្រហមសម្រាប់កាត់ក្តីអតីតសមាជិកនៃរបបខ្មែរក្រហម ដែលជារបបដ៏ឃោរឃៅមួយបានឡើងកាន់អំណាចចាប់ពីខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវដួលរលំនៅក្នុងខែមករា ឆ្នាំ១៩៧៩។ ជាលទ្ធផលរបបនេះបាន បណ្តាលឲ្យមនុស្សប្រហែលជាង១,៧លាននាក់ស្លាប់បាត់បង់ជីវិត។ តុលាការនេះ ត្រូវបានដាក់ឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការខ្មែរក្រហម ដែលបានកម្រិតយុត្តាធិការយ៉ាងច្បាស់លាស់ ថាតើនរណាខ្លះត្រូវនាំយកមកកាត់ទោស។ តុលាការខ្មែរក្រហម បានកំណត់យកតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬអតីតកម្មាភិបាលខ្មែរក្រហមដែលទទួលខុសត្រូវខ្ពស់បំផុត ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ។ ដោយសារតែ ដែនកំណត់នៃវិសាលភាពរបស់តុលាការខ្មែរក្រហមមានលក្ខណៈតូចចង្អៀត និងបានអូសបន្លាយពេលវេលាអស់រយៈពេលយ៉ាងយូរ ចាប់តាំងពីរបបខ្មែរក្រហមបានដួលរលំ ដូច្នេះហើយទើបមានតែកម្មាភិបាលខ្មែរក្រហមចំនួន៩នាក់ ត្រូវបាននាំខ្លួនយកមកកាត់ទោស ដែលក្នុងចំណោមនោះមានកម្មាភិបាលខ្មែរក្រហមចំនួន៣នាក់ទេ ត្រូវបានផ្តន្ទាទោសទៅតាមផ្លូវច្បាប់។ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ពីបទឧក្រិដ្ឋមនុស្សឃាត និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ នៅក្នុងខែធ្នូ ក្នុងឆ្នាំដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានថ្លែងថា ខ្លួនបានពិចារណាទៅលើការច្រានចោលសំណុំរឿងប្រឆាំង អ៊ឹម ចែម លើបទល្មើសព្រហ្មទណ្ឌនានា ដោយមូលហេតុមិនមានយុត្តាធិការបុគ្គល។ សហព្រះរាជអាជ្ញាអន្តរជាតិ បានប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែអង្គបុរេជំនុំជម្រះនៃតុលាការខ្មែរ-ក្រហម បានទទួលយករឿងក្តីនេះដោយបើកឲ្យមានសវនាការ រយៈពេលពីរថ្ងៃលើសំណុំរឿង០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម ចាប់ពីថ្ងៃទី១១ ដល់១២ ខែធ្នូឆ្នាំ២០១៧ ដើម្បីស្តាប់នូវអំណះអំណាងក្នុងសំណុំរឿងនេះ។

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះនៃតុលាការខ្មែរក្រហម បានចេញសេចក្តីពិចារណារបស់ខ្លួនលើពាក្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណុំរឿង០០៤/១។ ឯកសារនេះមាន១៣ទំព័រ និងត្រូវបានបែងចែកជា៨ផ្នែកក្នុងនោះ៦ផ្នែកដំបូងស្តីពីប្រវត្តិនីតិវិធីនិងបញ្ហាបឋម ២ទំព័រចុងក្រោយស្តីពីយោបល់របស់ចៅក្រមជាតិ និងអន្តរជាតិ។ អង្គបុរេជំនុំជម្រះផ្ទាល់មានចៅក្រមចំនួន៥រូប ដែលចៅក្រមចំនួន៣រូបជាចៅក្រមជាតិ និង២រូបទៀតជាចៅក្រមអន្តរជាតិ ហើយការអនុម័តលើសេចក្តីសម្រេចទាំងឡាយរបស់សហចៅក្រមស៊ើបអង្កេតគឺត្រូវការសំឡេងគាំទ្រផ្អែកទៅតាមមតិភាគច្រើនរបស់ចៅក្រមគឺ ចៅក្រមបួនរូបក្នុងចំណោមចៅក្រមទាំងប្រាំរូបត្រូវតែយល់ព្រមនៅក្នុងពេលតែមួយ។

នៅក្នុងផ្នែកដែលឈានទៅដល់ការបែងចែកអំពីយោបល់និងការសម្រេចចិត្តរបស់ចៅក្រម អង្គបុរេជំនុំជម្រះ ក៏មានមតិឯកច្ឆន្ទទៅលើការខ្វះចន្លោះនៃនីតិវិធីមួយចំនួន និងទៅលើផ្នែកដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងលើវិធីសាស្ត្រនិងដំណើរការរបស់ខ្លួន។ អង្គបុរេជំនុំជម្រះបាន

រកឃើញថា អង្គជំនុំជម្រះសាលាដំបូងបានចំណាយពេលមិនសមស្របក្នុងការផ្ញើសំណុំរឿងទៅឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដោយចំណាយពេល៦ខែ បន្ទាប់ពីការស្នើសុំការស៊ើបអង្កេតលើកចុងក្រោយត្រូវបានច្រានចោល ដែលផ្ទុយពីវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម ដែលបានចែងថា ព័ត៌មានទាំងអស់ត្រូវបញ្ជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិក្នុងរយៈពេល ២ថ្ងៃ បន្ទាប់ពីចេញដីកាដំណោះស្រាយ។ បន្ទាប់ពីមានភាពយឺតយ៉ាវនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចំណាយពេល១៨ខែ ដើម្បីចេញដីកាដំណោះស្រាយសំអាងហេតុ ដែលអង្គបុរេជំនុំជម្រះបានកំណត់ថាវាជា «ការពន្យាពេលជ្រុលហួសហេតុ» ដោយបានបញ្ជាក់ថាដីកាដំណោះស្រាយសម្រាប់សំណុំរឿង០០១ និង០០២ ត្រូវបានចេញនៅក្នុងរយៈពេល៣ទៅ៨ខែ។ ម្យ៉ាងទៀត ដោយកត់សម្គាល់ឃើញថា សេចក្តីសម្រេចចិត្តរបស់ចៅក្រមទៅលើការចោទប្រកាន់ អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤/០១ ទៅលើការចេញដីកាដំណោះស្រាយ ដោយមានការខ្វែងយោបល់ពីរផ្សេងគ្នា រវាងការច្រានចោលផ្នែកនៃសេចក្តីសម្រេច និងការចេញសំអាងហេតុសម្រាប់ដីកាដំណោះស្រាយ ដែលពុំធ្លាប់មានពីមុនមក និងមិនបានផ្តល់ជាប្រយោជន៍ដល់ភាគីពាក់ព័ន្ធណាមួយទេ។

អង្គបុរេជំនុំជម្រះបានរកឃើញពីការខ្វះចន្លោះនៃនីតិវិធីរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងការកំណត់ភ័ស្តុតាង។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា យោងតាមវិធានច្បាប់ផ្ទៃក្នុងរបស់តុលាការខ្មែរក្រហម សហចៅក្រមស៊ើបអង្កេតមិនអាចសម្រេចបានថាតើភ័ស្តុតាងណាខ្លះអាចទុកចិត្តបាន ឯកសារណាអាចមានតម្លៃជាភ័ស្តុតាង និងស្តង់ដារនៃភ័ស្តុតាងឡើយ។ យោងទៅតាម«គោលការណ៍នៃសេរីភាពក្នុងការដាក់ជូនភ័ស្តុតាង» នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលភ័ស្តុតាងទាំងអស់អាចទទួលយកបាន និងមានតម្លៃជាភ័ស្តុតាងស្មើគ្នា ប៉ុន្តែអង្គបុរេជំនុំជម្រះ បានរកឃើញថា សហចៅក្រមស៊ើបអង្កេត បានបង្កើតស្តង់ដារនៃភ័ស្តុតាងដោយខ្លួនឯង។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតបានចាត់ទុកថា របាយការណ៍ដែលបានផ្តល់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មិនអាចទុកចិត្តបាន និងមិនសូវមានតម្លៃជាលក្ខណៈភ័ស្តុតាងឡើយ។ វាដូចគ្នាទៅនឹងភ័ស្តុតាងដែលបានប្រមូល និងស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ ខណៈពេលការិយាល័យរបស់ខ្លួន ទទួលបានរបាយការណ៍ និងសន្មតថាអាចទុកចិត្តបាន។ អង្គបុរេជំនុំជម្រះ បានចាត់ទុកថាហេតុការណ៍នេះគឺជា «កំហុសឆ្គងផ្នែកច្បាប់»។

អង្គបុរេជំនុំជម្រះបានរកឃើញថា វានឹងមានការប៉ះពាល់ជាពិសេសនៅពេលដែលធ្វើការដោះស្រាយជាមួយនឹងអ្នកដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារអង្គបុរេជំនុំជម្រះ មិនអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការសន្មត អំពីភាពជឿទុកចិត្តលើពាក្យបណ្តឹងទាំងអស់ ហើយអង្គបុរេជំនុំជម្រះបានលើកឡើងថា«តុលាការខ្មែរក្រហមគឺជាតុលាការដំបូង ដែលព្យាយាមកាត់ទោសលើឧក្រិដ្ឋកម្មអន្តរជាតិដ៏ធំមួយ ហើយផ្តល់ឱកាសឲ្យជនរងគ្រោះចូលរួមដោយផ្ទាល់ក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី»។ អង្គបុរេជំនុំជម្រះក៏បានបន្តថា ប្រសិនបើសហចៅក្រមស៊ើបអង្កេត បានរកឃើញថាពាក្យបណ្តឹងទាំងអស់មិនអាចទុកចិត្តបាន សហចៅក្រមស៊ើបអង្កេត នឹងត្រូវពិនិត្យមើលឡើងវិញរាល់ពាក្យបណ្តឹងទាំងអស់ដែលតាំងខ្លួនជាសាក្សីផ្ទាល់ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីជាព័ត៌មានដំបូងបង្អស់ ដែលមានសារសំខាន់បំផុតសម្រាប់តុលាការ។ បើមិនដូច្នេះ សហចៅក្រមស៊ើបអង្កេត នឹងដាក់កម្រិតលើលទ្ធភាពរបស់ជនរងគ្រោះចូលរួមក្នុងតុលាការ ដែលវាជាការប្រឆាំងនឹងគោលការណ៍យុត្តិធម៌ និងមូលដ្ឋាននៃការអនុវត្តយុត្តិធម៌របស់អង្គការសហប្រជាជាតិ។

ក្រៅពីការមិនសូវផ្តល់តម្លៃចំពោះរបាយការណ៍ ដែលបានផ្តល់ដោយអង្គការ និងការិយាល័យផ្សេងៗទៀត ព្រមទាំងរបាយការណ៍ពីដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតក៏មិនសូវឲ្យតម្លៃទៅលើសេចក្តីថ្លែងការណ៍របស់

ចុងចោទផ្ទាល់ និងអង្គការមួយចំនួនដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា អង្គការយុវសន្តិភាព និង Smiling Toad Productions ដែរ។ អង្គបុរេជំនុំជម្រះ បានលើកឡើងពីបញ្ហានេះដោយបញ្ជាក់ម្តងទៀតថា សហចៅក្រមស៊ើបអង្កេតមិនមានលទ្ធភាពក្នុងការកំណត់ទៅលើកម្រិតនៃភាពទុកចិត្ត ឬតម្លៃនៃភ័ស្តុតាងបានទេ ហើយប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនទុកចិត្តទៅលើទិន្នន័យរបស់អង្គការដូចដែលបានរៀបរាប់ខាងលើ សហចៅក្រមស៊ើបអង្កេត គួរតែចុះប្រមែប្រមូលសក្ខីកម្មពីជនជាប់ចោទដោយខ្លួនឯង ប៉ុន្តែសហ-ចៅក្រមស៊ើបអង្កេតមិនធ្លាប់បានធ្វើបែបនោះទេ។ នៅក្នុងសេចក្តីបញ្ចប់ការសួរដេញដោលទៅលើភ័ស្តុតាង អង្គបុរេជំនុំជម្រះបានថ្លែងថា ស្តង់ដារនៃភ័ស្តុតាងនៅដំណាក់កាលស៊ើបអង្កេតគឺទាបជាងដំណាក់កាលជំនុំជម្រះគឺកម្រិតនៃការពិនិត្យពិច័យលើភ័ស្តុតាង ដែលបានអនុវត្តនៅមានកម្រិតទាប ដែលជាមូលហេតុធ្វើឲ្យភ័ស្តុតាងជាច្រើនទៀតត្រូវបានអនុញ្ញាតឲ្យដាក់បញ្ចូល។

ចំពោះផ្នែកចុងក្រោយ ដែលបានសរសេររៀបរាប់រួមគ្នាដោយអង្គបុរេជំនុំជម្រះ ស្តីពីសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតដែលទាក់ទងនឹងដីកាដំណោះស្រាយថា យុត្តិធម៌ ដែលតុលាការខ្មែរក្រហមបានផ្តល់ឲ្យចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហម បានដកចេញយុត្តាធិការពីតុ-លាការជាតិ។ អង្គបុរេជំនុំជម្រះ ចាប់ផ្តើមលើកឡើងពីតួនាទីរបស់តុលាការខ្មែរក្រហម ដែលជាអង្គភាពមួយនៅក្នុងរចនាសម្ព័ន្ធរបស់តុលាការកម្ពុជា ដូច្នេះតុលាការខ្មែរក្រហមមិនមានអំណាចក្នុងការសម្រេចលើយុត្តាធិការរបស់ស្ថាប័នដទៃឡើយ។ ដូច្នេះហើយ ទើបមានការរកឃើញថា សហចៅក្រមស៊ើបអង្កេត បានបំពានទៅលើសេចក្តីប្រកាសរបស់ខ្លួន ប៉ុន្តែក៏បានលើកព្រមគ្នាដែរថាបញ្ហាដែលទាក់ទងទៅនឹងយុត្តាធិ-ការគួតែលើកយកមកពិភាក្សាដើម្បីជាប្រយោជន៍របស់នីតិក្រមនាពេលអនាគត។ អង្គបុរេជំនុំជម្រះ បានបន្តបញ្ជាក់ថា សំណុំរឿងដែលកំពុងស្ថិតនៅក្រោមកម្មសិទ្ធិរបស់តុលាការខ្មែរក្រហមបច្ចុប្បន្ន គឺមិនអាចបញ្ជូនឲ្យតុលាការផ្សេងដោះស្រាយបានទេ ដូចគ្នាទៅនឹងតុលាការកម្ពុជា មិនមានយុត្តាធិការនៅក្នុងឯកសាររបស់តុលាការខ្មែរក្រហម។

មកដល់ចំណុចនេះ អង្គបុរេជំនុំជម្រះបានរកឃើញថា ខណៈពេលអង្គជំនុំជម្រះទាំងមូល បានយល់ស្របទៅលើកំហុសឆ្គងផ្លូវច្បាប់ និងនីតិវិធី ដែលបានប្រព្រឹត្តឡើងដោយសហចៅក្រមស៊ើបអង្កេត តែអង្គបុរេជំនុំជម្រះ មិនបានយល់ស្របទៅលើសាលក្រមចុងក្រោយទេ ដោយចៅក្រមថ្នាក់ជាតិ ៣ រូបគាំទ្រលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៤/១ ប្រឆាំងនឹង អ៊ឹម ចែម ក្នុងខណៈពេលដែលចៅក្រមអន្តរជាតិ ២រូបទៀត មិនយល់ស្របចំពោះដីកាដំណោះស្រាយនោះឡើយ។ ចំពោះមតិរបស់ចៅក្រមជាតិ ដែលមានប្រហែលជាងពីរទំព័រកន្លះបានលើកឡើងថា តុលា-ការពុំមានយុត្តាធិការបុគ្គលទៅលើ អ៊ឹម ចែម នោះទេ ព្រោះ អ៊ឹម ចែម មិនមែនជា «មេដឹកនាំជាន់ខ្ពស់» ហើយក៏មិនមែនជា «អ្នកទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងយោបល់របស់ចៅក្រមជាតិ ក៏បានលើកឡើងពីការខ្វែងគំនិតគ្នាទៅលើបណ្តឹងឧទ្ធរណ៍ រវាងសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ចំពោះការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត។

មតិរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលមានចំនួន១០៥ទំព័រ បានគាំទ្រដល់បណ្តឹងឧទ្ធរណ៍របស់តុលា-ការខ្មែរក្រហមទៅលើដីកាដំណោះស្រាយនោះ។ ចៅក្រមអន្តរជាតិ មើលទៅលើទឡ្ហីករណ៍ទាំង៦ នៃបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយច្រានចោលទឡ្ហីករណ៍១ និងគាំទ្រទឡ្ហីករណ៍ ៥ផ្សេងទៀត (មានការរាប់បញ្ចូលទឡ្ហីករណ៍៥ និង៦)។ នៅក្នុងទឡ្ហីករណ៍ ២បានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតបានបរាជ័យក្នុងការដោះស្រាយលើការចោទប្រកាន់ចំនួន ៥ចំណុច ក្នុងចំណោមការចោទប្រកាន់ទាំងអស់ទៅលើ អ៊ឹម ចែម ដែលក្នុងនោះរួមមាន ១)ការបោសសម្អាតនៅភូមិភាគពាយ័ព្យ ២)

អាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងផ្នែកទី៥ និងទី១៣ ៣ខក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងផ្នែកទី៥ ខក្រិដ្ឋកម្មប្រឆាំងខ្មែរក្រោមក្នុងផ្នែកទី១៣ ៤)ព្រមទាំងខក្រិដ្ឋកម្មផ្សេងៗទៀតដូចជា ការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម ៥)ការធ្វើឲ្យមានការបាត់ខ្លួនទាំងបង្ខំ និងអំពើអមនុស្សធម៌ផ្សេងទៀតៗ ចៅក្រមជាតិពីររូបរបស់អង្គបុរេជំនុំជម្រះគាំទ្រចំណុច១, ៣, និង ៥ នៃទឡ្ហីករណ៍២ ដោយរកឃើញចំណុចទី២ និងទី៤ថា សហចៅក្រមស៊ើបអង្កេតមិនមានការចោទប្រកាន់ទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយក៏មិនមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីភ្ជាប់ អ៊ឹម ចែម ទៅនឹងខក្រិដ្ឋកម្មប្រឆាំងនឹងខ្មែរក្រោម នៅក្នុងផ្នែកទី១៣ឡើយ។

នៅក្នុងទឡ្ហីករណ៍៣ នៃបណ្តឹងឧទ្ធរណ៍ ដែលសហព្រះរាជអាជ្ញាអន្តរជាតិចោទប្រកាន់សហចៅក្រមស៊ើបអង្កេតថាមានកំហុសអង្គច្បាប់ និងអង្គហេតុនៅពេលដែលកំណត់និយមន័យខក្រិដ្ឋកម្ម ការសម្លាប់រង្គាល និងការអនុវត្តនិយមន័យនេះលើការរកឃើញទាំងនោះៗ ចៅក្រមជាតិ បានរកឃើញថាសហចៅក្រមស៊ើបអង្កេតបានបែងចែកមិនត្រឹមត្រូវនូវចេតនា «មុនពេលព្រឹត្តិការណ៍» ហើយប្រសិនបើមិនមានរឿងបែបនេះកើតឡើងសហចៅក្រមស៊ើបអង្កេតអាចនឹងរកឃើញថា អ៊ឹម ចែម មានចេតនាលើការសម្លាប់រង្គាល។ នៅក្នុងទឡ្ហីករណ៍៤ បានចោទប្រកាន់ពីកំហុស ដែលទាក់ទងទៅនឹងការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ចៅក្រមបានរកឃើញថាសហចៅក្រមស៊ើបអង្កេត បានបែងចែកមិនត្រឹមត្រូវនៃសកម្មភាពអមនុស្សធម៌ ដែលនាំឲ្យពួកគេសន្និដ្ឋានមិនត្រឹមត្រូវថាគ្មានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីភ្ជាប់ទៅនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម។

ចុងក្រោយ ចៅក្រមអន្តរជាតិបានភ្ជាប់ទឡ្ហីករណ៍៥ និង ៦ ដែលទឡ្ហីករណ៍ទាំងពីរមានការផ្តោតលើកំហុសអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងតួនាទីរបស់ អ៊ឹម ចែម នៅភូមិភាគនិរតី។ ក្នុងការវាយតម្លៃរបស់ចៅក្រមបានរកឃើញថា សហចៅក្រមស៊ើបអង្កេតបានធ្វើខុសក្នុងការស្វែងរកឲ្យឃើញថា អ៊ឹម ចែម មិនបានកាន់តំណែងជាអ្នកដឹកនាំហើយក៏បានច្រានចោលសេចក្តីថ្លែងការណ៍របស់ចុងចោទផ្ទាល់ ដែលបានសារភាពថាបានកាន់តួនាទីខ្ពស់ជាច្រើនរួមទាំងស្រុកកោះអណ្តែតនិងជាសមាជិកគណៈតំបន់ ១៣។ ការកត់សម្គាល់បន្ថែមទៀតទៅលើ អ៊ឹម ចែម ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ តាម៉ុក គឺជាលេខាភូមិភាគពាយ័ព្យ។

នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតមានកំហុសជាច្រើនៗ នេះជាការប្រកាសអំពីភាពបរាជ័យរបស់សហចៅក្រមស៊ើបអង្កេតចំពោះការទទួលខុសត្រូវអំពីភាពឃោរឃៅ និងវិសាលភាពនៃខក្រិដ្ឋកម្មប្រឆាំងនឹង អ៊ឹម ចែម ដែលនាំឲ្យពួកគេសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជា «មេដឹកនាំជាន់ខ្ពស់» និងជាអ្នកដែលមានការ «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះខក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម ដែលធ្វើឲ្យគាត់ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលក្នុងតុលាការខ្មែរក្រហម។ ក្រុមចៅក្រមជាតិបានប្រឆាំងនឹងសេចក្តីសន្និដ្ឋានរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដោយបញ្ជាក់ថាភ័ស្តុតាងដែលផ្តល់ដោយសហព្រះរាជអាជ្ញាអន្តរជាតិគឺគ្រប់គ្រាន់ដើម្បីចាត់ថ្នាក់ជនជាប់ចោទឲ្យចូលក្នុងយុត្តាធិការបុគ្គលរបស់តុលាការខ្មែរក្រហម។

បើទោះបីជាមានការរកឃើញរបស់ចៅក្រមខាងលើក៏ដោយ ក៏ចៅក្រមជាតិទាំងពីររូប បានឈរនៅខាងភាគីសហចៅក្រមស៊ើបអង្កេត ដែលបណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ ហើយដីការដំណោះស្រាយត្រូវបានធ្វើឡើងៗ ចៅក្រមអន្តរជាតិបានបញ្ចប់មតិរបស់ខ្លួន ដោយការរំឭកឡើងវិញនូវអ្វីដែលតុលារកឃើញពីមុនថា តុលាការកម្ពុជាមានយុត្តាធិការបុគ្គលលើគ្រប់ករណីទាំងអស់ ដែលមិនត្រូវបានជំនុំជម្រះដោយតុលាការខ្មែរក្រហម។ ទោះបីជាបានលើកឡើងថា សំណុំរឿងរបស់ អ៊ឹម ចែម ត្រូវបានបិទដោយសហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏តុលាការជាតិនៅតែអាចកាត់ក្តីចំពោះខក្រិដ្ឋកម្មដែលគាត់បានប្រព្រឹត្តក្នុងរបបខ្មែរក្រហម។

***អាលីសុន វែលខេស***

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ
# របស់មជ្ឈមណ្ឌលឯកសារកម្ពុជា




បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅអគារ H
នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើក ក ម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥
អ៊ីម៉ែល truthchenda.s@dccam.org

# ការបណ្តុះបណ្តាលប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដល់គរុសិស្ស នៅសាលាចំណេះទូទៅ នៅតែមានសារសំខាន់ ទោះមុខវិជ្ជានេះមិនមែនជាមុខវិជ្ជាឯកទេស

*អស់រយៈពេលប្រហែលជាង១ទសវត្សរ៍កន្លងមកហើយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំយុវជន និង កីឡា ដើម្បីអនុវត្តកម្មវិធីសិក្សាគោលស្តីពីការស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដល់គ្រូបង្រៀនផ្នែកប្រវត្តិសាស្ត្រថ្នាក់មធ្យមសិក្សា គរុសិស្សនៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ គរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ សាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន សម្រាប់ឆ្នាំសិក្សាមូលដ្ឋាននៅទូទាំងប្រទេសកម្ពុជា។ កន្លងមក ដើម្បីពង្រីកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ឲ្យបានទូលំទូលាយ ក្រសួងអប់រំនិងមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការជ្រើសរើសគ្រូបង្រៀនមុខវិជ្ជាសង្គម សីលធម៌ ពលរដ្ឋ និងអក្សរសាស្ត្រខ្មែរ មកចូលរួមវគ្គបណ្តុះបណ្តាលនេះបន្ថែមទៀត។*

*កម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍ ត្រូវបានបន្តរហូតមកដល់បច្ចុប្បន្ន ហើយនៅពេលថ្មីៗនេះ ក្រសួងអប់រំយុវជននិងកីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំសិក្ខាសាលាមួយស្តីពី «ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់គរុសិស្សឆ្នាំទី១និងទី២ នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង ចំនួន ៦២នាក់ មកពីខេត្តស្វាយរៀង និងខេត្តព្រៃវែង ដែល*



*គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង កំពុងពិភាក្សាគ្នាអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម នៅក្នុងកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា*

មិនមែនជាគ្រូបង្រៀនមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា។

លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍បានមានប្រសាសន៍ថា ការរៀបចំសិក្ខាសាលាស្តីពី «ការបញ្ជ្រាបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» នេះឡើងក្នុងគោលបំណង អភិវឌ្ឍចំណេះដឹងរបស់គរុសិស្ស-និស្សិត អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ បង្កើនសមត្ថភាព ក្នុងការបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ ទៅកាន់ក្មេងៗជំនាន់ក្រោយ និងជាកត្តាមួយជំរុញឲ្យមានការពិភាក្សាលើប្រវត្តិសាស្ត្រដ៏សោកសៅ ក្នុងប្រទេសកម្ពុជា។ ការបណ្តុះបណ្តាលនេះ គឺមិនត្រឹមតែផ្តល់សារ-


គរុសិស្ស កំពុងធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដល់សិក្ខាកាមចូលរួមដទៃទៀត

សំខាន់ចំពោះការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាការបណ្តុះបណ្តាលមួយជំរុញឲ្យមានសក្តានុពលថ្មី នៅក្នុងវិជ្ជាជីវៈបង្រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិតេយ្យនៅគ្រប់សាលារៀនទាំងអស់ក្នុងប្រទេសកម្ពុជា។

ទោះបីយ៉ាងណា លោកបានបន្តថា ការអប់រំពីអំពើល័យពូជសាសន៍នេះ មិនសំដៅតែទៅលើគ្រូបង្រៀនប្រវត្តិសាស្ត្រទេ ដាក់ស្តែងសិក្ខាសាលាស្តីពី «ការបញ្ជ្រាបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដែលរៀបចំធ្វើថ្ងៃទី២៤ ដល់ថ្ងៃ២៦ ខែកក្កដា ឆ្នាំ២០១៨ នេះ គឺមានតែគ្រូអក្សរសាស្ត្រអង់គ្លេស និងវិទ្យាសាស្ត្រកំព្យូរ័ ដែលសុទ្ធតែមិនមែនមុខវិជ្ជាឯកទេសចូលរួម។ លោកបានបន្ថែមថា ការ-ងារសំខាន់សម្រាប់គម្រោងនេះ គឺធ្វើយ៉ាងផ្សព្វផ្សាយពីប្រ-វត្តិសាស្ត្រខ្មែរក្រហមឲ្យបានជ្រួតជ្រាបទៅដល់សាធារណជន សិស្ស លោកគ្រូ-អ្នកគ្រូ តាមរយៈការបណ្តុះបណ្តាលដែលមានឯកសារត្រឹមត្រូវ មានសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងមានកាលវិភាគច្បាស់លាស់ រួមទាំងវិធីសាស្ត្របង្រៀនថ្មីៗ

ឈាន វណ្ណៈស្រីម៉ៅ ជាគរុនិស្សិតឆ្នាំទី១ ផ្នែកវិទ្យាសាស្ត្រកំព្យូទ័រ មកពីស្រុកកំពង់លាវ ខេត្តព្រៃវែង បានឲ្យដឹងថា «ពេលមករៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះ គាត់មានការពិបាកយល់ខ្លះ ដូចជាការប្រើប្រាស់ពាក្យ អង្គការ និង ខ្មាំង ដែលគាត់មិនធ្លាប់ឮ។ គាត់គ្រាន់តែឮចាស់និយាយថា លំបាក


គរុសិស្សកំពុងអានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់១៩៧៩)

តែមិនបានរៀនស៊ីជម្រៅដូចការសិក្សាថ្ងៃនេះទេ»។

វណ្ណៈស្រីម៉ៅ បានបន្តថា «បន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ គាត់អាចចែករំលែកអ្វីដែលខ្ញុំបានរៀននៅទីនេះ ទោះបីខ្ញុំរៀនខាងវិទ្យាសាស្ត្រកំព្យូទ័រក៏ដោយ។ ឧទាហរណ៍ នៅចុងម៉ោង១០ទៅ១៥នាទី គាត់អាចនិយាយទៅកាន់សិស្សពីប្រវត្តិសាស្ត្រខ្មែរក្រហម ដោយប្រៀបធៀបជាមួយសម័យបច្ចុប្បន្ន ហើយម្យ៉ាងទៀតគាត់នឹងឲ្យសិស្សមើលខ្សែភាពយន្តឯកសារដែលទាក់ទងទៅនឹងប្រវត្តិ សាស្ត្រខ្មែរក្រហម»។

នី ស្រីណៃ ជាគរុសិស្សនៃមជ្ឈមណ្ឌលសិក្សាភូមិភាគខេត្តព្រៃវែង ឯកទេសភាសាអង់គ្លេស និងភាសាខ្មែរ ឆ្នាំទី១។ កាលពីដំបូង ស្រីណៃ ធ្លាប់បានយល់ដឹងអំពីរបបខ្មែរក្រហមតាមរយៈឪពុកម្តាយ និងតាមរយៈការសិក្សា។ ស្រីណៃ បាន

រៀបរាប់ថា នៅពេលដែលគាត់មានកំហុសអ្វីមួយ ឪពុកម្តាយខ្ញុំ តែងតែយករឿងរ៉ាវដែលបានកើតឡើងក្នុងសម័យខ្មែរក្រហមយកមកណែនាំដល់គាត់។ ស្រីណៅ បានបន្ថែមថា មូលហេតុដែលបណ្តាលឲ្យគាត់ចូលរួមកម្មវិធីការអប់រំនៃអំពើប្រល័យពូជសាសន៍នៅថ្ងៃនេះ ពីព្រោះគាត់ចង់ស្វែងយល់បន្ថែមឲ្យបានច្បាស់ និងចង់ស្វែងយល់អំពីព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ថាតើបានកើតឡើងយ៉ាងដូចម្តេច?

ស្រីណៅ បានបញ្ចេញនូវមតិផ្ទាល់ខ្លួនថា កម្មវិធីអប់រំនៃអំពើប្រល័យពូជសាសន៍ថ្ងៃនេះ គឺពិតជាមានសារសំខាន់ចំពោះគរុសិស្ស ក៏ដូចជាខ្លួនគាត់ផ្ទាល់ ព្រោះនៅថ្ងៃខាងមុខគាត់ និងគរុសិស្ស នឹងក្លាយជាគ្រូបង្រៀន ហើយចំណេះដឹងដែលគាត់ទទួលបាននៅថ្ងៃនេះ គាត់នឹងយកទៅចែករំលែកដល់សិស្សរបស់គាត់។ មិនតែប៉ុណ្ណោះ ស្រីណៅ ពិតជាមានអារម្មណ៍ត្រេកអរដែលបានមានឱកាសចូលរួមកម្មវិធីអប់រំនៃអំពើប្រល័យពូជសាសន៍នៅថ្ងៃនេះ ហើយគាត់ក៏ចង់ឲ្យមានកម្មវិធីបែបនេះតទៅទៀត ពីព្រោះគាត់ចង់ឲ្យសិស្សជំនាន់ក្រោយៗទៀតមានឱកាសសិក្សាស្វែងយល់អំពីការអប់រំនៃអំពើប្រល័យពូជសាសន៍ដូចជារូបគាត់ដែរ។

កែវ វឌ្ឍនៈ ជាគរុសិស្សនៃមជ្ឈមណ្ឌលសិក្សាភូមិភាគខេត្តព្រៃវែង ឆ្នាំទី២ ឯកទេសភាសាអង់គ្លេស។ វឌ្ឍនៈ ធ្លាប់បានយល់ដឹងពីសម័យខ្មែរក្រហមតាមរយៈការអានសៀវភៅដែលមានពាក់ព័ន្ធនឹងសម័យខ្មែរក្រហមជាច្រើន ជាពិសេសសៀវភៅដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលមាននៅក្នុងបណ្ណាល័យដែលគាត់កំពុងសិក្សា។ វឌ្ឍនៈ ក៏បានបន្ថែមថា ចំពោះខ្លួនគាត់ផ្ទាល់ពិតជាមានចំណាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយគាត់យល់ឃើញថា វាគឺជាប្រវត្តិសាស្ត្រមួយដែលទើបតែកន្លងផុតថ្មីៗ ដូច្នេះសម្រាប់គាត់ ក៏ដូចជាក្មេងជំនាន់ក្រោយទៀត គួរតែស្វែងយល់ឲ្យបានច្បាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួនដែលបានកើតឡើង។

វឌ្ឍនៈ បានរៀបរាប់ថា គាត់ពិតជាមានអារម្មណ៍សប្បាយរីករាយខ្លាំងណាស់ ដែលបានចូលរួមវគ្គសិក្សាស្តីពីការអប់រំនៃអំពើប្រល័យពូជសាសន៍ថ្ងៃនេះ ព្រោះគាត់ចង់ស្វែងយល់ឲ្យបានស៊ីជម្រៅជាងនេះ និងចង់ទទួលបានឯកសារខ្មែរក្រហមខ្លះៗ ដើម្បីធ្វើការស្វែងយល់បន្ថែមទៀត។ វឌ្ឍនៈ បានបញ្ជាក់ថា នៅពេលគាត់ទទួលបានចំណេះពីប្រវត្តិសាស្ត្រខ្មែរក្រហមកាន់តែច្បាស់ គាត់នឹងយកចំណេះទាំងនេះទៅចែករំលែកដល់សិស្សរបស់គាត់ ដើម្បីឲ្យយល់ពីមូលហេតុដែលបណ្តាលឲ្យកើតមានរបបខ្មែរក្រហម និងត្រូវស្វែងយល់ថា តើរបបខ្មែរក្រហមបានផ្តល់ផលប៉ះពាល់និងបាត់បង់អ្វីខ្លះក្នុងប្រទេសកម្ពុជា។ វឌ្ឍនៈ បានបន្តថា វគ្គសិក្សាស្តីពីការអប់រំនៃអំពើប្រល័យពូជសាសន៍ថ្ងៃនេះ វាពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់ខ្លួនគាត់ ក៏ដូចជាគរុសិស្សដែលបានចូលរួម។ មិនតែប៉ុណ្ណោះ វឌ្ឍនៈ បានស្នើសុំ ឲ្យមានវគ្គសិក្សាស្តីពីការអប់រំនៃអំពើប្រល័យពូជសាសន៍បែបនេះ រៀបចំឡើងរយៈពេលយូរជាងនេះ ព្រោះគាត់យល់ថា ព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងរបបខ្មែរក្រហមមានរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដូច្នេះយើងមិនអាចសិក្សាត្រឹមតែរយៈពេលបីថ្ងៃបានឡើយ។

នៅក្នុងកំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងរបបគ្រប់គ្រងដ៏ឃោរឃៅមួយ ហៅថារបបខ្មែរក្រហម។ របបនេះបានធ្វើឲ្យប្រជាជនកម្ពុជាប្រហែល ២លាននាក់បានបាត់បង់ជីវិតយ៉ាងអយុត្តិធម៌។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ប្រទេសកម្ពុជាបានកំពុងព្យាយាមដោះស្រាយវិបត្តិអតីតកាលរបស់ខ្លួនតាមរយៈការបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់គ្រូបង្រៀន និងសិស្សានុសិស្ស ក្នុងគោលបំណងលើកកម្ពស់ឲ្យមានការចងចាំ យុត្តិធម៌ និងការផ្សះផ្សានាពេលអនាគត។ លើសពីនេះ ការសិក្សាអំពីប្រវត្តិសាស្ត្រ គឺដើម្បីរារាំងនូវការកើតឡើងម្តងទៀត ដែលមានភាពស្រដៀងគ្នានាពេលអនាគត។

***អ៊ុន សុដាវី និង ដារ៉ារដ្ឋ មេត្តា***

# វត្តមានព្រះពុទ្ធសាសនានៅក្នុងសម័យអង្គរ

*លោកបណ្ឌិត នីកូឡាស រីវៀ គឺជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់នៅមជ្ឈមណ្ឌលខេមរៈសិក្សា លោកក៏ជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យសិក្សាស្រាវជ្រាវមូលដ្ឋានគ្រឹះសំខាន់ៗស្តីពីសិល្បៈសម័យបុរាណ* (Liberal Arts) *នៃសាកលវិទ្យាល័យ* Thammasat *នៅទីក្រុងបាងកក ប្រទេសថៃ។ លោកបណ្ឌិត នីកូឡាស រីវៀ បានបញ្ចប់សញ្ញាប័ត្របណ្ឌិតនៅសាកលវិទ្យាល័យបារាំងទី៣ នៅ* Sorbonne *ក្នុងប្រទេសបារាំង ជំនាញខាងសិល្បៈព្រះពុទ្ធសាសនា និងខាងបុរាណវិទ្យានៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដោយលោកបានផ្តោតទៅលើប្រទេសថៃ និងកម្ពុជា មុនសម័យទំនើប។ នៅល្ងាចថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ លោកបណ្ឌិត នីកូឡាស រីវៀ បានរៀបចំធ្វើបាឋកថាសាធារណៈមួយ ស្តីពី «វត្តមានរបស់ព្រះពុទ្ធសាសនានៅក្នុងសម័យអង្គរ» នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស៊ីករីត ស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ។*

*បាឋកថាសាធារណៈនេះ ត្រូវបានរៀបចំឡើងដើម្បីត្រួតពិនិត្យមើលអំពីវត្តមានរបស់ព្រះពុទ្ធនៅក្នុងសម័យអង្គរ ដែលត្រូវបានពិពណ៌នានៅក្នុងរឿងព្រេង។ ការសិក្សាអំពីវត្តមានព្រះពុទ្ធដ៏លម្អិតនេះ គឺមានប្រភពមកពីសម័យអង្គរ រួមទាំងវត្ថុតាងទាំងអស់ដែលបានបន្សល់ទុកតាំងពីសម័យមុន (សតវត្សរ៍ទី១២ ដល់សតវត្សរ៍ទី១៦)។ រឿងព្រេងទាំងនេះ ត្រូវបានរកឃើញនៅទីសក្ការៈព្រះពុទ្ធសាសនា ឬក៏នៅលើផ្ទាំងចម្លាក់ថ្ម ដែលភាគច្រើនមិនត្រូវបានបោះពុម្ពផ្សាយ។ ប៉ុន្តែឥឡូវរឿងព្រេង និងចម្លាក់ថ្មទាំងនេះ ត្រូវបានដាក់តាំងបង្ហាញនៅតាមសារមន្ទីរ ឬនៅតាមឃ្លាំងស្តុក ឬក៏ទីតាំងផ្ទុកវត្ថុបុរាណផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ថៃ និងវៀតណាម។*



*សាធារណជន កំពុងស្តាប់ការធ្វើបទបង្ហាញរបស់លោកបណ្ឌិត នីកូឡាស រីវៀ ពីប្រធានបទស្តីពី "វត្តមានរបស់ព្រះពុទ្ធសាសនានៅក្នុងសម័យអង្គរ"*

ការសិក្សាស្រាវជ្រាវនេះ គឺពឹងផ្អែកទៅលើសារពើភណ្ឌថ្មីៗដែលបានរៀបរាប់ និងបកប្រែអំពីរឿងព្រេងរបស់ព្រះពុទ្ធដែលប្រជាជនទូទៅ បានស្គាល់រហូតមកដល់បច្ចុប្បន្ននេះ។ ចំពោះការសិក្សាស្រាវជ្រាវនេះ គឺបានប្រើប្រាស់ឧបករណ៍ប៉ារ៉ាម៉ែត្រដំបូងគេ ក្នុងការសិក្សាអំពីរចនាបថរូបចម្លាក់ និងឯកសារសិក្សាអំពីវត្តមានព្រះពុទ្ធមុនបរិបទសម័យទំនើបនៅក្នុងប្រទេសកម្ពុជា។ ដោយមានបញ្ហាប្រឈមទាំងអក្សរចារិកជាភាសាបាលី និងការស្រាវជ្រាវដែលមានពីមុនមក ព្រមទាំងចំណុចសំខាន់នៃប្រភពភាសាតាមតំបន់ផ្សេងៗ ការសិក្សាស្រាវជ្រាវនេះ គឺមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវកាលបរិច្ឆេទ និងការស្វែងយល់ពីភាពជឿនលឿន និងភាពមានតែមួយនៃព្រះពុទ្ធសាសនាហីនយាននៅសម័យអង្គរនៃប្រទេសកម្ពុជា និងរីកសាយភាយក្នុងដែនដី អាស៊ីអាគ្នេយ៍នៃរយៈកាលចុងសម័យអង្គរ។

ក្នុងកម្មវិធីបាឋកថាសាធារណៈនេះ ក៏មានការចូលរួមពីសំណាក់សាធារណជនទូទៅជាច្រើន ដូចជា៖ បុគ្គលិក



អង្គការ សាស្ត្រាចារ្យ និងសិស្ស-និស្សិតជាច្រើននាក់ទៀត។

មុននឹងចាប់ផ្តើម បើកកម្មវិធីបាឋកថាសាធារណៈនេះ លោក នីកូឡាស រីវៀ ក៏បានមានប្រសាសន៍ថា ក្នុងដំណើរកិច្ចការងារស្រាវជ្រាវ ទាក់ទងនឹងវត្តមានរបស់ព្រះពុទ្ធនៅទូទាំងអាស៊ីអាគ្នេយ៍នេះ គឺលោកទទួលបានអាហាររូបករណ៍ដើម្បីសិក្សាទៅលើសិលាចារិកដែលពិពណ៌នា ពីវត្តមានរបស់ព្រះពុទ្ធនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ លោក នីកូឡាស រីវៀ ក៏បានបន្ថែមថា បាឋកថានៅថ្ងៃនេះគឺគាត់បង្ហាញតែទិន្នន័យដែលស្ថិតនៅក្នុងដំណាក់កាលដំបូងប៉ុណ្ណោះ ដោយសារតែលោកទើបតែចាប់ផ្តើមការងារស្រាវជ្រាវទាក់ទងនឹងរឿងរ៉ាវទាំងនេះ។ លោក នីកូឡាស រីវៀ បានបញ្ជាក់ថា បាឋកថានៅថ្ងៃនេះនឹងផ្តោតយ៉ាងសំខាន់ទៅលើសិលាចារិកដែលពិពណ៌នាពីការប្រសូត្ររបស់ព្រះពុទ្ធ ហើយវាជាផ្នែកមួយដែលគាត់បានធ្វើយ៉ាងធំទូលាយយូរណាស់មកហើយ។ មិនតែប៉ុណ្ណោះ លោក នីកូឡាស រីវៀ បានប្រាប់ទៅកាន់អ្នកចូលរួមទាំងអស់ថា នៅវគ្គសំណួរចម្លើយនៅខាងចុងនៃការធ្វើបទបង្ហាញ គាត់នឹងធ្វើជាភាសាអង់គ្លេសផង និងភាសាបារាំងដែលជាភាសាដើមរបស់គាត់។

បន្ទាប់ពី លោក នីកូឡាស រីវៀ បានធ្វើបទបង្ហាញទាក់ទងនឹងវត្តមានព្រះពុទ្ធនៅក្នុងសម័យអង្គររួចមក ក៏មានអ្នកចូលរួមមួយចំនួនបានសួរសំណួរទៅកាន់គាត់ដូចខាងក្រោម៖

១) តើធ្វើដូចម្តេច ដើម្បីឲ្យដឹងច្បាស់អំពីរឿងរ៉ាវរបស់ព្រះពុទ្ធដែលបានបង្ហាញនៅក្នុងរូបចម្លាក់?

២) តើមួយណាខុសមួយណាត្រូវរវាងអក្សរចារិកជាភាសាបាលី និងភាសាសំស្ក្រឹត ទាក់ទងនឹងការប្រសូត្ររបស់ព្រះពុទ្ធ?

៣) តើលោកជួបបញ្ហាអ្វីខ្លះ នៅក្នុងការងារស្រាវជ្រាវទាក់ទងនឹងវត្តមានព្រះពុទ្ធនៅក្នុងសម័យអង្គរ?

៤) ហេតុអ្វី បានជាមានរូបចម្លាក់ព្រះពុទ្ធនៅសម័យអង្គរនៅក្នុងវត្តវៀតណាម

ហ៊ូ ថុន

# តើយុវជនជំនាន់ក្រោយយល់យ៉ាងណាចំពោះតុលាការខ្មែរក្រហម?

កាលពីឆ្នាំ២០១៧កន្លងទៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការខ្មែរក្រហម) បានសម្រេចបញ្ចប់សំណុំរឿងអតីតកម្មាភិបាលខ្មែរក្រហមមួយរូបគឺ អ៊ឹម ចែម ដែលបានបង្កភាពចម្រូងចម្រាស់ជាច្រើនក្នុងចំណោមមតិជាតិ និងអន្តរជាតិ ហើយបានចោទជាសំណួរទៅលើប្រសិទ្ធភាពរបស់តុលាការ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការពេញលេញ នៅខែមិថុនា ឆ្នាំ២០០៧ ក្រោមការសហការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ។ តុលាការនេះ បានកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមបានចំនួនពាក់រួចមកហើយ ដែលរួមមាន នួន ជា, ខៀវ សំផន និង កាំង ហ្កេចអ៊ាវ ហៅ ឌុច។ ក្នុងនោះ ករណីរបស់ អ៊ឹម ចែម ត្រូវបានតុលាការបិទបញ្ចប់សំណុំរឿង ដោយលើកឡើងថាហួសពីដែនយុត្តាធិការរបស់តុលាការ ព្រោះតុលាការកាត់ទោសតែមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ប៉ុណ្ណោះ។ ក្នុងរយៈពេលជាង១០ឆ្នាំមកនេះ តុលាការខ្មែរក្រហមនេះបានសម្រេចសមិទ្ធផលដូចជាបានកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់របបខ្មែរក្រហមឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ ក្នុងនោះតុលាការបានចំណាយថវិកាអស់ចំនួន ២៣២.៤លានដុល្លា ដែលក្នុងនោះថវិកាជាតិមានចំនួន ៥៥.៧លានដុល្លា។ តើយុវវ័យជំនាន់ក្រោយគិតយ៉ាងណាចំពោះតុលាការមួយនេះ?

កញ្ញា អោក លីណា អាយុ២៦ ជាគរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង បាននិយាយថា ការបង្កើតតុលាការខ្មែរក្រហមជារឿងមួយដែលល្អក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនខ្មែរ។

កញ្ញាបន្តថា៖ «ការបង្កើតតុលាការខ្មែរក្រហមពិតជាល្អខ្លាំងដើម្បីចាប់ខ្មាំងក្រិដ្ឋជនដែលបានបង្កើតរបបនេះឡើង ក៏



សិស្សវិទ្យាល័យព្រះអង្គឌួងក្នុងខេត្តព្រៃវែង

ដូចជាស្វែងរកយុត្តិធម៌ឲ្យប្រជាជនខ្មែរទាំងមូលឲ្យគាត់អស់មន្ទិលសង្ស័យថាមូលហេតុអ្វីបានជាធ្វើឲ្យមានរបបនេះកើតឡើងមក (និង)មូលហេតុអ្វីដែលធ្វើឲ្យពួកគាត់ (ខ្មែរក្រហម) ចេះតែសម្លាប់ជាតិសាសន៍ឯង សម្លាប់ជាតិសាសន៍គ្នាឯងៗ»

បន្ថែមពីនេះ លោក លន់ ចន្ថា និស្សិតនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានឲ្យដឹងថាការបង្កើតតុលាការនេះឡើងមិនអាចលុបបំបាត់ភាពឈឺចាប់របស់ប្រជាជនខ្មែរដែលធ្លាប់រស់នៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ បានឡើយៗ

និស្សិតផ្នែកប្រវត្តិវិទ្យានេះបានបន្តថា៖ «ខ្ញុំគិតថាការបង្កើតឡើងនេះគឺដើម្បីរកយុត្តិធម៌ឲ្យប្រជាជន ដែលបានឆ្លងកាត់របបនោះ ប៉ុន្តែទោះជាយ៉ាងណា តុលាការមិនអាចរកយុត្តិធម៌ដល់មនុស្សដែលស្លាប់ក្នុងរបបនោះបានទេៗ»

អោក លីណា បាននិយាយថា តុលាការនេះពិតជាបានផ្តល់ប្រយោជន៍យ៉ាងច្រើនដល់យុវជនខ្មែរ ជាពិសេសសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗ

លីណាលើកឡើងថា៖ «ផលប្រយោជន៍ ដែលយុវជនទទួលបានពីតុលាការ គាត់អាចស្វែងយល់ច្រើន ជាពិសេសសម្រាប់អ្នកសិក្សាផ្នែកច្បាប់ គាត់នឹងបានយល់ច្រើនពីរបៀបកាត់ក្តី របៀបសួរចម្លើយ ហើយក៏ដូចជាការជួបជនដែលដល់ដោយផ្ទាល់ៗ»

ចំណែកឯ កើត សុគន្ធា សិស្សថ្នាក់ទី១២នៃវិទ្យាល័យហ៊ុន សែន សំរោង មានបំណងឲ្យតុលាការបន្តការកាត់ក្តីដោយនិយាយថា ៖ «ខ្ញុំសំណូមពរឲ្យតុលាការស្វែងរកយុត្តិធម៌ជូនប្រជាជនដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ព្រោះគាត់ឈឺចាប់ខ្លាំងដោយសារបាត់បង់គ្រួសារ ដូច្នេះខ្ញុំចង់ឲ្យតុលាការរកយុត្តិធម៌បន្តទៀតៗ»

ខណៈពេលនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំពុងដំណើរការសំណុំរឿង០០៣ និង០០៤ ដែលតុលាការបានដាក់ មាស មុត និង អោ អាន ឲ្យស្ថិតក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ស្តីពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងមនុស្សឃាតដោយចេតនាៗ

**នៀវ ជីហ័រ**



គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគព្រៃវែង កំពុងសរសេរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម

# ការយល់ឃើញរបស់អ្នកស្រាវជ្រាវបរទេស បន្ទាប់ពីទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»

«កុំស្មានបងភ្លេច» គឺជាខ្សែភាពយន្តឯកសារប្រវត្តិសាស្ត្រកម្ពុជាមួយ ដែលបាននិយាយអំពីសិល្បៈខ្មែរក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ និងអំពីតន្ត្រីរ៉ក អេន រ៉ូល ដែលខ្មែរបានបាត់បង់ក្នុងអំឡុងពេលប្រទេសកើតមានសង្គ្រាម។ «កុំស្មានបងភ្លេច» ក៏ជាខ្សែភាពយន្តឯកសារមួយដែលបានទាក់ទាញចំណាប់អារម្មណ៍អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិចូលមកទស្សនា និងសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា តាមរយៈចម្រៀងសិល្បៈ តន្ត្រី ដែលផ្លាស់ប្តូរពីសម័យកាលមួយទៅសម័យកាលមួយ និងនៅអំឡុងពេលសង្គ្រាមស៊ីវិល។ មិនតែប៉ុណ្ណោះ ខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» ក៏បានបង្ហាញពីគំហើញថ្មី ស្តីពីប្រទេសមួយដែលធ្លាប់តែឮពីសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ហើយខ្សែភាពយន្តឯកសារនេះ ក៏បានដាក់បញ្ចូលបទចម្រៀងពីសម័យដើមចំនួន៧២បទ ដើម្បីនាំអ្នកទស្សនាឲ្យបានយល់ដឹងអំពីសិល្បៈតន្ត្រីពីសង្គមអតីតកាល និងរហូតមកដល់បច្ចុប្បន្ន។

នៅរសៀលថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ ក៏មានអ្នកសិក្សាស្រាវជ្រាវអន្តរជាតិមួយក្រុម មកពីប្រទេសអាមេរិក និងអូស្ត្រាលី បានចាប់អារម្មណ៍មកទស្សនាខ្សែភាពយន្តឯក-សារ «កុំស្មានបងភ្លេច» នៅក្នុងវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្លឹករឹត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ដោយមានគោលបំណង ចង់ស្វែងយល់អំពីប្រវត្តិសាស្ត្រកម្ពុជាតាមរយៈខ្សែភាពយន្តឯកសារនេះ។ អ្នកសិក្សាស្រាវជ្រាវទាំងនេះយល់ឃើញថា ខ្សែភាពយន្តក៏ជាផ្នែកមួយជួយពន្យល់អំពីប្រវត្តិសាស្ត្រកម្ពុជាឲ្យកាន់តែមានភាពងាយស្រួលយល់ថែមទៀត។

បន្ទាប់ពីបានទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច» រួចមក មានអ្នកចូលរួមម្នាក់ឈ្មោះ ម៉ិឆែល បានបញ្ចេញនូវយោបល់ផ្ទាល់ខ្លួនថា ខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»នេះ ពិតជាមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការជួយចែករំលែកអំពីប្រវត្តិសាស្ត្រកម្ពុជា ជាពិសេសប្រវត្តិសាស្ត្រសម័យខ្មែរក្រហម។ មិនតែប៉ុណ្ណោះ ខ្សែភាពឯកសារនេះ ក៏បានឆ្លុះបញ្ចាំងអំពីសិល្បៈ និងតន្ត្រីខ្មែរដែលបានឈានដល់កម្រិត



កំពូល។ មុីឆែល បានបន្ថែមថា ខ្សែភាពយន្តឯកសារនេះ ក៏បានបង្ហាញអំពីបរិបទសង្គមកម្ពុជាជាច្រើនសម័យ ចាប់តាំងពីប្រទេសកម្ពុជាមិនទាន់កើតមានសង្គ្រាម រហូតដល់ធ្លាក់ក្នុងភ្លើងសង្គ្រាម និងរហូតដល់មានសុខសន្តិភាព។ ម្យ៉ាងទៀត ខ្សែភាពយន្តឯកសារនេះ ក៏បានបង្ហាញពីជីវភាព និងជីវិតប្រចាំថ្ងៃរបស់ប្រជាជនកម្ពុជា ដែលពេញចិត្តក្នុងការរស់នៅប្រកបដោយសុខសន្តិភាព និងការអភិវឌ្ឍន៍ មុនប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាម។ មិនតែប៉ុណ្ណោះ ខ្សែភាពយន្តឯកសារនេះ ក៏បានឆ្លុះបញ្ចាំងនៃការបម្លងវប្បធម៌ និងចម្លងសិល្បៈតន្ត្រីគ្រប់ប្រភេទ ជាពិសេសតន្ត្រីមកពីលោកខាងលិច និងបង្កើតជាសិល្បៈបែបថ្មីរបស់ខ្លួន។ ប៉ុន្តែរាល់អ្វីៗដែលបានខំសាងឡើងទាំងអស់ បែរជាត្រូវបាត់បង់នៅក្នុងអំឡុងពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

មុីឆែល ក៏បានលើកឡើងពីទស្សនៈផ្ទាល់ខ្លួនថា ចំពោះប្រទេសកម្ពុជាសព្វថ្ងៃគឺស្ថិតនៅក្នុងដំណើរការស្តារឡើងវិញពីប្រទេសដែលបានខ្ទេចខ្ទាំដោយសង្គ្រាម ដូច្នេះគឺយើងត្រូវការពេលវេលាមួយឲ្យបានសមស្របក្នុងការស្តារឡើងវិញ។ អ្វីដែល មុីឆែល កត់សម្គាល់នោះគឺប្រទេសកម្ពុជាសព្វថ្ងៃពិតជាមានការអភិវឌ្ឍន៍ និងរីកចម្រើនយ៉ាងខ្លាំងគួរឲ្យកត់សម្គាល់ ព្រោះគាត់ និងក្រុមរបស់គាត់បានដើរកម្សាន្តនៅតាមបណ្តាខេត្តនានា ហើយបានឃើញប្រជាជនកម្ពុជាមានជីវភាពធូរធា និងមានដំណាំបន្លែបង្ការស្ទើរតែគ្រប់ផ្ទះ។

ហូ ថុនា



ក្រុមអ្នកស្រាវជ្រាវអន្តរជាតិមកពីសហរដ្ឋអាមេរិក និងអូស្ត្រាលី មកទស្សនាខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»

# គរុសិស្សនៅខេត្តព្រៃវែងទទួលការបណ្តុះបណ្តាលបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម

នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំសិក្ខាសាលាស្តីពីការបញ្ជ្រាប «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដល់គរុសិស្សនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តព្រៃវែង ដែលប្រព្រឹត្តទៅនៅវិទ្យាល័យព្រះអង្គឌួង ក្រុងព្រៃវែង ខេត្តព្រៃវែង។

សិក្ខាសាលា ដែលមានរយៈពេល៣ថ្ងៃ គិតចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ដោយមានការ ចូលរួមពីសំណាក់គរុសិស្សឆ្នាំទី១និងទី២ចំនួន៦១នាក់។ សិក្ខាកាមទាំងអស់ទទួលបានការបង្ហាត់បង្ហាញពីប្រវត្តិសាស្ត្រខ្មែរក្រហមពីគ្រូខទ្ទេសថ្នាក់ជាតិចំនួន៤នាក់ មកពីក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជា។

នៅក្នុងពិធីបើកសិក្ខាសិលា លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា បានមានប្រសាសន៍ថាការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាកត្តាដែលចាំបាច់ដើម្បីឲ្យយុវវ័យជំនាន់ក្រោយមានការយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេសប្រវត្តិសាស្ត្រខ្មែរក្រហម។

លោកជំទាវបន្តថាមូលហេតុដែលក្រសួងអប់រំ យុវជន និងកីឡា សម្រេចឲ្យមានការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់សិស្សានុសិស្ស គឺដើម្បីការចងចាំ និងការទប់ស្កាត់អំពើហិង្សា និងអំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងម្តងទៀតនៅកម្ពុជា។

សូមបញ្ជាក់ថា សិក្ខាសាលានេះត្រូវបានរៀបចំធ្វើឡើងដើម្បីបញ្ជ្រាបប្រវត្តិសាស្ត្រខ្មែរក្រហម ទៅក្នុងឯកទេសដែលមិនមែនជាឯកទេសប្រវត្តិវិទ្យា។ នេះជាលើកទីមួយហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំសិក្ខាសាលា ហើយមានការចូលរួមពីគរុសិស្សដែលមិនមែនរៀនមុខវិជ្ជាប្រវត្តិវិទ្យា។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួន២៣លើករួចមកហើយ ប៉ុន្តែមានការចូលរួមពីសំណាក់គ្រូប្រវត្តិ-ភូមិ សីលធម៌ពលរដ្ឋ និងគរុសិស្ស-និស្សិតឯកទេសប្រវត្តិវិទ្យាតែប៉ុណ្ណោះ។

លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានថ្លែងនៅក្នុងកម្មវិធីនោះថា សិក្ខាសាលានេះជាផ្នែកមួយក្នុងការអប់រំ និងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហម សម្រាប់យុវវ័យជំនាន់ក្រោយ។ លោកបានបន្តថា ៖ «មជ្ឈមណ្ឌលឯកសារកម្ពុជាមើលឃើញ ពិចក្ខុវិស័យវែងឆ្ងាយដោយស្របទៅតាមយុត្តិ-សាស្ត្រឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ដែលលោកបានមានប្រសាសន៍ថា លោកគ្រូអ្នកគ្រូមានតួនាទីយ៉ាងសំខាន់ដែលមិនអាចកាត់ថ្លៃបានក្នុងការថែរក្សាប្រវត្តិសាស្ត្រកម្ពុជា។ លោកគ្រូ អ្នកគ្រូគឺជាអ្នកបញ្ជា ចង្កូតនាវាប្រវត្តិសាស្ត្រ ដែលដឹកនាំសិស្សានុសិស្សទាំងអស់ឆ្លងកាត់ព្យុះសង្ឃរានៃអតីតកាលដ៏វិការបស់ជាតិយើង ដើម្បីឆ្ពោះទៅកាន់អនាគតដ៏រុងរឿងមួយ។»

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបន្តកិច្ចការរបស់ខ្លួនតទៅទៀត ក្នុងការបង្រៀននិងផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដើម្បីធានាថាការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានជ្រាបទៅដល់ប្រជាជនភាគច្រើន និងសិស្សានុសិស្សភាគច្រើនក្នុងប្រទេសកម្ពុជា។

*ង៉ូវ ជីហ័រ និង ឡុង មុនីវណ្ណ*

# ដំណឹងស្វែងរកកូនប្រុស ផាន់ សុធា បាត់ខ្លួននៅសម័យខ្មែរក្រហម



ផាន់ សុខុម

ខ្ញុំបាទឈ្មោះ ផាន់ សុខុម មានទីកន្លែងកំណើតនៅខាងជើងវត្តទួលទំពូង ក្នុងក្រុងភ្នំពេញ។ ពីមុនសម័យខ្មែរក្រហម ខ្ញុំមានតួនាទីជាទាហានជើងទឹក នៅជ្រោយចង្វារ។ នៅពេលដែលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញឆ្នាំ១៩៧៥ ខ្មែរក្រហម បានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំ ទៅព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំបានរស់នៅខេត្តតាកែវបានមួយរយៈ ទើបខ្មែរក្រហមបានបញ្ជូនគ្រួសារខ្ញុំឲ្យទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ សុផារី ពីមុនជាគ្រូបង្រៀននៅជ្រោយចង្វារ និងម្តាយឈ្មោះ ញឹម យ៉ា ព្រមទាំងកូនប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ ផាន់ សុធា អាយុ៣ឆ្នាំ។ កូនខ្ញុំ ផាន់ សុធា កើតថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៣។

ក្រោយមក ប្រពន្ធរបស់ខ្ញុំបានកើតពិស និងបានស្លាប់នៅពេលខ្មែរក្រហមចាត់តាំងគាត់ ឲ្យទៅធ្វើការនៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ខណៈដែលខ្ញុំត្រូវបានខ្មែរក្រហមបំបែក ចេញពីគ្រួសារឲ្យទៅនេសាទត្រី នៅខាងស្ទឹងសង្កែ ខេត្តបាត់ដំបង។ ចំណែកកូនប្រុសរបស់ខ្ញុំ ដោយសារនៅក្មេងពេកមិនដឹងថាម្តាយស្លាប់ទេ គឺនៅយំឱបសាកសពម្តាយ។

នៅពេលវៀតណាមវាយចូលប្រទេសកម្ពុជាឆ្នាំ១៩៧៩ ខ្ញុំបានទទួលដំណឹងថា មានតាចាស់ម្នាក់បានយកកូនរបស់ខ្ញុំទៅចិញ្ចឹម។ នៅឆ្នាំ១៩៨០ ខ្ញុំបានភៀសខ្លួនទៅនៅជំរំខាវអ៊ីដាង ក្នុងទឹកដីថៃ។ ក្រោយមក ខ្ញុំបានចេញទៅរស់នៅសហរដ្ឋអាមេរិក ប៉ុន្តែមិនដែលបានទទួលដំណឹងពីកូនប្រុសរបស់ខ្ញុំឡើយ។

ដូច្នេះ ប្រសិនបើបងប្អូនណាបានដឹងដំណឹង ឬស្គាល់កូនប្រុសរបស់ខ្ញុំ ផាន់ សុធា សូមទាក់ទងមកខ្ញុំបាទឈ្មោះ ផាន់ សុខុម តាមរយៈអាសយដ្ឋាន៖ #1419 Red Field Rodd, Bel Air, MD (Marry Land) 2115, USA អ៊ីម៉ែល Sxphann@yahoo.com ទូរសព្ទនៅប្រទេសកម្ពុជាលេខ ០១៥ ៩៧១ ១៨៨ ទូរសព្ទនៅកន្លែងធ្វើការផារលេខ ៨១ ៨៣៦ ២៥៩២ និងទូរសព្ទដៃ ៨៨ ៣៨ ១៨៨ ៣១៨ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ទូរសព្ទលេខ ០២៣ ២១១ ៨៧៥។

សូមអរគុណ!

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

(តពីលេខមុន)

ខាត់ ឆុន មានអាយុ២៨ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់ពូខៀវ ខាត់ និងមីង ឌី ប៊ុន យុទ្ធជនធ្វើការនៅពាណិជ្ជកម្មក្រុង (ភ្នំពេញ) ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ១៩៧៦ និងមកដល់គុកទួលស្លែងនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ ១៩៧៦ ជាប់ឃុំឃាំងនៅក្នុងផ្ទះ ខ បន្ទប់ធំ ៥ បន្ទប់តូច ៩។ ខ្មែរក្រហមសម្លាប់ ខាត់ ឆុន នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីឃុំឃាំងអស់រយៈពេល ១៥២ថ្ងៃ។

ខាត់ កម្តែង ហៅ លន់ មានអាយុ៤០ឆ្នាំ គិតត្រឹមឆ្នាំ ១៩៧៧ អតីតទាហានសក្តិ៤កន្លះ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ ពៅ ខាត់ និងអ៊ំស្រី ផេង ប្រែត មានប្រពន្ធឈ្មោះ យក ឡេង ហៅ នាង មានកូនប្រុស៤នាក់ និងកូនស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៦ នៅព្រែកតាគង់ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក២ បន្ទប់ធំ ៩។

ខាន់ សំអុន ហៅ ស្រ៊ាង មានអាយុ២៨ឆ្នាំ គិតត្រឹមឆ្នាំ ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ នុត ខាត់ និងមីង ឯម គីប យុទ្ធនារីកាត់ដេរនៃកងពល៣១០ មានប្តីឈ្មោះ មឿក មុយ ហៅ សាន អនុនយោ-បាយវរៈសេនាតូចនៃកងពល៣១០ ត្រូវខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៣១០ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ៦ បន្ទប់តូច ១៦។ ខ្មែរក្រហមសម្លាប់ ខាន់ សំអុន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

ខាំម៉ៃ ចំរើនស៊ុក មានអាយុ៣១ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខុងណាស៊ុក ខេត្តវៀងច័ន្ទ (ប្រទេសឡាវ) ជាកូនរបស់លោកតា ឆាត ម៉ៅ និងលោកយាយ ណាង បាង មានប្រពន្ធឈ្មោះ ណាង ដាវ មានកូនប្រុស៤នាក់ និងកូនស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកចិន ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកដាក់ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ២ បន្ទប់តូច ៤។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខឹម ជនជាតិសៀម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅខេត្តកំពង់សោម ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី២៤ ខែឆ្នាំដដែល។

ខឹម គុច ហៅ ស៊ិ មានអាយុ២២ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក៥៥ (ព្រែកប្បាស) ខេត្តតាកែវ ជាកូនរបស់ពូខឹម យែងនិងមីងជុំលត យុទ្ធជនកងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកងពល៧០៣។ ខ្មែរក្រហមសម្លាប់ ខឹម គុច នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល ៣២ថ្ងៃ។

ខឹម ឌុន ជាយុទ្ធជនកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល១៧០។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខឹម យ៉ាំ ជាយុទ្ធជនកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកងពល១៧០ និងបញ្ជូនចូលគុកទួលស្លែងនៅថ្ងៃ១៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខឹម យ៉ាំ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៨ថ្ងៃ។

ខឹម សុខុម ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦

នៅកងពលធ្លា១៧០។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ឌឹម សៃ អតីតទាហាន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស្រុកបារាំង ឬភូមិតាលៃ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឌឹម សៃ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៨៤ថ្ងៃ។

ឌូវ បូវសិច ត្រូវបានខ្មែរក្រហមឃាត់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅរោងចក្រកៅស៊ូកង់ និងបញ្ជូនចូលគុកទួលស្លែងនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជ រកឃើញថា កាលបរិច្ឆេទនៃការសម្លាប់មានដល់ទៅ២ ទី១ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦ និងទី២ ខែកញ្ញា ឆ្នាំ១៩៧៧។

ឌូវ សុងឃុន មានអាយុ២៩ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ អតីតសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់ពូ ឌូវ ជួ និងមីង ហាក់ឡាង មានប្រពន្ធឈ្មោះ ឡូវ សៀមគិច មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅភូមិក្បាលកោះទៀវ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក៨ បន្ទប់ ១៥។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា មានកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងរហូតដល់ទៅ៤ខុសគ្នា គឺថ្ងៃទី២ ខែកុម្ភៈ, ថ្ងៃទី៦ ខែមីនា, ថ្ងៃទី១០ ខែមីនា និងថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ឌូវ សុងឃុន នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦។

ខៀវ ឈឿន មានអាយុ១៦ឆ្នាំគិតត្រឹមឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក១០៥ (ត្រាំកក់) ខេត្តតាកែវ ជាកូនរបស់ពូ ឆុន និងមីង ង៉ាន់ ជាកម្មកររទេះភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៦ នៅរទេះភ្លើងភ្នំពេញ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៥ បន្ទប់តូច ៥។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា មានកាលបរិច្ឆេទនៃការមកដល់ទួលស្លែង២ផ្សេងគ្នា គឺថ្ងៃទី៣០ ខែកញ្ញា និងថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខៀវ ថ្មី ជាមេពួកនៅឋាមពល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកន្លែងឋាមពលក្នុងឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខៀវ ធិន អាយុ៣៥ឆ្នាំគិតត្រឹមឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រៃឈរ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ខៀវ ធី និងអ៊ំស្រី កែវ សេង ជាប្រធានពេទ្យស្រុកព្រៃឈរ មានប្រពន្ធឈ្មោះ ថ្វាង ភាង មានកូនស្រី២នាក់ (ស្លាប់) ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅ (ភូមិភាគ) ខត្តរ។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា មានកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង២ខុសគ្នា គឺថ្ងៃទី២៤ ខែកុម្ភៈ និងថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ខៀវ ធិន នៅថ្ងទី១៨ ខែតុលា ឆ្នាំ១៩៧៧។

ខៀវ រុំ ជាអ្នកថតរូបក្នុងកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៥០២ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជ

អាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា មានកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង ៣ខុសគ្នា គឺថ្ងៃទី៦, ១៦ និង ១៧ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខៀវ រ៉ុ នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

ខៀវ វណ្ណថន ហៅ គាំ សំអុន អតីតទាហានសក្តិ២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅខេត្តកំពង់សោម ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនចូលដល់គុកទួលស្លែងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខៀវ វណ្ណថន នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៨ថ្ងៃ។

ខៀវ ស៊ីថា មានអាយុ១៧ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកំពង់ត្របែក ខេត្តព្រៃវែង ជាកូនរបស់ពូ ខៀវ ហ៊ុំ និងមីង សូ ប៊ិច ជាកម្មកររទេះភ្លើង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦ នៅទួលទំពូង (ភ្នំពេញ) ផ្ទះ ១០ បន្ទប់ធំ ៣។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខៀវ ថា ហៅ ស៊ីថា ត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់ចោលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦។

ខៀវ សាគួរ មានអាយុ៣១ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតនិស្សិតរៀនប្រទេសជប៉ុន មានស្រុកកំណើតនៅសំបូរខេត្តក្រចេះ ជាកូនរបស់អ៊ំ ខៀវ កុំ និងអ៊ំស្រី ដុក យោត ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៦ នៅភ្នំពេញ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខៀវ សាយ ហៅ ភិន មានឋានៈកងវរសេនាធំកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦ ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខៀវ សាយ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២០ថ្ងៃ។

ខៀវ សុជាតា ហៅ សាអាត មានអាយុ ១៩ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ជាកូនរបស់ពូ ខៀវ មិន និងមីង ស៊ិង ទេព ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ ខែសីហាឆ្នាំ១៩៧៥ នៅភូមិសំរោង ឃុំស្វាយចេក ស្រុកថ្មពួក ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃដដែល ឃុំឃាំងក្នុងផ្ទះ ក បន្ទប់ធំ ៦ បន្ទប់តូច ៨។ ខៀវ សុជាតា ធ្លាប់ត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅនៅមន្ទីរ ស២១គ មុននឹងសម្លាប់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

ខៀវ ស្រីម ហៅ ខៀវ ទួន មានអាយុ ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ខៀវ ឃឹម និងអ៊ំស្រី ដុំ គួរ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៧ នៅភូមិសំរោង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ ខ្មែរក្រហមបញ្ជូន ខៀវ ទួន មកដល់គុកទួលស្លែងនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៧៨ ឃុំឃាំងក្នុងផ្ទះ ឆ បន្ទប់ធំ ៣ បន្ទប់តូច ៧។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខៀវ ហុកសោ មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ខៀវ ឡេង និងមីង អ៊ីត វ៉ាន យោធានៅមន្ទីរវរៈសេនាធំលេខ១៧ ពោធិ៍ចិនតុង ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៥ នៅមន្ទីរវរៈសេនាធំលេខ១៧ ពោធិ៍ចិនតុង។ ខ្មែរក្រហមបញ្ជូន ខៀវ ហុកសោ មកដាក់ឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក៥ បន្ទប់ ១១ នៅថ្ងៃទី២២ ឬ២៣ ខែមីនា ឆ្នាំ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦។

ខៀវ ហឿន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស៊ីធរកណ្តាល ខេត្តព្រៃវែង ជាកូនរបស់ពូ ខៀវ

យាម និងមីង អោម ដៃ ជាយុទ្ធជនកងពល២៩០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦ នៅកងពល២៩០ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះ ច បន្ទប់ធំ ១ បន្ទប់តូច ១៦។ ខ្មែរក្រហមសម្លាប់ ខៀវ ហឿន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

ខៀវ អ៊ុត ហៅ វ៉ា មានអាយុ២១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅអង្គស្នួល ខេត្តកណ្តាល ជាកូនរបស់ពូ ខៀវ ជុំ និងមីង នូ ទូច យុទ្ធនារី ១៤ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស២១យ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល ២៥ ថ្ងៃ ខ្មែរក្រហមសម្លាប់ ខៀវ អ៊ុត នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។

ខៀវ អែម មានអាយុ៤៦ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅតាខ្មៅ ខេត្តកណ្តាល ជាកូនរបស់អ៊ំ ពេជ ខៀវ និងអ៊ំស្រី អោ សេង ធ្វើការនៅរោងពុម្ព ក២៧ មានប្រពន្ធឈ្មោះ ស៊ិន គីមហេង មានកូនប្រុស២នាក់ និងកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ នៅរោងពុម្ព ក២៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង ក្នុងផ្ទះច បន្ទប់ធំ ១ បន្ទប់តូច ១៦។ ខ្មែរក្រហមសម្លាប់ ខៀវ អែម នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ៨៨ថ្ងៃ។

ខេង គីមឆៃ ហៅ ឆាយ មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកោះធំ ខេត្តកណ្តាល ជាកូនរបស់ពូ ខេង ថ្វី និងមីង ហ៊ាល អ៊ាង មាននាទីជាមេក្រុមផ្សារដំបូលរោងចក្រ នៅបឹងក្រយ៉ាប ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ៣ បន្ទប់តូច ៧។ ខ្មែរក្រហមសម្លាប់ ខេង គីមឆៃ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ ក្រោយឃុំឃាំងអស់រយៈពេល ៥៦ថ្ងៃ។

ខែ ហេង ហៅ ណូ មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ ឈាង ហុង និងអ៊ំស្រី ឈួន យន់ ប្រធានបញ្ជីពាណិជ្ជកម្មក្រៅប្រទេស នៃពាណិជ្ជកម្មរដ្ឋ មានប្រពន្ធឈ្មោះ សុក ហួយ ហៅ ជាតិ (ប្រធានផ្សារបរទេស មន្ទីរ ប១) មានកូនស្រី១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ៥ បន្ទប់តូច ៦។ ខ្មែរក្រហមសម្លាប់ ខែ ហេង នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ក្រោយឃុំឃាំងអស់រយៈពេល ១១៦ ថ្ងៃ។ ប្រពន្ធឈ្មោះ សុក ហួយ ត្រូវបានខ្មែរចាប់បញ្ជូនទៅនៅមន្ទីរ ស២១យ មុននឹងបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែង នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៨ ហើយសម្លាប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨។

ខែក ស៊ីថា ហៅ ខែក សុផាត មានអាយុ២២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅអូររាំងឪ ខេត្តកំពង់ចាម ជាកូនរបស់ពូ ខែក មាង និងមីង ហាក់ ម៉ុល យុទ្ធជនរោងចក្រអគ្គីសនីទី៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ជ បន្ទប់ធំ ៤ បន្ទប់តូច ១៤។ ខ្មែរក្រហមសម្លាប់ ខែក ស៊ីថា នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៨ ក្រោយឃុំឃាំងអស់រយៈពេល ៩៣ថ្ងៃ។

ខែក សឿន ជាសមាជិកអនុសេនាធំនៃកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមបញ្ជូន ខែក សឿនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃទី៧ ខែតុលា គឺរំលង ២១ថ្ងៃក្រោយមក។

ខ្ញឹង ជិន ជាយុទ្ធជនកងពល៥០២ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល៥០២។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង

មាន២គឺ ថ្ងៃទី១៩ និងទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខ្វឹង ជិន នៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៦។

ខ្វឹង ស៊ីហៀង ជាប្រពន្ធរបស់ឈ្មោះ គូស៊ុម សូវ៉ាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ហើយសម្លាប់ចោលនៅថ្ងៃបន្ទាប់។ ប្តីត្រូវបានខ្មែរក្រហមចាប់ខ្លួនមុនប្រពន្ធតែ២ថ្ងៃប៉ុណ្ណោះ។

ខូត សុខុម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្ថានីយរថភ្លើង ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វរកឃើញថា កាលបរិច្ឆេទនៃការមកដល់គុកទួលស្លែងមាន៣ គឺថ្ងៃទី៨, ៩ ឬ១១ ខែកញ្ញា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ខូត ស៊ីហៀង នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។

ខូត ស្រ៊ី មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់ពូ ឈឹម ខូត និងមីង អ៊ុំម ឈឿង មានប្រពន្ធឈ្មោះ សុក កន មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ល បន្ទប់ធំ ៣ បន្ទប់តូច ១៨។ ខ្មែរក្រហមសម្លាប់ ខូត ស្រ៊ី នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៨ថ្ងៃ។

ខ្វាច បូវឡឹម អាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅខេត្តវិចយ៉ា (វៀតណាម) ជាកូនរបស់លោក ខ្វិច វ៉ាន់ឃឿង និងលោកស្រី ខៃវ ណាំងអាយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកោះរ៉ៃ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ១ បន្ទប់តូច៣។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

ខ្វែង សំរួត មានអាយុ៣៤ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសេរីសោភ័ណ (ខេត្តបន្ទាយមានជ័យ) ជាកូនរបស់អ៊ុំ ខ្វែង និងអ៊ុំស្រី ណាក់ ហួន ជាប្រជាជនលើកភ្លឺ ជីកប្រឡាយ (នៅបន្ទាយមានជ័យ) មានប្រពន្ធឈ្មោះ ផន ស មានកូនប្រុស៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៧៦ រួចបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ក្នុងផ្ទះ ឃ បន្ទប់ធំ ៤ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ ខ្វែង សំរួត នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១៣៧ថ្ងៃ។

គង់ ទៀង មានអាយុ៤៦ឆ្នាំ មានស្រុកកំណើតនៅកៀនស្វាយ ខេត្តកណ្តាល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅតំបន់៣៣ និងបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី១ ឬ២ ខែមេសា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ គង់ ទៀង នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦។

គង់ អាន ហៅ សំអន មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅមានជៃថ្មី ខេត្តស្វាយរៀង ជាកូនរបស់អ៊ុំស្រី គង់ នួន ហៅ ទូច មានប្រពន្ធឈ្មោះ សោម សាមុត ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ ក្នុងបន្ទប់ធំ ៧ បន្ទប់តូច ២៨។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គង់ គាត មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៦ ស្រុកកំណើតនៅស៊ីធរកណ្តាល ខេត្តព្រៃវែង ជកូនរបស់ពូ រ៉ុក គង់ និងមីង ភឹម ម៉ៃ ជាប្រធានផ្នែកនៅរោងចក្រកែវ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រកែវ ថ្ងៃទី១៤ ខែវិច្ឆិកាឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ១ បន្ទប់តូច ១៣។ ខ្មែរក្រមសម្លាប់ គង់ គាត នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ ក្រោយពីជាប់ឃុំឃាំងអស់រយៈពេល ១២៥ថ្ងៃ។

(តទៅលេខក្រោយ)

វ៉ាន់ថាន់ ពៅដារ៉ា

មជ្ឈមណ្ឌលឯកសារកម្ពុជា

# ម៉េង ឆេង ៖ មន្ត្រីរដ្ឋបាលព្រលានយន្តហោះ

ខ្ញុំមានសំណាងខ្លាំងណាស់ដែលមានជីវិតនៅរស់ពីរបបខ្មែរក្រហម។ ម្ដាយខ្ញុំ និងបងប្អូនប្រាំនាក់ទៀត ក្នុងចំណោមប្រាំបីនាក់បានស្លាប់។ ខ្ញុំបានកុហកអង្គការថា ខ្ញុំជាអ្នកដាក់ស៊ីក្លូ។

ឈ្មោះដើមខ្ញុំគឺ ម៉េង ឆេង ជាឈ្មោះចិនដែលធ្វើឲ្យខ្ញុំពិបាកខ្លាំងណាស់ ក្នុងការស្វែងរកការងារធ្វើ។ នៅមុនរបប លន់ នល់ ខ្ញុំបានប្ដូរឈ្មោះខ្ញុំទៅជា គា សុធី ជំនួសវិញ។

បន្ទាប់ពីខ្ញុំបានរៀបការជាមួយ តាំង សុដានី នៅឆ្នាំ១៩៧០ យើងរស់នៅក្បែរព្រលានយន្តហោះពោធិចិនតុង ខាងលិចទីក្រុងភ្នំពេញ។ បងប្រុសខ្ញុំ ឈុន និងខ្ញុំបានចាប់ផ្ដើមធ្វើការនៅព្រលានយន្តហោះ នៅឆ្នាំ១៩៧១។ ខ្ញុំជាអ្នកត្រួតពិនិត្យមើលអ្នកធ្វើដំណើរ និងផលិតផលទំនិញចេញចូល។ នៅពេលទំនេរ ខ្ញុំបានរៀនភាសាបារាំងដែលធ្វើឲ្យខ្ញុំងាយស្រួលប្រាស្រ័យទាក់ទងជាមួយអាកាសយានិក ដែលជាជនជាតិលាវ។



ម៉េង ឆេង អាយុ២៧ឆ្នាំ នៅក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧១

នៅឆ្នាំ១៩៧៣ ការធ្វើដំណើរបានចាប់ផ្ដើមជួបគ្រោះថ្នាក់ខ្លាំងនៅក្នុងប្រទេសកម្ពុជា សម្រាប់អ្នកធ្វើដំណើរតាមផ្លូវគោក និងផ្លូវទឹក។ ផ្លូវជាច្រើនត្រូវបានដាក់គ្រាប់បែកបំផ្លាញ និងជាសមរភូមិប្រយុទ្ធនៅតាមបណ្ដោយផ្លូវទាំងពីរ។ ដូច្នេះ អ្នកធ្វើដំណើរដែលមានប្រាក់អាចធ្វើដំណើរតាមយន្តហោះវិញ។ ជាញឹកញាប់មានភ្ញៀវពី៣៥ ទៅ៦០នាក់ បានធ្វើដំណើរតាមជើងយន្តហោះទៅកាន់បណ្ដាខេត្តនានា។

នៅព្រឹកថ្ងៃទី១៧ មេសា ១៩៧៥ ខ្ញុំបានធ្វើដំណើរតាមជើងហោះហើរទៅខេត្តកំពង់ឆ្នាំង ដើម្បីទៅមើលទំនិញខ្លះដែលត្រូវផ្ញើមកទីក្រុងភ្នំពេញ។ យ៉ាងណាក៏ដោយ នៅពេលដែលយើងព្យាយាមត្រឡប់មកវិញ យន្តហោះមិនត្រូវបានអនុញ្ញាតឲ្យហោះហើរទៀតទេ។ អាកាសយានិកជាជាតិលាវបាននិយាយថា គាត់នឹងត្រឡប់ទៅប្រទេសលាវវិញ និងបានសួរខ្ញុំថាចង់ទៅជាមួយគាត់ទេ? ពេលនោះ ខ្ញុំបានប្រកែកថាមិនចង់ទៅទេ ខ្ញុំចង់ត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំ នៅខេត្តកណ្ដាលវិញ។ ពេលខ្លះខ្ញុំបានដឹងថា ប្រទេសជាតិកើតមានអសន្តិសុខ ហើយខ្ញុំបានពិភាក្សារឿងនេះរួចហើយជាមួយប្រពន្ធខ្ញុំ។

សុដានី ត្រូវបានជម្លៀសចេញទៅមុនខ្ញុំ នាងបានពកូនប្រុសយើងរហូតនៅតាមផ្លូវ ប៉ុន្តែកូនប្រុសខ្ញុំបានស្លាប់ដោយសារកម្ដៅថ្ងៃ និងការអត់ឃ្លានមុនពេលទៅដល់ស្រុកភូមិយើង។ខ្ញុំបានចំណាយពេលមួយខែជាងទើបបានជួបសុដានី។ ប៉ុន្តែបន្ទាប់ពីខ្ញុំបានទៅដល់ អង្គការបានឲ្យយើងចេញទៅខេត្តបាត់ដំបង។ នៅពេលដែលអង្គការសួរខ្ញុំអំពីប្រវត្តិរូប ខ្ញុំបាន

ប្រាប់ថា ខ្ញុំជាអ្នកផាក់ស៊ីក្លូ។

យើងត្រូវបានបញ្ចូលទៅក្នុងសហករណ៍មួយ នៅបាត់ដំបង។ នៅទីនោះប្រជាជនមូលដ្ឋានមិនធ្វើការធ្ងន់ធ្ងរដូចប្រជាជនថ្មីទេ។ ប្រជាជនមូលដ្ឋានមានរបបអាហារច្រើន ហើយអនុញ្ញាតឲ្យទុកដាក់ស្រូវអង្ករនៅក្នុងផ្ទះផង។ ប្រជាជនមូលដ្ឋាន ហូបបាយស្មើរតែរាល់ពេល ខណៈដែលប្រជាជនថ្មីបានហូបបាយនៅពេលមានឱកាសពិសេសប៉ុណ្ណោះ មិនដូច្នោះយើងហូបបបររាវ។ យើងរស់នៅដាច់ដោយឡែកពីគ្រួសារ ខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យទៅជួបប្រពន្ធខ្ញុំទេ។

គណៈសហករណ៍ឈ្មោះ អេន ជាមនុស្សកាចសាហាវ និងឃោរឃៅណាស់។ គាត់បានចាប់រំលោភកូនស្រីអ្នកភូមិជាច្រើននាក់។ ខ្ញុំបានឃើញ អេន រំលោភក្មេងស្រីម្នាក់រួចសម្លាប់នាងចោល។ ពេលខ្លះគាត់បានវះពោះមនុស្សហើយយកថ្លើមទៀត។ ភ្នែករបស់គាត់ឡើងក្រហមខ្លាំង។

បងប្រុសខ្ញុំឈ្មោះ គា ឈុន មានឋានៈខ្ពស់ជាងគេនៅក្នុងចំណោមកូនៗនៅក្នុងគ្រួសាររបស់ខ្ញុំ។ គាត់ឆ្លាតណាស់ និងអាចនិយាយភាសាបរទេសបានច្រើនភាសាទៀតផង។ គាត់បានសិក្សានៅប្រទេសអាល្លឺម៉ង់អាមេរិក បារាំងអូស្ត្រាលី និងប៊ុលហ្គារី។ ឈុន ជាអ្នកគ្រប់គ្រងនៅព្រលានយន្តហោះ បានជួយខ្ញុំរកបានការងារធ្វើនៅទីនោះ និងជួយប្អូនប្រុសខ្ញុំឈ្មោះ គា ម៉េងលាង បានចូលធ្វើជាភ្នាក់ងារទេសចរណ៍ឯកជនមួយកន្លែង។ គាត់បានជួយប្អូនស្រីខ្ញុំពីរនាក់ទៀត ឲ្យបានចូលធ្វើជាអ្នកបម្រើការតាមយន្តហោះ។ ឈុន មានផ្ទះវីឡាធំមួយនៅក្នុងក្រុងភ្នំពេញ។

នៅពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង ឈុន បានទៅស្រុកកំណើតខាងប្រពន្ធរបស់គាត់នៅខេត្តកណ្ដាល។ គាត់បានដាក់របស់ប្រើប្រាស់ផ្ទាល់ខ្លួនចូលទៅក្នុងរថយន្ត ប៉ុន្តែបានបោះបង់វាចោលនៅពេលទៅដល់តំបន់ដែលមានទឹកជំនន់មួយ។ មុនដំបូង ឈុន ប្រពន្ធ និងកូនគាត់ប្រាំនាក់ បានរស់នៅត្រើយម្ខាងពីគ្រួសារយើង ប៉ុន្តែបន្ទាប់មកគាត់ត្រូវបានជម្លៀសទៅបាត់ដំបង។

នៅទីនោះបុរសម្នាក់ធ្លាប់បានធ្វើការជាមួយ ឈុន បានប្រាប់អង្គការថា ឈុន ជាវរសេនីយ៍ឯកនៅព្រលានយន្តហោះ។ បងប្រុសខ្ញុំ មានការហត់នឿយខ្លាំងដោយសារកង្វះម្ហូបអាហារ។ គាត់បានសម្រេចចិត្តរត់ចេញ នៅពេលដែលបានដឹងពីរឿងនេះ។ គាត់បានព្យាយាមរត់នៅលើកទីមួយ និងបានវង្វេងផ្លូវនៅក្នុងព្រៃ។ អង្គការចាប់គាត់បាន ហើយប្រាប់ថា «កុំរត់ទៀត ប្រសិនបើហូបមិនគ្រប់គ្រាន់ ប្រាប់អង្គការឲ្យដឹង»។ នៅពេលដែលគាត់រត់ចេញជាលើកទីពីរ គាត់ត្រូវបានចាប់ខ្លួនម្តងទៀត។ កម្មាភិបាលបានដាក់ទោសគាត់ឲ្យរែកទឹកបំពេញពាងធំមួយឲ្យពេញក្នុងមួយថ្ងៃ។ ឈុន មិនអាចបំពេញការងារនោះបានទេ ពីព្រោះគាត់អស់កម្លាំង



យ៉ាងខ្លាំង រួមនឹងការអត់បាយផងៗ កម្មាភិបាលបានសម្លាប់គាត់នៅក្បែរពាងទឹកធំនោះៗ កម្មាភិបាលក៏បានចាប់ប្រពន្ធគាត់ទៀត ព្រោះប្រពន្ធរបស់គាត់បានលួចអង្ករពីផ្ទះបាយសហករណ៍ ហើយបន្ទាប់មកក៏សម្លាប់ចោលទៅៗ

បន្ទាប់ពីនេះ នៅឆ្នាំ១៩៧៨ ម្តាយខ្ញុំ និងបងប្រុសម្នាក់ទៀតបានស្លាប់ដោយសារការអត់ឃ្លានៗ នៅក្នុងខែមករា ឆ្នាំ១៩៧៩ ប្រធានអង្គភាពយើងបានហៅអ្នកភូមិទាំងអស់ឲ្យចូលរួមប្រជុំមួយ គាត់បាននិយាយថា «ប្រទេសរបស់យើងនឹងមានសន្តិភាពឆាប់ៗនេះ សូមមេត្តាកុំប្រកាន់អី ខ្ញុំមិនអាចនៅជាមួយអ្នកទាំងអស់គ្នាបានទេ ព្រោះខ្ញុំត្រូវចេញទៅឆ្ងាយ»ៗ ពីរបីថ្ងៃបន្ទាប់មក នៅទីនោះមានស្គរកាំភ្លើងធំនិងរថយន្តច្រើនគ្រឿងផ្ទុកកម្មាភិបាលខ្មែរក្រហមពេញណែនបានបើកយ៉ាងលឿនចូលទៅក្នុងព្រៃៗ ខ្ញុំបានលាក់ទុកវិទ្យុមួយនៅនឹងដើមឈើ ហើយយកវាមកបើកស្តាប់ វិទ្យុបានប្រកាសថា ប្រទេសកម្ពុជានឹងត្រូវរំដោះឆាប់ៗនេះៗ

បន្ទាប់មក ប្រពន្ធរបស់ខ្ញុំ និងខ្ញុំបានវិលត្រឡប់មកភ្នំពេញវិញៗ នៅក្នុងចំណោមបងប្អូនយើងទាំងអស់ មានតែប្អូនស្រីខ្ញុំពីរនាក់ និងខ្លួនខ្ញុំបានរស់រានមានជីវិតៗ ក្រោយមកខ្ញុំបានដឹងថា កូនៗរបស់ ឈុន បីនាក់នៅរស់ៗ ខ្ញុំបានរកឃើញពួកគេ និងយកមកចិញ្ចឹមថែរក្សាតាំងពីពេលនោះមកៗ

ប៉ាង ពីរ័ន្ត និង វេនី ខកហ្មៀល



សមាជិកក្រុមគ្រួសាររបស់ ម៉េង ឆេង៖ ម្តាយរបស់ម៉េង ឆេង (រូបទី២រាប់ពីខាងឆ្វេងដៃ) និងយាយរបស់ ម៉េង ឆេង(រូបទី៤ រាប់ពីខាងឆ្វេងដៃ)




មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 224, August 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 0291 P.M/99, 2 August 1999.